ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការយល់ដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងសង្គម



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ... អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅ " ការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៨ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ២០០៥-២០០៩
- យោងសេចក្តីណែនាំលេខ០៣ អយក.សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២
- យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេសនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

ប្រការ១- អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ" ការយល់ដឹងផ្ទាល់ខ្លួននិងទំនាក់ទំនងសង្គម " ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់អង្គការអប់រំពិភពលោកសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀននិងរៀនកម្មវិធីបំណិនជីវិតនៅតាមអនុវិទ្យាល័យ ។

ប្រការ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ កញ្ញា ឆ្នាំ២០១៣

អ៊ឹម_សិទ្ធី

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ ឯកសារ

E-mail: crsmeys@camnet.com.kh / yangyanc@camnet.com.kh Web Site: www.moeys.gov.kh

## គណៈកម្មការអភិវឌ្ឍសៀវភៅ
## "ការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម"

### គណៈកម្មការនិពន្ធ និងរៀបរៀង

១. លោក អេង សុខ
២. ស៊ូ ហ្លោដិហ្វើ
៣. វិលៀម វ៉ាន់ឌឺវ៉ាល់

### គណៈកម្មការកែសម្រួល

១. លោក ឈុំ វណ្ណធន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

### គណៈកម្មការត្រួតពិនិត្យ

១. លោក មាស ជុតិមា
២. លោក ឃិន ធី

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា.................................................................................... ក

វត្ថុបំណងរួម.................................................................................... ខ

ការត្រៀមលក្ខណៈមុខពេលបង្រៀន.................................................................................... ខ

ខ្លឹមសារសង្ខេប.................................................................................... គ

មេរៀនទី ១: ការយល់ដឹងផ្ទាល់ខ្លួន.................................................................................... ១

មេរៀនទី ២: ស្គាល់ខ្ញុំ ស្គាល់អ្នក.................................................................................... ៦

មេរៀនទី ៣: ខ្ញុំត្រូវការអ្នក អ្នកត្រូវការខ្ញុំ.................................................................................... ១២

មេរៀនទី ៤: រក្សាការសម្ងាត់.................................................................................... ១៨

មេរៀនទី ៥: ពិភពខាងក្នុងរបស់ខ្ញុំ.................................................................................... ២៣

មេរៀនទី ៦: តើខ្ញុំជានរណា?.................................................................................... ២៩

មេរៀនទី ៧: ការផ្លាស់ប្តូរអត្តចរិតផ្ទាល់ខ្លួន.................................................................................... ៣៥

មេរៀនទី ៨: ការបង្ហាញអារម្មណ៍ .................................................................................... ៤០

មេរៀនទី ៩: ការគ្រប់គ្រងអារម្មណ៍.................................................................................... ៤៥

មេរៀនទី ១០: ការរួបរួមទាំងអស់គ្នា.................................................................................... ៥១

# អារម្ភកថា

វិស័យអប់រំជាវិស័យគន្លឹះមួយ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្ត នៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹង ផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងពង្រឹងជំនាញផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិនចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

ឯកសារស្តីអំពី "ការយល់ដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងសង្គម" មានបំណងជួយអ្នករៀនឱ្យទទួលបានចំណេះដឹង បំណិន និងបទពិសោធន៍ ក្នុងផ្នែកបំណិនដែលទាក់ទងនឹង **ការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម** ។ **ការ យល់ដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងសង្គម** មានតួនាទីសំខាន់មសម្រាប់គ្រួសាររបស់យើងនិងសហគមន៍។ **ការរៀនពីការយល់ដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងសង្គម** តាំងពីនៅវ័យក្មេង គឺជាការផ្សារភ្ជាប់ទៅនឹងតម្រូវការទៅតាមអាទិភាព និងគោលបំណងដែលនឹងជួយមនុស្សវ័យក្មេង ឱ្យជៀសផុតពីការប្រឈមនឹងបញ្ហា ដែលបណ្តាលមក ពីកង្វះការយល់ ដឹងក្នុងការរស់នៅនិងការឱ្យតម្លៃខ្លួនឯង។

សម្ភារៈ និងធនធានជាច្រើន បានបង្កើតឡើងរួចរាល់ នៅជុំវិញប្រធានបទ ដែលស្តីអំពីការយល់ដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងសង្គម។ សម្ភារៈទាំងអស់នេះ ត្រូវបានយកទៅសាកល្បង និងរចនាឡើងទុកជា មុន ដោយផ្អែកទៅលើការវាយតម្លៃនៃលទ្ធផលរបស់ការសាកល្បងផ្នែកនេះ។ ដូច្នេះឯកសារនេះ កាន់តែមានប្រសិទ្ធភាពដើម្បីយកទៅ ប្រើប្រាស់ ព្រោះវាបានធ្វើការសាកល្បងរួច ជាងការច្នៃប្រឌិតឯកសារផ្សេង។

មេរៀន នៅក្នុងម៉ូឌុលនេះ គឺត្រូវបានយកលំនាំតាមប្រភពសំខាន់ៗចំនួន២ គឺទី១ ប្រភពពី GIZ "កម្រងឧបករណ៍បណ្តុះបណ្តាលសម្រាប់មនុស្សវ័យក្មេងស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ" ២០១០ *(ក្រសួងកិច្ចការនារី សហការជាមួយ GIZ )* *ទី២ គឺ* ការអប់រំកុមារអំពីផ្នែកហិរញ្ញវត្ថុ១ *(ការអប់រំកុមារទ ាក់ទងទៅនឹងសង្គមនិងហិរញ្ញវត្ថុ ដែលដកស្រង់ចេញពីសៀវភៅសកម្មភាពកុមារ អាហ្វ្លាតែទូន អង្គការការពារកុមារអន្តជាតិ គេហទំព័រ www.aflatoun.org និង អ៊ីមែល info@aflation.org)* និងសង្គម របស់អាហ្វ្លែតទូន។ មាតិកា និងខ្លឹមសារពីប្រភពទាំង២នេះ បានបង្កើតជា ទម្រង់មួយដែលត្រូវបានរចនាឡើង ដើម្បីឱ្យគ្រូនៅមធ្យមសិក្សាបឋមភូមិផ្នែកបំណិនជីវិត និងសិស្សរបស់ពួកគេប្រើប្រាស់។

សិស្សដែលសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ គឺជាវ័យមួយ ដែលពួកគេត្រូវឆ្លងកាត់ដំណាក់កាលផ្លាស់ប្តូរពីកុមារភាព ទៅកាន់វ័យជំទង់។ ដើម្បីជួយពួកគេឱ្យឆ្លងកាត់ដំណាក់កាលនេះ ប្រកបដោយការពិចារណា និងវិធីវិជ្ជមាននោះ យើងចាំបាច់ត្រូវឱ្យពួកគេស្វែងរកមើលថា តើពួកគេជានរណា ហើយតើពួកគេមានសមត្ថភាពខាងផ្នែកអ្វី។ ដើម្បីធ្វើដូច្នេះបាន ពួកគេត្រូវតែមានពេលវេលាល្អ សម្រាប់ធ្វើការឆ្លុះបញ្ចាំងខ្លួនពួកគេផ្ទាល់ និងការរៀនមើលផ្លូវចិត្តខ្លួនឯង ដើម្បីឱ្យពួកគេអាចយល់អំពីផ្លូវចិត្ត និងអារម្មណ៍ ដែលជះឥទ្ធិពលមកលើអ្វី ដែលពួកគេគិត និងមុនប្រព្រឹត្តអ្វីមួយ។

កាលណាមនុស្សវ័យក្មេង យល់ដឹងអំពីខ្លួនឯងកាន់តែច្រើន នោះពួកគេកាន់តែអាចមានលទ្ធភាពនាពេលបច្ចុប្បន្ន ដើម្បីបង្កើនឥទ្ធិពលជាវិជ្ជមានទៅលើការរស់នៅក្នុងឆាកជីវិតរបស់ពួកគេទាំងនៅក្នុងពេលបច្ចុប្បន្ន ទាំងថ្ងៃអនាគត។ ការស្គាល់កាន់តែច្បាស់អំពីខ្លួនរបស់ពួកគេ មានន័យថា ពួកគេកំពុងតែធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីបង្កើនចំណងទាក់ទងប្រកបដោយការគោរពជាមួយអ្នកដទៃ ។

## ១. វត្ថុបំណងរួម

*បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន ហើយបំណិនទាំងនេះ រួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព ដើម្បីដោះស្រាយបញ្ហាក្នុងជីវិតប្រចាំថ្ងៃបានយ៉ាងជោគជ័យ។*

វត្ថុបំណងនៃការបង្កើតម៉ូឌុលនេះ គឺជួយបង្កើនការយល់ដឹងដល់សិស្សានុសិស្ស អំពីខ្លួនរបស់ពួកគេផ្ទាល់ និងអ្នកដទៃដើម្បីឱ្យពួក គេអាចឆ្លងកាត់ឆាកជីវិតរបស់ពួកគេបាន នៅពេលដែលការផ្គត់ផ្គង់តម្រូវការមនុស្សកាន់តែត្រូវការលើកកំពស់ការមានទំនាក់ទំនង ការចេះយោគយល់គ្នាទៅវិញទៅមក ការថែរក្សាសុខុមាលភាព រួមបញ្ចូលគ្នានិងបុគ្គលឱ្យកាន់តែមានប្រសិទ្ធភាព។ ម៉ូឌុលបំណិនជីវិត ដែលទាក់ទងនៅក្នុងសង្គម បានដើរតួនាទីយ៉ាងសំខាន់នៃ បំណិនជីវិតដែលនឹងរៀបចំសិស្សឱ្យមានការទំនាក់ទំនងជាមួយនឹងសង្គម។ ការផ្តោតទៅលើការបង្កើនជំនឿចំណេះដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងជាវិជ្ជមានជាមួយនឹងអ្នកដទៃ នឹងជួយ សិស្សទាំងអស់គ្នាឱ្យមានទំនាក់ទំនងកាន់តែទូលំទូលាយ ជាមួយនឹងសង្គមតាមរយៈប្រធានបទទាំងអស់នោះ ដែលមួយចំនួនសិស្សបានបានដឹងរួចហើយ។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះត្រូវបានបែងចែកជាផ្នែកខុសៗគ្នា។ ក្នុងផ្នែកនីមួយៗមាន គោលបំណងរបស់វា ព័ត៌មានទាក់ទងនឹងរបៀបចាប់ផ្តើមបង្រៀនសិស្ស ឬផ្នែកដែលទាក់ទងនឹងសកម្មភាពក្នុងការរៀន ការណែនាំអំពីរបៀបរៀបចំសម្ភារៈដែលត្រូវការសម្រាប់ធ្វើសកម្មភាព។

- **សម្ភារឧបទេស**

ផ្នែកនេះរៀបរាប់បង្ហាញពីសម្ភារឧបទ្ទេស ដែលត្រូវមានសម្រាប់បង្រៀនសិស្ស។ ភាគច្រើនជាសម្ភារៈមូលដ្ឋាន ដូចជា ប៊ិក ឬក្រដាស។ សម្ភារៈផ្សេង ទៀតនៅក្នុងមេរៀននេះនឹងត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្ត តាមរយៈឯកសារសម្រាប់សិស្ស ដែលបានភ្ជាប់នៅក្នុងម៉ូឌុលនេះ។

- **លទ្ធផលរំពឹងទុក**

សិស្សនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថពីការសិក្សាមេរៀនការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម ដែលឆ្លុះបញ្ចាំងទៅនឹងគោលបំណងរួមរបស់បំណិនជីវិត ដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងកំណត់នៅក្នុង *បំណិនជីវិតតាមមូលដ្ឋាន ដូចជាការសិក្សាជំនួញ បំណិនសេដ្ឋកិច្ច និង បំណិនអាជីពងាយៗ។*

- **សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ**

សញ្ញាខាងក្រោមនេះ សម្រាប់សម្គាល់សកម្មភាពបង្រៀន ដើម្បីគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀននិងរៀន។

ធ្វើសកម្មភាព ៖ គ្រូចាំបាច់ត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន

សរសេរ ៖ ពេលខ្លះត្រូវការឱ្យគ្រូសរសេរនៅលើក្តារខៀន

សួរ ៖ មានសំណួរ ដែលត្រូវសួរសិស្ស

ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ ផ្នែក។ ផ្នែកទី១ គឺជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹងដែលសិស្សមានស្រាប់ ឬរំឭកមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗដោយផ្អែកលើវិធីសាស្ត្របង្រៀនសកម្ម (ចុះស្រាវជ្រាវ ប្រមូលព័ត៌មាន សម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ គឺវាយតម្លៃចំណេះដឹងសិស្សក្រោយពីបានរៀនចប់ម៉ូឌុលនីមួយៗ តាមរយៈវិធីឬសកម្មភាពវាយតម្លៃផ្សេងៗ។

## ៣. ខ្លឹមសារសង្ខេប

កម្មវិធីត្រូវបានផ្តល់ជូនគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀនមួយ ទៅមេរៀនមួយទៀត ។

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃមេរៀនទាំង១០ដែលមាននៅក្នុងម៉ូឌុលបំណិនជីវិតនេះ។

| ចំណងជើងមេរៀន | រយៈពេល | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១. ការយល់ដឹងផ្ទាល់ខ្លួន | ២ម៉ោង | កំណត់និយមន័យនៃពាក្យថា "ការស្វែងយល់ពីខ្លួនឯង" និង"ទំនាក់ទំនងក្នុងសង្គម" និងទំនាក់ទំនងរវាងពាក្យទាំងអស់នេះជាមួយនឹងខ្លួនរបស់សិស្សផ្ទាល់។ | ១ |
| ២. ស្គាល់ខ្ញុំ ស្គាល់អ្នក | ២ម៉ោង | បង្កើនជំនាញក្នុងការវិភាគ អារម្មណ៍របស់យើង នៅពេលដែលយើងចែករំលែករឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួនជាមួយនឹងអ្នកដទៃ។ ពង្រឹងជំនាញក្នុងស្តាប់ ដើម្បីជួយបង្កើនទំនាក់ទំនងឱ្យកាន់តែល្អ។ | ៦ |
| ៣. ខ្ញុំត្រូវការអ្នក អ្នកត្រូវការខ្ញុំ | ២ម៉ោង | បង្កើនការយល់ដឹងអំពីខ្លួនឯង និងផលប្រយោជន៍នៃការសហការគ្នា និងការរួបរួមគ្នា។ | ១២ |
| ៤. រក្សាការសម្ងាត់ | ២ម៉ោង | បង្កើនភាពជឿជាក់ របស់យើង ក្នុងការចូលរួមសកម្មភាពក្នុងថ្នាក់ និងសិក្សាអំពីអត្ថន័យនិងគោលបំណងនៃការរក្សាការសម្ងាត់។ | ១៨ |
| ៥. ពិភពខាងក្នុងរបស់ខ្ញុំ | ២ម៉ោង | បង្កើនការទទួលស្គាល់ពីសារៈសំខាន់នៃការឆ្លុះបញ្ចាំងពីខ្លួនឯង និងអារម្មណ៍ខាងក្នុង ដែលជាដំណើរការនៃការអប់រំដ៏សំខាន់មួយ។ | ២៣ |
| ៦. តើខ្ញុំជានរណា ? | ២ម៉ោង | អនុវត្តដើម្បីបង្កើនការស្វែងយល់អំពីជីវិត បុគ្គលិកលក្ខណៈ គំនិត និងអារម្មណ៍របស់ក្មេងប្រុស/ស្រី នឹងមានអារម្មណ៍ជឿជាក់ នៅពេលដែលគេចែករំលែករឿងរ៉ាវទាក់ទងនឹងជីវិតផ្ទាល់ខ្លួនរបស់គេ។ | ២៩ |
| ៧. ការផ្លាស់ប្តូរអត្តចរិតផ្ទាល់ខ្លួន | ២ម៉ោង | បង្កើនជំនាញ ដើម្បីពិពណ៌នានូវបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន និងចរិតលក្ខណៈដែលយើងចង់អភិវឌ្ឍបន្ថែម។ | ៣៥ |

| | | | |
|---|---|---|---|
| ៨. ការបង្ហាញអារម្មណ៍ | ២ម៉ោង | សិក្សាអំពីអារម្មណ៍អវិជ្ជមានរបស់យើង ដែលជាធម្មតាយើងតែងតែជួបប្រទះនៅក្នុងការរស់នៅ។កំណត់សកម្មភាពវិជ្ជមាន ដែលអាចជួយយើងឱ្យមានការទាក់ទងទៅនឹងអារម្មណ៍ដែលពិបាកៗទាំងឡាយ។ | ៤០ |
| ៩. ការគ្រប់គ្រងអារម្មណ៍ | ២ម៉ោង | បង្កើនជំនាញក្នុង ការរៀបចំអារម្មណ៍ដែលពិបាកៗ បន្ទាប់ពីធ្វើការសិក្សាអំពីអារម្មណ៍ខុសៗគ្នា មួយចំនួនរួចមក។ | ៤៥ |
| ១០. ការរួបរួមទាំងអស់គ្នា! | ២ម៉ោង | បង្ហាញជំនាញ និង ចំណេះដឹងអំពីការយល់ដឹងផ្ទាល់ខ្លួន និងជំនាញទំនាក់ទំនងក្នុងសង្គម។ | ៥១ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរដែលយើងគ្រូវបញ្ចូលនៅផ្នែកខាងចុងម៉ូឌុល ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេតផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ។ ចំពោះការវាយតម្លៃសិស្សនេះយើងគិតពិន្ទុ ៥០ស្មើទៅនឹងមុខវិជ្ជាមួយចំនួនផងដែរគឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្តាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបងសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: ការយល់ដឹងផ្ទាល់ខ្លួន

រយៈពេលបង្រៀន: ២ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

សម្ភារឧបទេស ធនធានដែលត្រូវការ

- ហ្វឺត ឬ ដីស
- ក្តារខៀន
- ខ្មៅដៃ សៀវភៅសរសេរ ក្រដាសស (A4)
- ក្រដាសផ្ទាំងធំ ស្កុតបិទ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ប្រាប់ពីនិយមន័យ "ការយល់ដឹងផ្ទាល់ខ្លួន" និង "ទំនាក់ទំនងសង្គម"
- អនុវត្តលំហាត់ការស្គាល់ខ្លួនឯង។

## ចំណងជើងមេរៀនទី ១: ការយល់ដឹងផ្ទាល់ខ្លួន

### សេចក្តីផ្តើម

២៥ នាទី

គ្រូសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន:

អ្វីគ្រប់យ៉ាងដែលកំពុងដំណើរការក្នុងទំនាក់ទំនងទាំងអស់ក្នុងជីវិតរបស់អ្នក គឺវាឆ្លុះបញ្ចាំង នូវអ្វីដែលកំពុងដំណើរក្នុងខ្លួនរបស់អ្នក។

គ្រូសួរសិស្ស "តើប្រយោគនេះមានន័យយ៉ាងណាចំពោះអ្នក"?

គ្រូទុកពេលឱ្យសិស្ស ៥ នាទី គិតអំពីប្រយោគនេះ។ បន្ទាប់មកឱ្យសិស្សចូលតាមក្រុម ដើម្បីចែករំលែកចម្លើយរបស់ខ្លួនរយៈពេល១០នាទីសម្រាប់ការពិភាក្សា។

គ្រូចែកក្រដាសមួយសន្លឹក សម្រាប់ក្រុមមួយៗ។ សសរសេរគំនិតដែលគេបានពិភាក្សា ដាក់លើក្រដាសដែលគ្រូចែក។ ចូរប្រាកដថា គំនិតរបស់សិស្សទាំងអស់ (ប្រុស/ស្រី) ត្រូវបានសរសេរចូលក្នុងក្រដាស ប៉ុន្តែកុំឱ្យជាន់គ្នា។

នៅពេលដែលសិស្សបញ្ចប់ការសរសេរ គ្រូឱ្យក្រុមនីមួយៗអានចម្លើយរបស់ពួកគេ។

គ្រូសរុប និងបញ្ជាក់បន្ថែមនូវនិយមន័យនៃពាក្យ ការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គមៈ

● ការយល់ដឹងផ្ទាល់ខ្លួន គឺជាការស្វែងយល់អំពីខ្លួនឯង ហើយវាមានសារៈសំខាន់ណាស់សម្រាប់យើងក្នុងការស្គាល់ខ្លួនឯង ព្រោះថាវាជួយឱ្យយើងយល់ពីមូលហេតុនៅពីក្រោយការគិត ការប្រព្រឹត្ត ការសម្តែងចេញ និងទំនាក់ទំនងជាមួយនឹងអ្នកដទៃ។

● ទំនាក់ទំនងសង្គម គឺជាទំនាក់ទំនងរវាងមនុស្សពីរនាក់ ឬច្រើន។ នៅពេលដែលយើងធ្វើអ្វីមួយជាមួយមនុស្សដទៃ ឬមានទំនាក់ទំនងជាមនុស្សដទៃ យើងហៅថាទំនាក់ទំនងសង្គម។ វិធីដែលយើងធ្វើទំនាក់ទំនងជាមួយអ្នកដទគឺអាស្រ័យទៅលើកម្រិតនៃការយល់ដឹងផ្ទាល់ខ្លួនរបស់យើង។ កាលណាយើងយល់អំពីខ្លួនឯងកាន់តែច្បាស់ នោះធ្វើឱ្យទំនាក់ទំនងយើងជាមួយអ្នកដទៃកាន់តែល្អ ហើយទំនាក់ទំនងយើងចាំបាច់ ត្រូវផ្តល់សេចក្តី ទុកចិត្តនិងការគោរពឱ្យគ្នាទៅវិញទៅមក។

យើងនឹងចំណាយពេលសិក្សា ១០មេរៀនទៀត ដើម្បីស្វែងយល់អំពីខ្លួនរបស់យើងឱ្យកាន់តែច្បាស់ ដែលវានឹងជួយឱ្យទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ ប្រកបដោយសុវត្ថិភាព សមភាព/សមធម៌ និងការស្ថាបនា។

◈ គ្រូឱ្យសិស្សកត់ត្រា និយមន័យរបស់ពាក្យ ប្រយោគផ្សេងៗទៀត ហើយបន្ទាប់មកសរសេរទុកក្នុងសៀវភៅរបស់ពួកគេ ។

✎ ការយល់ដឹងផ្ទាល់ខ្លួនគឺជា...
ទំនាក់ទំនងសង្គមគឺជា...

## សកម្មភាពសំខាន់។ ◷ ៦០ នាទី

គ្រូប្រាប់សិស្សថា មុននឹងយើងស្វែងយល់អំពីខ្លួនរបស់យើង និងអ្នកដទៃ យើងត្រូវចាំបាច់ស្វែងយល់ពី អ្វីទៅជាសេចក្តីទុកចិត្តនិងសុវត្ថិភាព និងសារៈសំខាន់ក្នុងការរៀនពីការទុកចិត្តអ្នកដទៃ។ ដូច្នេះមេរៀនថ្ងៃនេះគឺសេចក្តីទុកចិត្តនិងសុវត្ថិភាព។

◈ គ្រូសួរសិស្សទាំងអស់អ្នក តើយល់ដូចម្តេចដែរចំពោះពាក្យថា "សេចក្តីទុកចិត្ត" ឬ "ការទុកចិត្តអ្នកដទៃ"។ ស្តាប់នូវគំនិតមួយចំនួនរបស់សិស្ស និងបញ្ជាក់នូវគំនិតមួយចំនួនដែលសិស្សបានលើកឡើង។

គ្រូឱ្យសិស្សធ្វើការជាដៃគូ ដែលមានភេទដូចគ្នា គឺប្រុសគូជាមួយប្រុស ស្រីគូជាមួយស្រី។

● គ្រូឱ្យគូនីមួយៗរកនឹកពីស្ថានភាពមួយ ធ្វើឱ្យពួកគេមិនសប្បាយចិត្ត ឬព្រួយបារម្ភ ដែលបានកើតឡើងចំពោះពួកគេ ឬគ្រួសាររបស់គេ ហើយពួកគេចង់និយាយប្រាប់នរណាម្នាក់។ តើពួកគេមានអារម្មណ៍បែបណា នៅពេលពួកគេមិនសប្បាយចិត្ត ឬព្រួយបារម្ភ?

● នៅពេលដែលអ្នកមានអារម្មណ៍បែបនេះ តើអ្នកចង់និយាយប្រាប់នរណា? ប្រហែលជាមិត្ត ឬសមាជិកគ្រួសារណាម្នាក់ ឬលោក/អ្នកគ្រូ។ ចូរគិតពីមនុស្សដែលអ្នកចង់និយាយប្រាប់ ដោយឆ្លើយនូវសំណួរខាងក្រោម។

◈ តើហេតុអ្វីបានជាអ្នកចង់ទៅនិយាយជាមួយម្នាក់នោះ? តើពួកគេមានលក្ខណៈសម្បត្តិដូចម្តេច ដែលធ្វើឱ្យអ្នកចូលចិត្ត? តើពួកគេបង្ហាញ ឬធ្វើអាក្បកិរិយាបែបណា នៅពេលដែលអ្នកនិយាយរឿងពិបាកចិត្តជាមួយគាត់?

គ្រូទុកពេលឱ្យសិស្ស ១០នាទី សម្រាប់ការពិភាក្សានេះ។ ដើរពិនិត្យមើលគូនីមួយៗ ដើម្បីឱ្យប្រាកដថាពួកគេកំពុងពិភាក្សា និងកត់ត្រាចម្លើយសំណួរខាងលើ។ នៅពេលសិស្សទាំងអស់ពិភាក្សាចប់ គ្រូប្រាប់ពួកគេថា ពួកគេនឹងចែករំលែកចម្លើយរបស់ពួកគេទៅក្រុមធំ ដើម្បីឱ្យយើងអាចរៀនអំពីគ្នា ទៅវិញទៅមក។

គ្រូឱ្យតំណាងក្រុមសិស្ស ឡើងបង្ហាញចម្លើយ។

✎ គ្រូសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖
ប្រភេទមនុស្សដែលខ្ញុំអាចទុកចិត្តបានគឺ មនុស្សស្មោះត្រង់...

កំណត់សម្គាល់៖ ខណៈពេលដែលសិស្សកំពុងចែករំលែកគំនិតគ្រូកាត់ត្រានូវចម្លើយទាំងនោះនៅលើក្តារខៀន។ គ្រូត្រូវប្រាកដថា សិស្សត្រូវផ្តល់មូលហេតុជុំវិញលក្ខណៈសម្បត្តិ ដែលពួកគេបានជ្រើសរើស មិនចាំបាច់និយាយគំនិត នោះឡើងវិញឡើយ។ គ្រាន់តែកត់គុណសម្បត្តិ និងចរិតលក្ខណៈដែលសិស្សនឹកឃើញ។ គ្រូអាចស្វែងយល់បន្ថែមពីឯកសារជំនួយ ដើម្បីឱ្យប្រាកដថា លក្ខណៈសម្បត្តិនិងអាកប្បកិរិយាទាំងអស់ត្រូវបានដាក់បញ្ចូល ។

តើអ្នកគិតថា ក្នុងចំណោមលក្ខណៈសម្បត្តិទាំងនេះ មួយណាមានសារៈសំខាន់ជាងគេ? ហេតុអ្វី?

គ្រូត្រូវរំឮកសិស្សទាំងអស់ថា គ្មានចម្លើយខុស ឬត្រូវឡើយចំពោះសំណួរនេះ។ លក្ខណៈសម្បត្តិទាំងអស់ គឺមានសារៈសំខាន់ដូចគ្នាប៉ុន្តែវាអាស្រ័យទៅលើខ្លួនរបស់យើងម្នាក់ៗដែលយើងយល់ថាមួយណាមានសារៈសំខាន់ជាង។

យើងទាំងអស់គ្នាអាចប្រើបញ្ជីនេះ ជាសេចក្តីណែនាំមួយដែលប្រាប់ពីលក្ខណៈ និងអាកប្បកិរិយាសំខាន់ៗ ដែលយើងត្រូវការ ដើម្បីក្លាយជាមិត្តភក្តិល្អម្នាក់ ជាមនុស្សជាទីទុកចិត្តរបស់អ្នកដទៃ ហើយនឹងជួយគាំទ្រដល់អ្នកដែលមានអារម្មណ៍មិនសប្បាយចិត្ត ឬព្រួយបារម្ភ។

បន្ថែមប្រយោគខាងក្រោមទៅខាងក្រោមតារាងនៅទំព័រទី ៥៖

"ប្រសិនបើខ្ញុំមានអាកប្បកិរិយាបែបនេះ ខ្ញុំនឹងក្លាយជាមនុស្សជាទីទុកចិត្តរបស់អ្នកដទៃ!"

គ្រូឱ្យសិស្សកត់ត្រាបញ្ជី "លក្ខណៈ និងអាកប្បកិរិយា" នៅលើក្តារខៀនចូលក្នុងសៀវភៅ។

គ្រូប្រាប់សិស្សទាំងអស់ ប្រសិនបើអ្នកបានបញ្ចប់ការកត់ត្រា ចូរអ្នកសួរខ្លួនឯងនូវសំណួរខាងក្រោមនេះ៖

តើខ្ញុំមានលក្ខណៈគ្រប់គ្រាន់ ដែលជួយឱ្យអ្នកនៅជុំវិញខ្លួនទុកចិត្តខ្ញុំហើយឬនៅ?

គ្រូឱ្យសិស្សគិតមួយនាទី ហើយប្រាប់ពួកគេថាពួកគេមិនចាំបាច់ចែករំលែកចម្លើយទៅមិត្តរួមថ្នាក់ទេ ប៉ុន្តែវានឹងប្រើប្រាស់សម្រាប់សកម្មភាពចុងក្រោយ។

**បញ្ចប់មេរៀន៖** ១៥ នាទី

គ្រូពន្យល់ថា ក្នុងរយៈពេល ១០សប្តាហ៍ទៅមុខទៀត ក្នុងមេរៀនរបស់យើង យើងនឹងបង្កើតភាពសប្បាយរីករាយជាមួយគ្នា ធ្វើការជាមួយគ្នា ហើយយើងនឹងពិភាក្សាគ្នានូវគំនិត ការយល់ឃើញ និងបទពិសោធន៍របស់យើងទាំងចំណុចល្អនិងមិនល្អជាពិសេសចង់ឱ្យពួកយើងទាំងអស់គ្នាមានអារម្មណ៍សុវត្ថិភាពក្នុងការនិយាយរឿងរ៉ាវអស់ទាំងនេះ។

គ្រូសួរសិស្សទាំងអស់នូវសំណួរខាងក្រោមនេះ៖

- តើមានចំណុចល្អអ្វីខ្លះនៅពេលដែលយើងបាននិយាយរឿងរ៉ាវផ្ទាល់ខ្លួន ចែករំលែកគំនិតនិងបទពិសោធន៍ផ្ទាល់ខ្លួនប្រាប់អ្នកដទៃ?
- តើការដែលប្រាប់រឿងរ៉ាវផ្ទាល់ខ្លួនទៅអ្នកដទៃ អាចមានបញ្ហាអ្វីខ្លះ?
- តើយើងអាចធ្វើការជាមួយគ្នាបានយ៉ាងដូចម្តេច ដើម្បីកាត់បន្ថយបញ្ហាទាំងនេះ?
- គ្រូឱ្យសិស្សចម្លងចម្លើយទាំងនេះ។
- គ្រូរំឮកសិស្សពីសំណួរមុន៖ តើខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជួយឱ្យអ្នកនៅជុំវិញខ្លួនទុកចិត្តខ្ញុំហើយឬនៅ?

សេចក្តីទុកចិត្តមានសារៈសំខាន់ណាស់ ប្រសិនបើយើងអាចចែករំលែកគំនិត យោបល់ និបទពិសោធន៍របស់យើងដោយសុវត្ថិភាព នោះវាបង្កលក្ខណៈឱ្យយើងមានឱកាសស្វែងយល់អំពីខ្លួនឯង ហើយជួយឱ្យមានទំនាក់ទំនងរបស់យើងកាន់តែល្អជាមួយអ្នកដទៃ។

ក្រោយពីបញ្ចប់មេរៀន គ្រូឱ្យសិស្សទាំងអស់គិត តើចំណុចសំខាន់អ្វីខ្លះដែលពួកគេបានរៀនពីមេរៀនថ្ងៃនេះ។ ពួកគេអាចសរសេរចំណុចទាំងនោះដាក់ក្នុងសៀវភៅ ពេលដែលពួកគេត្រឡប់ទៅផ្ទះ។

*អរគុណអ្នកទាំងអស់គ្នា យើងខ្ញុំទន្ទឹងរង់ចាំជួបអ្នកនៅមេរៀនក្រោយទៀត។*

## ខ្លឹមសារៈសំខាន់

- ការមានសេចក្តីទុកចិត្តមានន័យថា៖ អ្នកអាចពឹងពាក់គេឱ្យជួយអ្នកបាន ហើយគេមិនកេងចំណេញពីអ្នក ឬមិនប្រើប្រាស់អ្នកក្នុងផ្លូវមិនល្អ និងមិននិយាយអាក្រក់ពីអ្នក។

- ទាំងគ្រូ ទាំងសិស្ស គួរទុកចិត្តគ្នាទៅវិញទៅមក ដើម្បីជួយសិស្សឱ្យមានអារម្មណ៍សុវត្ថិភាពគ្រប់គ្រាន់ហើយក្លាហានក្នុងការចែករំលែកបទពិសោធន៍ គំនិត និងអារម្មណ៍ ក៏ដូចជាក្លាហានក្នុងការរៀន។

- លោក/អ្នកគ្រូ គឺជាគំរូដ៏សំខាន់ដល់សិស្ស ដូច្នេះហើយលោក/អ្នកគ្រូគឺជាអ្នកអនុវត្តគំរូក្នុងការផ្តល់ការទុកចិត្តចំពោះសិស្ស ដែលបង្កបរិយាកាសមួយប្រកបដោយការគោរពគ្នាទៅវិញទៅមក និងជំរុញឱ្យមានសេចក្តីទុកចិត្ត និងសុវត្ថិភាពចំពោះគ្នាទៅវិញទៅមក។

- អ្វីដែលល្អចំពោះការដែលយើងមានឱកាសក្នុងការចែករំលែកបទពិសោធន៍របស់យើង គឺវាជួយឱ្យយើងយល់ពីជីវិតផ្ទាល់ខ្លួន និងអារម្មណ៍របស់យើង ។ វាក៏ជួយឱ្យយើងចេះចែករំលែកគំនិត និងយោបល់របស់យើង។ នៅពេលដែលយើងស្ថិតក្នុងបរិយាកាសសុវត្ថិភាព នោះវាជួយឱ្យយើងអាចរៀនពីគ្នាទៅវិញទៅមកកាន់តែច្រើន។

- បញ្ហាដែលអាចកើតមានពេលចែករំលែករឿងរ៉ាវផ្ទាល់ខ្លួន អាចមានភាពអវិជ្ជមាន។ ដូចជា គេអាចមិនចិត្តទុកដាក់ស្តាប់យើង ឬធ្វើឱ្យយើងមានអារម្មណ៍មិនមានសុវត្ថិភាព អាម៉ាសមុខ អាចវិនិច្ឆ័យនូវអ្វីដែលយើងនិយាយ និងមិនរក្សាការសម្ងាត់ឱ្យយើង។

- យើងអាចជៀសវាងបញ្ហាដែលអាចកើតមាន ដោយអនុវត្តតាមសេចក្តីណែនាំដែលយើងបានបង្កើតឡើងពីលក្ខណៈសម្បត្តិ និងអាកប្បកិរិយាមនុស្សដែលអាចទុកចិត្តបាន ក្នុងការចែករំលែករឿងសប្បាយចិត្ត និងមិនសប្បាយចិត្ត ដែលសិស្សទាំងអស់បានបង្កើតក្នុងមេរៀន ដូចជា៖
    - យកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក
    - មិនយករឿងផ្ទាល់ខ្លួនរបស់គ្នាទៅប្រាប់អ្នកដទៃ។

- ប្រសិនបើយើងយល់ថា វាមានប្រយោជន៍ក្នុងការប្រើឈ្មោះអ្នកដទៃនៅពេលដែលយើងនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់យើង វាគ្មានបញ្ហាទេក្នុងការធ្វើរបៀបនេះ។

- អាទិភាពចម្បងក្នុងការចែករំលែកពីគំនិត រឿងរ៉ាវផ្ទាល់ខ្លួន គឺត្រូវប្រាកដថាទាំងយើង ទាំងអ្នកដទៃមានអារម្មណ៍សុវត្ថិភាព និងមិនមានការព្រួយបារម្ភកំឡុងពេលចែករំលែកនោះ។



តារាងធនធាន - ការទុកចិត្ត និងសុវត្ថិភាព

តើមនុស្សប្រភេទណាដែលខ្ញុំអាចទុកចិត្ត និងធ្វើឱ្យខ្ញុំមានអារម្មណ៍សុវត្ថិភាព?



មនុស្សនោះគឺ...

រាក់ទាក់ ចេះបារម្ភ និង ចិត្តល្អ

នរណាម្នាក់ដែលស្តាប់ និងមិននិយាយបញ្ឈឺខ្ញុំ។

នរណាម្នាក់ដែលមិនវិនិច្ឆ័យខ្ញុំ និងថែទាំខ្ញុំដោយស្មើភាព



មានទំនួលខុសត្រូវ និងអាចទុកចិត្តបាន

មានការលើកទឹកចិត្ត។

នរណាម្នាក់ដែលចាត់ទុកខ្លួនរបស់ពួកគេ ថាជាខ្ញុំដើម្បីយល់ពីខ្ញុំ

នរណាម្នាក់ដែលមិនស្តីបន្ទោសខ្ញុំ។

នរណាម្នាក់ដែលមិននិយាយដើមខ្ញុំ និងសើចចម្អកនៅពីក្រោយខ្នងខ្ញុំ។

នរណាម្នាក់ដែលស្មោះត្រង់ និងរក្សាសន្យារបស់ពួកគេ។

នរណាម្នាក់ដែលមិនសន្យានូវអ្វីដែលពួកគេមិនអាចធ្វើបាន។

នរណាម្នាក់ដែលមិនកេងចំណេញពីរូបខ្ញុំ។

នរណាម្នាក់ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍គ្មានគ្រោះថ្នាក់ និងមានសុវត្ថិភាព។

ប្រសិនបើខ្ញុំប្រព្រឹត្តដូចនេះ អ្នកដទៃនឹងអាចទុកចិត្តខ្ញុំបាន!



# មេរៀនទី ២: ស្គាល់ខ្ញុំ ស្គាល់អ្នក

រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។



សម្ភារឧបទេស ធនធានដែលត្រូវការ

- ហ្វឹត ឬក៏ដីស
- ក្តារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត
- ប័ណ្ណសារ ដែលជាឯកសារសម្រាប់សិស្ស និងប្រអប់/ធុងមួយសម្រាប់ដាក់ឯកសារទាំងនោះ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់អាច :

- ពណ៌នាអំពីអារម្មណ៍ក្នុងការចែករំលែកនូវរឿងរ៉ាវផ្ទាល់ខ្លួន និងបទពិសោធន៍ទាំងឡាយជាមួយនឹងអ្នកដទៃ។
- វាយតម្លៃពីផលប្រយោជន៍នៃទំនាក់ទំនង និងបំណិនស្តាប់ ដើម្បីពង្រឹងទំនាក់ទំនងក្នុងសង្គម

## រំឭកមេរៀនចាស់

២៥ នាទី

គ្រូសួរ "តើអ្នកអាចចែករំលែកនូវខ្លឹមសារៈសំខាន់ៗ ដែលអ្នកបានរៀនកាលពីមេរៀនមុនបានទេ?"

សួរទៅថ្នាក់ទាំងមូល និងជ្រើសរើសសិស្សប្រុសស្រី ពីរបីនាក់ ឡើងចែករំលែកនូវគំនិតរបស់ពួកគេជាមួយនឹងមិត្តរួមថ្នាក់ ។ ឱ្យសិស្សទាំងអស់សរសេរនូវគំនិតរបស់ពួកគេនៅលើក្តារខៀន ដោយប្រើប្រាស់ពាក្យខ្លីៗ។

## ចំណងជើងមេរៀនទី ២: ស្គាល់ខ្ញុំ ស្គាល់អ្នក

### សេចក្តីផ្តើម

ប្រាប់សិស្សកាលពីមេរៀនមុន យើងក៏បានរៀនពិភាក្សាគ្នាអំពីជីវិតរបស់យើង បុគ្គលិកលក្ខណៈ និងចរិតលក្ខណៈរបស់យើង ទាំងអស់គ្នា ហើយក៏បានធ្វើការកំណត់នូវអ្វី ដែលយើងចង់ផ្លាស់ប្តូរអំពីខ្លួនរបស់យើង ដូច្នេះវាធ្វើឱ្យទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃ កាន់តែមានភាពល្អប្រសើរឡើង។ យើងក៏បានសិក្សាផងដែរថាយើងទាំង ពួអស់គ្នា ចាំបាច់ត្រូវស្វែងរកចំណុចឬលក្ខណៈ ដែលយើងចូលចិត្តអំពីខ្លួនរបស់យើង ក៏ដូចជាចំណុចឬលក្ខណៈដែលយើងចង់ ធ្វើការផ្លាស់ប្តូរ។ វាពិតជាសំខាន់ណាស់ ក្នុងការកំណត់នូវរបស់អ្វីមួយដែលយើងពេញចិត្ត ក៏ដូចជារបស់អ្វីមួយដែលយើងអាចធ្វើ ឱ្យកាន់តែល្អប្រសើរអំពីខ្លួនរបស់យើង។

ថ្ងៃនេះយើងទាំងអស់គ្នា នឹងបន្តការស្វែងយល់ពីខ្លួនឯងទៅមុខទៀត ដោយយើងគិតអំពីសារៈសំខាន់នៃបំណិនស្តាប់ ដើម្បីបង្កើនរបៀបដែលយើងអាចធ្វើការផ្លាស់ប្តូរខ្លួនរបស់យើង។ យើងកាន់តែអាចស្តាប់អ្នក ដទៃបានល្អប្រសើរគឺយើងក៏កាន់តែអាចធ្វើការសិក្សាពីខ្លួនរបស់យើងបានផងដែរ ដោយសារតែការស្តាប់ដោយមានប្រសិទ្ធភាពគឺបង្រៀនយើងក្នុងការទាក់ទង អ្វីដែលយើងពុចំពោះរបៀប ដែលយើងបញ្ចេញចរិតលក្ខណៈរបស់យើង។ វាក៏អាចជួយយើងផងដែរដើម្បីបង្កើនពីរបៀប ដែលយើងទាក់ទងជាមួយនឹងអ្នកដទៃ។ ក៏ប៉ុន្តែដូចអ្វីដែលយើងបានរៀននៅក្នុងមេរៀនមុនប្រសិន បើយើងចង់បង្កើន គឺទាល់តែយើងទាំងអស់គ្នាចាំបាច់ត្រូវចែករំលែក ហើយដើម្បីចែករំលែកបានយើងក៏ចាំបាច់ត្រូវ...(ឱ្យសិស្សបញ្ចប់ល្បះ ប្រសិនបើពួកគេអាច)... ជឿជាក់ទៅលើគ្នាទៅវិញទៅមក។

● គ្រូបែងចែកសិស្សជាពីរក្រុម ហើយឱ្យពួកគេឈរជារង្វង់ធំមួយ- ធ្វើសកម្មភាពនេះនៅខាងក្រៅ ប្រសិនបើអ្នកត្រូវការកន្លែងទូលាយបន្ថែម។ បន្ទាប់មកជ្រើសរើសសិស្សម្នាក់ ហើយស្នើឱ្យគេបិទភ្នែក ឬក៏ប្រើក្រមាដើម្បីបិទភ្នែករបស់ពួកគេ។

● គ្រូប្រាប់សិស្សថា អ្នកនឹងដើរជុំវិញរង្វង់នេះ។ ហើយប្រសិនបើ អ្នកដើរទៅដល់នរណាម្នាក់ បុគ្គលនោះនឹងចាប់បង្វិលអ្នកថ្នមៗត្រឡប់ទៅចំកណ្តាលរង្វង់វិញ។ ចូរធ្វើដូច្នេះរយៈពេលមួយសន្ទុះជាមួយនឹងសិស្សដដែលហើយ បន្ទាប់មកបញ្ឈប់សកម្មភាពនេះសិន។ ប្រាប់សិស្សឱ្យបើកភ្នែករបស់គេដោយដោះក្រមាចេញ។

● គ្រូសួរ តើអ្នកមានអារម្មណ៍ដូចម្តេចដែរ? តើអ្នកមានអារម្មណ៍ថា អ្នកអាចជឿជាក់មិត្តរបស់អ្នកបានទាំងស្រុងដែរឬទេ? តើអ្វីទៅ ដែលអាចជួយអ្នកឱ្យជឿជាក់មកលើពួកគេ? ធ្វើការរៀបចំនូវការពិភាក្សាមួយជុំវិញចម្លើយចំពោះសំណួរទាំងនេះដោយប្រើប្រាស់កំណត់ត្រារបស់គ្រូ ដើម្បីជាការណែនាំចំពោះអ្នក។ បន្ទាប់មកសិស្សដទៃ ទៀតអាចត្រឡប់ចូលថ្នាក់វិញ ប្រសិនបើពួកគេចង់ និងមានពេលគ្រប់គ្រាន់។

ដូច្នេះ តើយើងអាចជឿជាក់គ្នាទៅវិញទៅមកបានដែរឬទេ?(សង្ឃឹមថាសិស្សនឹងឆ្លើយថា បាទ/ចាស) តើអ្នកទាំងអស់គ្នាមានសំណួរអ្វី ចំពោះមេរៀននៅថ្ងៃនេះទេ?

## សកម្មភាពសំខាន់។ 🕑 ៦០ នាទី

●គ្រូសួរៈ តើអ្នកទាំងអស់គ្នាមានបានចាំការធ្វើជារូបតំណាង ដែលយើងបានធ្វើកាលពីមេរៀនមុនឬទេ? តើអ្នកមានបានរៀននូវអ្វីៗដែលថ្មីពីមិត្តរបស់អ្នកដែរឬទេ នៅពេលដែលអ្នកបានអនុវត្តសកម្មភាពនោះ? ឥឡូវនេះប្រសិនបើយើង ក្រឡេកមើលជុំវិញមិត្តភក្តិរបស់យើង តើអ្នកគិតថាយើងអាចនិយាយបានថា យើងអាចដឹងអ្វីៗអំពីគ្នាទៅវិញទៅមកបានដែរឬទេ ទាំងក្មេងស្រី និងក្មេងប្រុស?

● គ្រូប្រាប់សិស្សៈ មានរបស់ជាច្រើន ដែលយើងមិនអាចដឹង ដោយគ្រាន់តែធ្វើការក្រឡេកមើលទៅកាន់នរណាម្នាក់។ ដូច្នេះប្រសិនបើយើងចង់ឱ្យ មនុស្សទាំងអស់ដឹងអំពីខ្លួនយើង យើងចាំបាច់ត្រូវតែចែករំលែកនូវគំនិត អារម្មណ៍ និងបទពិសោធន៍របស់យើង។

● គ្រូៈ ចែកសិស្សជាក្រុម ដែលមានគ្នា៦នាក់ ឱ្យពួកគេអង្គុយនៅក្នុងរង្វង់ ដាក់ប័ណ្ណទាំងអស់នៅលើតុចំកណ្តាលសិស្ស។

យកសៀវភៅរបស់អ្នកទាំងអស់គ្នាចេញ ព្រមទាំងខ្មៅដៃ។ អ្នកទាំងអស់គ្នាម្នាក់ៗ នឹងយកបណ្ណ មួយចេញពីតុនេះ ហើយត្រូវនាំគ្នាបំពេញជាល្បះនៅបណ្ណទាំងនោះ។ ឱ្យឧទាហរណ៍ គំរូមួយ ដោយយកបណ្ណមួយ ហើយបំពេញល្បះ។ (ឧទាហរណ៍៖ "របស់ដែលជាចំណង់ចំណូលចិត្តរបស់ខ្ញុំ គឺជាសំពត់ចាស់មួយ ដែលជាកាដូរមួយដែលកូនស្រីជូនមកខ្ញុំហើយខ្ញុំបានរក្សាទុកវាអស់រយៈពេល១០ឆ្នាំមកហើយ"។) នៅពេលដែលអ្នកទាំងអស់គ្នាបានបញ្ចប់ការបំពេញល្បះទាំងអស់ចូលក្នុងសៀវភៅរបស់ខ្លួនរួចអ្នកទាំងអស់គ្នានឹងត្រូវធ្វើការចែករំលែកល្បះ របស់អ្នកជាមួយនឹងអ្នកដទៃ។

អ្នកក៏អាចសួរគ្នាទៅវិញទៅមក បានផងដែរអំពីល្បះទាំងនោះ។ នៅពេលដែលនរណាម្នាក់ ចែករំលែកចប់ អ្នកនៅក្នុងក្រុមដទៃទៀត អាចធ្វើការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន នូវរឿងដូចគ្នានេះផងដែរ។ ឧទាហរណ៍ៈ ប្រសិនបើពួកគេនិយាយអំពីចំណង់ចំណូលចិត្តរបស់ពួកគេរួច បន្ទាប់មកអ្នកអាចចែករំលែកទាំងអស់នូវអ្វី ដែលជារបស់ចំណង់ចំណូលចិត្តរបស់អ្នក។ នៅពេលដែលការចែករំលែកទាំងអស់ត្រូវបានបញ្ចប់ ចូរចាប់ផ្តើមអនុវត្តសកម្មភាពនោះម្តងទៀត ហើយ យកបណ្ណថ្មីមួយផ្សេងទៀត។

- គ្រូពិនិត្យមើលការយល់ដឹងៈ

តើប័ណ្ណចំនួនប៉ុន្មាន ដែលអ្នកបានយកក្នុងម្នាក់? (មួយ)

តើនឹងត្រូវធ្វើអ្វីខ្លះជាមួយនឹងបណ្ណនោះ? (បំពេញល្បះចូលក្នុងសៀវភៅរបស់អ្នក)

តើបន្ទាប់មកទៀត អ្នកនឹងធ្វើអ្វី? (បុគ្គលម្នាក់នឹងធ្វើការចែករំលែកនូវអ្វី ដែលពួកគេបានសរសេរ) ហើយបន្ទាប់មកទៀត? (សិស្សផ្សេងទៀតអាចសួរសំណួរបាន) ហើយបន្ទាប់មកទៀត? (សិស្សដទៃទៀតអាចចែករំលែកនូវបទពិសោធន៍របស់ពួកគេ ដោយប្រើប្រាស់ល្បះដដែល)ហើយបន្ទាប់មកទៀត? (សិស្សបន្ទាប់ត្រូវអាននូវល្បះរបស់ពួកគេ ហើយដំណើរការសកម្មភាព នេះក៏ចាប់ផ្តើមជម្តងទៀត។)

- គ្រូសួរៈ តើជំនាញអ្វីដែលសំខាន់នៅក្នុងសកម្មភាពនេះ? (ជំនាញស្តាប់)

ឱ្យសិស្សចាប់ផ្តើមអនុវត្តសកម្មភាព ហើយអ្នកអាចដើរជុំវិញដើម្បីត្រួតពិនិត្យមើលថាតើ ពួកគេទាំងអស់គ្នាយល់ និងចូលរួមទាំងអស់គ្នា ដោយអ្នកចូលអង្គុយជាមួយនឹងក្រុមខុសៗគ្នា និងស្តាប់ពួកគេ។ តួនាទីរបស់អ្នក គឺគ្រាន់តែស្តាប់ ហើយមិនចាំបាច់ធ្វើការផ្តល់ជាការពន្យល់អ្វីនោះទេ។

- គ្រូសន្និដ្ឋានសកម្មភាព នៅពេលណាដែលអ្នកគិតថា សិស្សទាំងអស់គ្នាបានចែករំលែកនូវ រឿងរ៉ាវរបស់ពួកគេបានគ្រប់គ្រាន់។

- គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ហើយឱ្យសិស្សចម្លងចូលក្នុងសៀវភៅសរសេរៈ

ក) តើអ្នកមានអារម្មណ៍ដូចម្តេច ចំពោះការនិយាយពីរឿងផ្ទាល់ខ្លួនប្រាប់មិត្តរួមថ្នាក់?

ខ) តើអ្នកមានអារម្មណ៍ដូចម្តេច ចំពោះការស្តាប់អ្នកដទៃធ្វើការចែករំលែកនូវរឿងផ្ទាល់ខ្លួនរបស់គេ?

គ) តើការការចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនប្រាប់គេផ្តល់នូវប្រយោជន៍អ្វីខ្លះ?

ឃ) តើការស្តាប់គេចែករំលែករឿងរ៉ាវរបស់គេ ប្រាប់យើងផ្តល់នូវប្រយោជន៍អ្វីខ្លះ?

- គ្រូឱ្យសិស្សឆ្លើយសំណួរទាំងអស់នោះនៅក្នុងសៀវភៅរបស់ពួកគេ ។ ប្រសិនបើសិស្សមួយចំនួនបានបញ្ចប់ មុនសិស្សដទៃ អ្នកអាចស្នើពួកគេឱ្យចែករំលែកនូវគំនិតរបស់ពួកគេ ប្រសិនបើពួកគេចង់។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

- គ្រូឱ្យសិស្សឈរនៅក្នុងរង្វង់មួយ ហើយក្រលេកមើលគ្នាជុំវិញបន្ទប់។ ខ្ញុំគិតថាយើងទាំងអស់គ្នាគួរតែដឹងបន្ថែមទៀតអំពីគ្នាទៅវិញទៅមក។ តើអ្នកទាំងអស់គ្នាយល់ស្របទេ? នាំគ្នាទៅស្វែងរកមើល។
- គ្រូឱ្យសិស្សប្តូរទីតាំងដោយសេរីនៅជុំបន្ទប់។ នៅពេលដែលអ្នកទះដៃរបស់អ្នក សិស្សទាំងអស់ត្រូវនាំគ្នារត់មកខាងមុខនរណាម្នាក់ ដែលពួកគេចងចាំនូវអ្វីមួយកាលពីពេលព្រឹក មិញ។ ពួកគេធ្វើការតភ្ជាប់ដៃគ្នាហើយបង្កើតជារង្វង់ មួយ។ វាមិនមានបញ្ហាអ្វីនោះទេ ថាតើត្រូវមានសិស្សចំនួនប៉ុន្មាន នៅក្នុងក្រុមនីមួយៗ ឬក៏ក្រុមចំនួនប៉ុន្មាន ដែលត្រូវធ្វើការបង្កើតនោះទេ។ អ្នកប្រហែលជាបញ្ចប់ទៅជាមួយនឹងសិស្សដែលនៅក្នុងក្រុមដដែលដែលបានមកពីការអនុវត្តសកម្មភាពមុន។ នេះមិនមានបញ្ហាអ្វីនោះទេ គឺគ្រាន់តែពិនិត្យមើលថាតើមានអ្វីកើតឡើង។

● គ្រូសួរៈ តើអ្នកទាំងអស់គ្នាមានការយល់ទាស់ទេ ប្រសិនបើនរណាម្នាក់ក្នុងក្រុមរបស់អ្នក ចែករំលែកជាមួយនឹងមិត្តរួមថ្នាក់ទាំងអស់ នូវរឿងផ្ទាល់ខ្លួនមួយក្នុងចំណោមរឿងទាំងអស់ ដែលអ្នកបានចែករំលែកជាមួយនឹងក្រុមរបស់អ្នកកាលពីព្រឹកមិញនេះ?

ប្រសិនបើមានសិស្សម្នាក់នៅក្នុងក្រុមមួយនិយាយថា នាងមិនថាអ្វីនោះទេ ប្រសិនបើរឿងរបស់នាងត្រូវបាន ចែករំលែកហើយបន្ទាប់មកឱ្យសិស្សដែលមកពីក្រុមរបស់នាង ចែករំលែកនូវរឿងរបស់នាង។ ឧទាហរណ៍ៈ ប្រសិនបើស៊ីដេត និយាយថា នាងមិនថា អ្វីនោះទេ ប្រសិនបើរឿងរបស់នាងត្រូវបានចែករំលែក ចូរប្រាប់សិស្សដទៃថា នាង/គាត់ត្រូវតែចាប់ផ្ដើមនូវកំណែថ្មីនៃរឿងរបស់ ស៊ី ដេត ដោយប្រើប្រាស់ពាក្យមួយចំនួនដូចខាងក្រោមៈ
ខ្ញុំចងចាំថា ស៊ី ដេតបានប្រាប់ពួកយើងថា...

ចូរប្រាប់សិស្សឱ្យព្យាយាមចងចាំឱ្យបានច្រើនតាមដែលអាចធ្វើទៅបានអំពីរឿងទាំងនោះ។ (ឧទាហរណ៍ៈខ្ញុំ ចងចាំថាស៊ីដេតបានប្រាប់ពួកយើងថាកន្លែងដែលនាងចូលចិត្តគឺសួនបន្លែរបស់នាងដោយសារតែនាងបានដាំបន្លែជាច្រើន ដោយខ្លួននាងផ្ទាល់ ហេតុដូច្នេះហើយ ទើបនាងបានចំណាយពេលជាច្រើននៅទីនោះ ដើម្បីមើលថែរក្សាដំណាំទាំង នោះ។ ម្ដាយរបស់នាងក៏បានចំណាយពេលជាច្រើននៅក្នុងសួនបន្លែនោះផងដែរ ដូច្នេះវាបានផ្ដល់ជា ពេលវេលាមួយឱ្យពួកគេបាននៅជាមួយគ្នា ដើម្បីនិយាយគ្នា និងពិភាក្សាគ្នាអំពីអ្វីៗមួយចំនួនទៀតផងដែរ។ ចំពោះឪពុករបស់នាងបានស្លាប់អស់រយៈពេលពីរបីឆ្នាំទៅហើយ ដូច្នេះធ្វើឱ្យនាងមានអារម្មណ៍ថា នាងជាមនុស្សតែម្នាក់ គត់ដែលម្ដាយរបស់នាង អាចនិយាយជាមួយអំពីកិច្ចការគ្រួសារមួយចំនួន។)នៅពេលដែលសិស្សទាំងអស់គ្នាបានបញ្ចប់ អ្នកក៏អាចសួរ ស៊ី ដេត ប្រសិនបើមានអ្វីផ្សេងទៀត។

បន្តធ្វើបែបនេះទៀត ដោយឱ្យសិស្សទាំងអស់គ្នា ចែករំលែករឿងរបស់សិស្សដទៃទៀត ប្រសិនបើសិស្សនោះអនុញ្ញាតឱ្យធ្វើដូច្នោះ។

● គ្រូឱ្យសិស្សត្រឡប់ចូលមកក្នុងរង្វង់វិញ ហើយក្រឡេកមើលជុំវិញម្ដងទៀត ទៅកាន់មិត្តភក្ដិរបស់អ្នក ។ ខ្ញុំនឹងសួរអ្នកនូវសំណួរមួយចំនួនហើយមិនត្រូវឆ្លើយវាឮៗចេញមកក្រៅនោះទេ-ដោយគ្រាន់តែគិតអំពីពួកគេនៅក្នុងខ្លួនរបស់អ្នកទៅបានហើយ។

បន្ទាប់ពីបានស្ដាប់ និងចែករំលែកនូវរឿងមួយចំនួនរបស់យើង តើមានអ្វីថ្មីទេដែលអ្នកគិតថាធ្វើឱ្យអ្នកមានការភ្ញាក់ផ្អើលអំពីមិត្តភក្ដិរបស់អ្នក ដែលជារឿងមួយដែលអ្នកមិនបានរំពឹងទុក?

តើអ្នកទាំងអស់គ្នាអាចគិតពាក្យវិជ្ជមានណាមួយបានទេដែលពិពណ៌នាអំពីនរណាម្នាក់នៅក្នុងថ្នាក់រៀនដោយផ្អែកទៅលើព័ត៌មានថ្មី ដែលអ្នកបានទទួល? ឧទាហរណ៍ ៖ បន្ទាប់ពីបានឮនូវរឿងរបស់ ស៊ី ដេត ពាក្យមួយដែលខ្ញុំគិតថាអាចពិពណ៌នាពីខ្លួនរបស់នាងបាន គឺ "ភាពទទួលខុសត្រូវ"។ នៅពេលដែលអ្នកបានពាក្យរបស់អ្នកហើយ ចូរដើរជុំវិញថ្នាក់ ហើយ និយាយពាក្យនោះទៅកាន់អ្នកដទៃទៀត វាមិនចាំបាច់ឱ្យអ្នកត្រូវក្លាយទៅជាបុគ្គលម្នាក់ដែលអ្នកកំពុងតែគិតអំពីនោះទេ គឺគ្រាន់តែនិយាយវាទៅកាន់អ្នករាល់គ្នាដែលអ្នក បានជួបទៅបាន ហើយ។

● គ្រូឱ្យសិស្សទាំងអស់គ្នាចាប់ផ្ដើមអនុវត្ត ហើយបន្ទាប់ពីរយៈពេលពីរបីនាទីបញ្ឈប់ពួកគេហើយធ្វើការទះដៃដើម្បីបញ្ចប់មេរៀន។

*អរគុណអ្នកទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកទាំងអស់គ្នានៅក្នុងពេលឆាប់ៗនេះ នៅក្នុងមេរៀនលើកក្រោយ។*

# ខ្លឹមសារសំខាន់

● គោលបំណងនៃសកម្មភាពទីមួយ គឺដើម្បីបង្កើនការជឿជាក់ របស់សិស្សទាំងប្រុសទាំងស្រី រវាងគ្នាទៅវិញទៅមក។ ដូច្នេះនៅពេលដែលពួកគចែករំលែក នូវរឿងផ្ទាល់ខ្លួនរបស់ពួកគេ គឺពួកគេមិនចាំបាច់ព្រួយបារម្ភណ៍ថាអ្នកដទៃនឹងប្រើប្រាស់ព័ត៌មានទាំងនោះ ដើម្បីយកទៅនិយាយលេងឬក៏បញ្ឈឺពួកគេនៅក្នុងមធ្យោបាយណានោះទេ។ ចំពោះការពិភាក្សាជុំវិញការជឿជាក់គ្នា អាចរួមបញ្ចូលចំណុចមួយចំនួនដូចជា គិតថាតើយើងមានអារម្មណ៍យ៉ាងណា ឬតើយើងនឹងធ្វើយ៉ាងដូចម្ដេច ប្រសិនបើយើងមិនអាចជឿជាក់ទៅលើនរណាបាន។ ឧទាហរណ៍ ៖ ការនៅក្នុងរង្វង់តែឯង អាចធ្វើឱ្យយើងមានការភ័យ ឬក៏អសមត្ថភាព។ ដូច្នេះ យើងចាំបាច់ត្រូវតែ ជឿជាក់ទៅលើអ្នកដទៃ ដើម្បីឱ្យជួយយើងអាចផ្លាស់ប្ដូរនៅជុំវិញ និងមានអារម្មណ៍ថាមានសុវត្ថិភាព។ ដូចនេះ មធ្យោបាយតែមួយគត់ដើម្បីបង្កើនទំនាក់ទំនងដ៏ល្អគឺ ការមានភាពជឿជាក់រវាងគ្នាទៅវិញទៅមក។

● នៅអំឡុងពេលសិក្សាមេរៀននេះ វាគឺពិតជាសំខាន់ណាស់ក្នុងការបញ្ជាក់សារៈសំខាន់របស់ក្រុមទាំងមូល ក៏ដូចជាអ្នកចូលរួមទាំងអស់នៅក្នុងការធ្វើដំណើរស្វែងយល់អំពីខ្លួនរបស់គេ។

● ចំណុចសំខាន់ក្នុងមេរៀននេះ ឱ្យយើងទាំងអស់គ្នាអាចបង្កើតចំណងទាក់ទងមួយ ប្រកបដោយការគោរព និងផ្ដល់សុវត្ថិភាពចំពោះគ្នាចាំបាច់យើងត្រូវស្ដាប់អ្នកដទៃនិយាយ ហើយយើងក៏ត្រូវចែករំលែកត្រឡប់ទៅវិញពីអារម្មណ៍ការគិត និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងជាមួយនឹងអ្នកដទៃដែរ ហើយការធ្វើសេចក្ដីសន្និដ្ឋានរបស់យើងត្រូវផ្អែកលើចំណុចទាំងអស់របស់អ្នកទាំងនោះ។ការដែលយើងសិក្សាពីអ្នកដទៃនិងការដែលយើងអនុញ្ញាតឱ្យអ្នកដទៃ សិក្សាពីយើង នោះគឺជាការបង្កើតទំនាក់ទំនងមួយដែលប្រកបដោយភាពរឹងមាំ និងល្អ ដោយសារតែទំនាក់ទំនងនេះកើតឡើងដោយ ភាពស្មោះត្រង់ និងការជឿជាក់គ្នា។

● ជួនកាលវាមានលក្ខណៈងាយស្រួលក្នុងការវិនិច្ឆ័យអ្នកដទៃ ដោយមើលលើចំណុចអវិជ្ជមានរបស់ពួកគេ ក៏ប៉ុន្តែប្រសិនបើយើងចាប់ផ្ដើម ដោយការស្គាល់ពីចំណុចវិជ្ជមាន និងឱ្យតម្លៃទៅលើចំណុចទាំងអស់នេះ នោះវានឹងជួយ បង្កើនទំនាក់ទំនងរបស់យើងឱ្យកាន់តែល្អ និងភាពសប្បាយរីករាយ។ នៅពេលណាទំនាក់ទំនងយើងកាន់តែល្អពេលនោះយើងក៏កាន់តែស្គាល់នូវគំនិតរបស់អ្នកដទៃថែមទៀត។ការធ្វើបែបនេះគឺមិនមានន័យថាយើងត្រូវតែយល់ស្របជាមួយនឹងពួកគេ ក៏ប៉ុន្តែវាជួយយើងឱ្យមានការគោរពចំពោះគ្នា បើទោះបីជាយើងមិនមានការយល់ស្របគំនិតគេក៏ដោយ។

| | | |
|---|---|---|
| មនុស្សម្នាក់ ដែលខ្ញុំសរសើរគឺ..... | សុបិន្តដ៏អាក្រក់បំផុត ដែលខ្ញុំធ្លាប់បានឃើញគឺ...... | រឿងដែលសប្បាយបំផុត ដែលបានកើតឡើងចំពោះ ខ្ញុំ គឺ................ |
| របស់ដែលជាចំណង់ចំណូលចិត្តរបស់ខ្ញុំគឺ...... | របស់ដែលខ្ញុំចូលចិត្តធ្វើ នៅពេលខ្ញុំនៅជាមួយនឹង ក្រុមគ្រួសាររបស់ខ្ញុំគឺ........ | របស់ដែលខ្ញុំពិតជាចង់បាន គឺ............. |
| របស់ដែលខ្ញុំពិតជាចូលចិត្តធ្វើ □□............ | កន្លែងដែលជាចំណង់ ចំណូលចិត្តរបស់ខ្ញុំគឺ............. | បំណងប្រាថ្នាដ៏អាថ៌កំបាំង ដែលខ្ញុំមានគឺ.......... |

| | |
|---|---|
| ខ្ញុំចង់ក្លាយទៅ ជា................. | រឿងមួយដែលខ្ញុំពិតជាអាច ធ្វើបានល្អគឺ.............. |
| របស់មួយចំនួនដែលខ្ញុំចង់រក្សាទុកជារៀងរហូតគឺ..................... | របស់មួយចំនួន ឬនរណាម្នាក់ដែលខ្ញុំពិតជាភ័យខ្លាចគឺ........ |
| សុបិន្តនៅពេលថ្ងៃ ដែលជាចំណង់ចំណូលចិត្តរបស់ខ្ញុំ គឺ.......... | មនុស្សម្នាក់ដែលខ្ញុំស្រឡាញ់ គឺ.............. |

# មេរៀនទី ៣: ខ្ញុំត្រូវការអ្នក អ្នកត្រូវការខ្ញុំ

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ហ្វឺត ឬដីស
- ក្ដារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត ប័ណ្ណរូបភាព រឿងសត្វជ្រូកបីក្បាល

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សទាំងអស់នឹងអាច ៖

- យល់អំពីគុណប្រយោជន៍នៃការសហការ និងការធ្វើការរួមគ្នា

## រំឭកមេរៀនចាស់

🕑 ២៥ នាទី

"តើអ្នកអាចចែករំលែកនូវអ្វី ដែលយើងបានរៀនកាលពីមេរៀនមុនបានទេ?"

- គ្រូឱ្យសិស្សពីរ បីនាក់ ចែករំលែកគំនិតរបស់ពួកគេជាមួយនឹងមិត្តរួមថ្នាក់។ គ្រូត្រូវគិតពីការចូលរួម ចែករំលែកគំនិតរវាងសិស្សប្រុស និងសិស្សស្រី។



## ចំណងជើងមេរៀនទី ៣: ខ្ញុំត្រូវការអ្នក អ្នកត្រូវការខ្ញុំ

## សេចក្ដីផ្ដើម

គ្រូប្រាប់សិស្សថា:កាលពីមេរៀនមុន យើងក៏បានសិក្សាអំពីសារៈសំខាន់នៃការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងក្នុងសង្គម ។ ក្នុងមេរៀននេះយើងនឹងបន្តសិក្សា និងបង្កើនសេចក្ដីទុកចិត្តរវាងគ្នាថែមទៀតដែលយើងបានបង្កើតនៅមេរៀនមុន ។

ប្រសិនបើមិនមានកន្លែងគ្រប់គ្រាន់នៅក្នុងថ្នាក់ សម្រាប់ធ្វើសកម្មភាព ចូរប្រាប់សិស្សឱ្យចេញទៅខាងក្រៅថ្នាក់រៀន។ គ្រូឱ្យសិស្សទាំងអស់កាន់ដៃគ្នា ដើម្បីបង្កើតជារង្វង់មួយ ដោយមិនឱ្យដាច់រង្វង់ ពួកគេត្រូវដើរនៅក្រោមដៃគ្នា រហូតដល់ពួកគេ បានបង្កើតជាចំណងមួយ។ គោលបំណងរបស់សកម្មភាព គឺត្រូវស្រាយចំណងនោះ ដោយមិនឱ្យព្រលែងដៃពីគ្នា។

នៅពេលដែលសិស្សបានស្រាយចំណងរួចគ្រូឱ្យសិស្សធ្វើសកម្មភាពនោះម្តងទៀត។ ពេលនេះគឺមានសិស្សម្នាក់ត្រូវដកចេញពីក្នុងរង្វង់នោះ។ ចំណែកឯសិស្សដែលនៅសល់ត្រូវនាំគ្នាចងចំណងដូចដែលបានធ្វើពីខាងលើ។ ចំពោះសិស្សដែលមិននៅក្នុងរង្វង់ ត្រូវព្យាយាមប្រាប់អ្នកដែលនៅក្នុងរង្វង់ពីរបៀបក្នុងការស្រាយចំណងខ្លួនពួកគេ។ នាង/គាត់អាចផ្តល់ជាការណែនាំ ថា តើនរណាគួរតែប្តូរទៅកន្លែងណាទៀត...។

- នៅពេលដែលសកម្មភាពនេះបញ្ចប់ គេសួរទៅសិស្សទាំងអស់ថា៖ តើវិធីមួយណាដែលធ្វើបានលឿនបំផុត? ដោយមានការណែនាំពីសិស្សគ្នាឯង ឬក៏គ្មានការណែនាំ? ហេតុអ្វី?

- ចំពោះសកម្មភាពនេះ គឺនិយាយអំពីការធ្វើការងារជាក្រុម។ នៅពេលដែលយើងធ្វើការងារជាក្រុម គឺយើងត្រូវការទំនាក់ទំនងឱ្យបានច្បាស់លាស់ ចេះសហការគ្នា ព្រមទាំងការជួយគាំទ្រ និងជួយគ្នាទៅវិញទៅមក។ សម្រាប់មេរៀនថ្ងៃនេះ យើងនឹងធ្វើការផ្តោតទៅលើការបង្កើនជំនាញ ក្នុងការធ្វើការងារជាក្រុមរបស់យើង។ នៅពេលក្នុងដំណើរការមេរៀននេះ យើងក៏នឹងបន្តការសិក្សាជាច្រើនទៀតអំពីខ្លួនរបស់យើងផ្ទាល់ ដែលនឹងជួយយើងឱ្យរៀនធ្វើការងារកាន់តែប្រសើរជាមួយអ្នកដទៃ។

## សកម្មភាពសំខាន់។

🕑 ៦០ នាទី

- យើងទាំងអស់គ្នានឹងបង្កើតជាសាច់រឿងមួយជាមួយគ្នា។ គ្រូបែងចែកសិស្សនៅក្នុងក្រុមដែលមានគ្នា ៩នាក់ ឬច្រើនជាង នេះអាស្រ័យទៅតាមចំនួនសិស្សក្នុងថ្នាក់ (ចំនួនសិស្សប្រុសនិងសិស្សស្រីត្រូវមានភាពប្រហាក់ប្រហែលគ្នាក្នុងក្រុមនីមួយៗ)។

- គ្រូចូរប្រាប់សិស្សថា អ្នកនឹងឱ្យសិស្សម្នាក់ៗនៅក្នុងក្រុមនីមួយៗ នូវបណ្ណរូបភាពម្នាក់ មួយសន្លឹក។ ចំពោះរូបភាពនេះគឺបានមកពីរឿងមួយ។ សិស្សម្នាក់ៗ ត្រូវតែធ្វើការពណ៌នារូបភាពរបស់ខ្លួនទៅកាន់សិស្សដទៃទៀតនៅក្នុងក្រុមរបស់ខ្លួន។ បន្ទាប់ពីសិស្សម្នាក់ៗបានពិពណ៌នារូបភាពរបស់ខ្លួនរួចក្រុមនីមួយៗ ត្រូវរៀបឬចាត់លំដាប់លំដោយនៃរូបភាពទាំងនោះ ដើម្បីឱ្យពួកគេអាចប្រាប់អំពីដំណើររឿងនេះបានពេញលេញ។ សិស្សម្នាក់ៗ ព្រមទាំងបណ្ណមួយសន្លឹកនោះ នឹងបង្ហាញថាពួកគេ គឺស្ថិតនៅផ្នែកណាមួយរបស់សាច់រឿងនេះ។

- គ្រូធ្វើការពន្យល់ទៅកាន់សិស្សថា នេះគឺជាការប្រកួតប្រជែងមួយ ដើម្បីពិនិត្យមើលថា តើក្រុមមួយណាដែលអានរឿងបានត្រឹមត្រូវតាមដំណើររឿង។ ជំរុញនិងលើកទឹកចិត្តសិស្ស ឱ្យមានការជជែក ពិភាក្សា និងឯកភាពគ្នារួមមួយក្នុងការរៀបលំដាប់នៃរូបភាព។

- គ្រូចែកបណ្ណរូបភាពដល់សិស្សម្នាក់មួយសន្លឹកៗ ក្នុងក្រុម (ឬពីរនាក់មួយសន្លឹក អាស្រ័យទៅតាមចំនួនសិស្សក្នុងក្រុមនីមួយៗ)

- គ្រូទុកពេលឱ្យសិស្ស ១៥នាទី។ នៅខណៈពេលដែលក្រុមនីមួយកំពុងពិភាក្សា គ្រូអាចសង្កេត និងបំពេញសន្លឹកវាយតម្លៃការសិក្សារបស់សិស្ស (សន្លឹកវាយតម្លៃនេះមាននៅផ្នែកខាងក្រោយសៀវភៅនេះដែលលោកគ្រូ/អ្នកគ្រូនឹងបំពេញវាបន្ទាប់ពីមេរៀនទី១០)។

- គ្រូសង្កេត ហើយកត់ត្រាដោយផ្អែកលើចំណុចសំខាន់ៗខាងក្រោម:

- តើក្រុមនីមួយៗ ធ្វើការប្រាស្រ័យទាក់ទងគ្នាជាមួយសមាជិកដូចម្តេចដែរ? តើពួកគេរីករាយដែរឬទេ?
- តើពួកគេជួយគ្នាដោយរបៀបណានៅក្នុងក្រុមនីមួយៗក្នុងការរៀបលំដាប់សាច់រឿង? តើពួកគេបានចូលរួមពិភាក្សាទាំងអស់គ្នា ដែរឬទេ?
- តើមានសិស្សមួយចំនួន បានត្រួតត្រាលើសិស្សដទៃ ដែរឬទេ?

- បន្ទាប់ពីក្រុមនីមួយៗពិភាក្សាចប់គ្រូឱ្យក្រុមនីមួយៗឡើងបង្ហាញលទ្ធផលក្រុមរបស់ខ្លួនឯងក្រុមដទៃទៀតស្តាប់។

- ជំរុញឱ្យមានការទះដៃ បន្ទាប់ពីក្រុមនីមួយៗបង្ហាញចប់។ គ្រូត្រូវបង្ហាញចម្លើយត្រឹមត្រូវដល់សិស្សវិញបន្ទាប់ពីក្រុមទាំងអស់បានបង្ហាញរួច។ ទាំងអស់គ្នាទះដៃលើកទឹកចិត្តដល់ក្រុម ដែលធ្វើបានត្រឹមត្រូវ។

- គ្រូប្រើសំណួរខាងក្រោម ដើម្បីពិភាក្សាពីសារៈសំខាន់នៃការធ្វើការងារជាក្រុម
- គ្រូសួរសំណួរមួយចំនួនដូចខាងក្រោមៈ
  - តើអ្នកមានអារម្មណ៍ដូចម្តេច ចំពោះការធ្វើសកម្មភាពនេះ ?
  - តើមានការពិបាកដែរឬទេ ? បើមាន អ្វីខ្លះ ?
  - តើការធ្វើការងារជាក្រុម ជួយអ្នកឱ្យសម្រេចការងារបានដូចម្តេចដែរ ?
  - តើអ្នកគិតថា អ្នកអាចសម្រេចកិច្ចការនេះដោយខ្លួនអ្នកបានល្អប្រសើរដែរឬទេ ?
  - បើមានឱកាស តើអ្នកអាចធ្វើអ្វីឱ្យខុសប្លែកពីលើកនេះឬទេ ?
  - តើអ្នកគិតថា ការធ្វើការងារជាក្រុមផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

កត់ត្រាចម្លើយ និងចំណុចសំខាន់ៗនៃសំណួរខាងលើ ដើម្បីបង្កើតជាបញ្ជីមួយស្តីពី សារៈសំខាន់នៃការធ្វើការងារជាក្រុម និងការណែនាំអំពីរបៀបក្នុងការធ្វើការងារជាក្រុមរបស់យើងឱ្យកាន់តែប្រសើរឡើង។ លោកគ្រូ/អ្នកគ្រូអាចប្រើប្រាស់គំនិតនៅក្នុងសេចក្តីណែនាំសម្រាប់គ្រូ ដើម្បីប្រាកដថាចំណុចសំខាន់ៗត្រូវបានដាក់បញ្ចូល រួចឱ្យសិស្សសរសេរ សេចក្តីណែនាំចូលក្នុងសៀវភៅរបស់គេ។

**បញ្ចប់មេរៀន** ១៥ នាទី

នៅពេលដែលសិស្សកំពុងតែអនុវត្តសកម្មភាពពិភាក្សា គ្រូត្រូវសង្កេតនិងកត់ត្រាពីរបៀបដែលក្មេងទាំងអស់ធ្វើការងារជាមួយគ្នា។ តើប្អូនៗទាំងអស់គ្នាចង់ដឹងដែរឬទេ ថាអ្នកគ្រូ/លោកគ្រូបានអង្កេតមើលអ្វីខ្លះ ?

សម្គាល់៖ *ការផ្តល់ជាមតិត្រឡប់របស់គ្រូចំពោះការអង្កេត មិនត្រូវផ្តល់ជាលក្ខណៈបុគ្គលនោះទេ ឧ. មិនត្រូវហៅឈ្មោះឬចង្អុលសិស្សចំៗនោះទេ។ លោកគ្រូ/អ្នកគ្រូត្រូវនិយាយជាទូទៅអំពីអ្វីខ្លួនបានអង្កេត។ ការផ្តល់មតិត្រឡប់ ត្រូវមានលក្ខណៈវិជ្ជមាន និងបែបស្ថាបនាសម្រាប់សកម្មភាពលើកក្រោយទៀត។ គ្រូអាចប្រើប្រាស់សេចក្តីណែនាំដែលបានបង្កើតនៅក្នុងមេរៀនការយល់ដឹងផ្ទាល់ខ្លួន*

បន្ទាប់ពីចែករំលែករួចរាល់ គ្រូប្រាប់សិស្សថាពួកគេត្រូវតែគិតអំពី ចំណុចសំខាន់មួយដែលពួកគេបានរៀនពីមេរៀនក្នុងថ្ងៃនេះ។ គ្រូឱ្យពួកគេនូវល្បះខ្លីៗមួយ ដូចខាងក្រោមដើម្បីឱ្យពួកគេ បំពេញ។ ពួកគេអាចសរសេរល្បះទាំងអស់នេះនៅក្នុងសៀវភៅកត់ត្រារបស់ពួកគេ។

✎ ចំណុចសំខាន់បំផុត ដែលខ្ញុំរៀនបានពីក្រុមការងាររបស់ខ្ញុំនៅថ្ងៃនេះគឺ...

គ្រូផ្តល់ពេល៥នាទីសម្រាប់ការបំពេញ និងសរសេរល្បះនេះដាក់ចូលក្នុងសៀវភៅ។បន្ទាប់ពីសិស្សបំពេញចប់គ្រប់គ្នាហើយ គ្រូអាចឱ្យសិស្សស្រី/ប្រុសស្ម័គ្រចិត្ត ២/៣នាក់ ឡើងអានល្បះរបស់គេ ដល់សិស្សក្នុងថ្នាក់ទាំងអស់។

*អរគុណអ្នកទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកក្នុងពេលឆាប់ៗនេះ នៅក្នុងមេរៀនក្រោយ។*

## ខ្លឹមសារសំខាន់

- នៅពេលយើងធ្វើការជាមួយគ្នាបានល្អនៅក្នុងក្រុម យើងទាំងអស់គ្នានឹងមានភាពសប្បាយរីករាយ ហើយនឹងអាចសម្រេចបាននូវគោលបំណងរបស់យើងថែមទៀត។

- ប្រសិនបើយើងចង់ធ្វើការជាមួយគ្នាបានល្អ យើងចាំបាច់ត្រូវរៀនទំនាក់ទំនងគ្នា ឱ្យបានច្បាស់លាស់។

- យើងត្រូវចេះស្តាប់ និងគោរពគ្នាទៅវិញទៅមក ប្រកបដោយភាពស្មើគ្នា។

- យើងត្រូវចាប់ផ្តើមជឿជាក់ថា គំនិតរបស់មនុស្សដទៃ/មិត្តរួមថ្នាក់ គួរតែត្រូវបានគោរព បើទោះបីជាយើងមិនឯកភាពលើគំនិត ឬយោបល់នោះក៏ដោយ។

- នៅពេលធ្វើការងារជាក្រុម អ្នកចាំបាច់ត្រូវមានភាពស្មោះត្រង់រវាងគ្នានឹងគ្នា ហើយត្រូវនិយាយនូវអ្វីដែលអ្នកគិតក្នុងន័យស្ថាបនា មិនមែនរិះគន់បន្ទុះបង្អាប់នោះទេ។

- យើងត្រូវចេះជួយគ្នា ផ្តល់ទំនុកចិត្ត និងស្តាប់មតិយោបល់ និងការយល់ឃើញរបស់គ្នាទៅវិញទៅមក ហើយពេលខ្លះនៅក្នុងក្រុម យើងអាចជ្រើសរើសមនុស្សម្នាក់ជាតំណាងក្រុម ដើម្បីចែករំលែកគំនិតបន្តទៅក្រុមដទៃទៀត។ សមាជិកក្រុមទាំងអស់អាចធ្វើជាអ្នកតំណាងក្រុមបានដូចគ្នាមិនថាសិស្សប្រុស/ស្រី ទេ។

- នៅក្នុងការធ្វើការងារជាក្រុម វាសំខាន់ណាស់ ក្នុងការទទួលស្គាល់ពីមុខងាររបស់សមាជិកម្នាក់ៗរបស់ក្រុម។ សមាជិកទាំងអស់មានមុខងារមួយ ដែលខ្លួនត្រូវបំពេញ។ មុខងារនេះ គឺវាអាស្រ័យទៅលើភាពផ្សេងៗគ្នានៃចរិតលក្ខណៈ និងការយល់ឃើញរបស់សមាជិកម្នាក់ៗ។ ភាពខុសប្លែកគ្នានេះ នាំឱ្យ ការធ្វើការងារជាក្រុមកាន់តែមានភាពសំបូរបែប។ មុខងារនីមួយៗគឺជួយបំពេញឱ្យគ្នាទៅវិញទៅមក។

- ការទំនុកបម្រុងគ្នាទៅវិញទៅមក ក៏អាចមានន័យផងដែរថា យើងជួយគ្នាទៅវិញទៅមក ដោយមានការយោគយល់គ្នា ហើយក៏ធ្វើការកត់ចំណាំនូវអ្វីដែលជាតម្រូវការ របស់អ្នកដទៃ។

- ការរៀបចំគម្រោងជាមួយគ្នា គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ភាពជោគជ័យរបស់ ក្រុមការងារ។

- បើទោះបីជាយើងមិនមានការយល់ព្រមគ្នាក៏ដោយ ក៏នៅចុងបញ្ចប់គំនិតដែលសំខាន់បំផុតគឺត្រូវបានគាំទ្រ។

- ការមិនពេញចិត្តនឹងគ្នា និងភាពមិនសប្បាយចិត្ត ទាំងអស់នេះគឺមិនអាចជួយក្រុមការងារបានឡើយ។ យើងចាំបាច់ត្រូវតែស្វែងរកមើលនូវវិធីដែលជាការស្ថាបនា ដើម្បីដោះស្រាយភាពមិនទទួលបានជោគជ័យនិងការមិនចុះសំរុងនឹងគ្នា។



១.កាលពីព្រេងនាយមានជ្រូកតូចចំនួន៣ក្បាលដែលបាន
សម្រេចចិត្តថា ពួកគេត្រូវនាំគ្នាសាងសង់ផ្ទះមួយ។



២.ជ្រូកតូចមួយក្បាលបានសម្រេចចិត្តសាងសង់
ផ្ទះធ្វើអំពីឈើ។



៣.ជ្រូកតូចមួយទៀតបានសម្រេចចិត្តថាសាងសង់ផ្ទះធ្វើ
អំពីចំបើង។



៤.ចំណែកឯជ្រូកតូចទី៣វិញសម្រេចចិត្តថាសាងសង់ផ្ទះ
អំពីឥដ្ឋ ក្បឿង។



៥.ថ្ងៃមួយមានឆ្កែចចកអត់ឃ្លានមួយក្បាល បានធ្វើដំណើរ
មកដល់ផ្ទះឈើនោះហើយបានបំផ្លិចបំផ្លាញផ្ទះនោះដើម្បី
ចាប់សត្វជ្រូកដែលកំពុងតែនៅខាងក្នុងនោះ។ សំណាង
ល្អជ្រូកនោះបានរត់គេចខ្លួនបាត់ទៅស្នាក់នៅជាមួយជ្រូក
ដែលធ្វើផ្ទះអំពីចំបើង ។



៦.ប៉ុន្មានថ្ងៃក្រោយមកសត្វឆ្កែចចកដដែលនោះ ក៏បានធ្វើដំណើរទៅកាន់ផ្ទះចំបើងនោះ។ សំណាងល្អម្តងទៀត ជ្រូកទាំង២ក្បាលក៏បានរត់គេចខ្លួន ហើយទៅរស់នៅជាមួយនឹងជ្រូកដែលផ្ទះធ្វើអំពីឥដ្ឋក្បឿង។



៧.ក៏ប៉ុន្តែឆ្កែចចកនោះនៅតែមកម្តងទៀត ហើយបាននិយាយថា"ឱ្យយើងស៊ីអាជ្រូកតូចនោះភ្លាមបើមិនដូច្នោះទេយើងនឹងស៊ីពួកឯងទាំងអស់គ្នាតែម្តង។"



៨.ជ្រូកតូចទាំង៣បានជំទាស់ ដូច្នេះហើយពេលនោះឆ្កែចចកក៏បានឡើងទៅលើខាងលើផ្ទះហើយចុះមកវិញតាមបំពង់ផ្សែង។



៩.ក៏ប៉ុន្តែនៅពេលដែលឆ្កែចចកចុះមកដល់ខាងក្រោមនៃបំពង់ផ្សែង មានឆ្នាំងទឹកក្តៅមួយ កំពុងតែរងចាំវា! ពេលនោះជ្រូកតូចទាំងបីក៏ចាប់ឆ្កែចចកបានទៅ! ។

# មេរៀនទី ៤: រក្សាការសម្ងាត់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ហ្វឺត ឬក៏ដីស
- ក្ដារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត
- ប័ណ្ណដែលមានពណ៌ និងរូបដើមឈើ

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- មានអារម្មណ៍កាន់តែមានទំនុកចិត្តអំពីការចូលរួមដោយសេរីនៅក្នុងថ្នាក់
- យល់អំពីអត្ថន័យ និងសារៈសំខាន់នៃការរក្សាការសម្ងាត់ ដែលពួកគេបានរៀននៅក្នុងថ្នាក់សម្រាប់ខ្លួនពួកគេផ្ទាល់

## រំឭកមេរៀនចាស់ 🕑 ២៥ នាទី

"តើអ្នកអាចចែករំលែកនូវអ្វីមួយ ដែលអ្នកបានរៀនពីមេរៀនមុនបានទេ ?"

គ្រូឱ្យសិស្សពីរ/បីនាក់ ចែករំលែកគំនិតរបស់ពួកគេជាមួយនឹងមិត្តរួមថ្នាក់ និងធ្វើការរំឭកមេរៀនមុន។

## ចំណងជើងមេរៀនទី ៤: រក្សាការសម្ងាត់

### សេចក្ដីផ្ដើម

ប្រាប់សិស្ស:កាលពីមេរៀនមុនយើងបានសិក្សាអំពីសារៈសំខាន់នៃការធ្វើការងារជាមួយគ្នាគឺការងារជាក្រុម។យើងក៏រៀនផងដែរថាការធ្វើការងារជាក្រុមតម្រូវឱ្យមានការគេស៊ូ ការជឿជាក់ នឹងការគោរពគ្នាទៅវិញទៅមក។ ថ្ងៃនេះយើងនឹងបន្តស្វែងយល់ពីអត្ថន័យនៃការជឿជាក់គ្នាបន្ថែមទៀត។មុននឹងចាប់ផ្ដើមមេរៀនយើងនឹងលេងល្បែងមួយសិន ។

- គ្រូឱ្យសិស្សក្រោកឈរឡើង ហើយបង្កើតជារង្វង់មួយ។ ចំពោះការបង្កើតជារង្វង់នេះអាចធ្វើនៅខាងក្រៅថ្នាក់រៀន ប្រសិនបើមិនមានកន្លែងគ្រប់គ្រាន់នៅក្នុងថ្នាក់រៀន។

● គ្រូធ្វើការពន្យល់ប្រាប់សិស្សដែលនៅជិតខ្លួនថា អ្នកត្រូវតែនឹករកល្បះមួយ ដែលអ្នក ត្រូវខ្សឹបប្រាប់សិស្សដែលនៅជាប់ខ្លួនអ្នក។ ចំពោះល្បះអាចនិយាយអំពីអ្វីក៏បានដែរ ក៏ប៉ុន្តែវាមិនចាំបាច់វែងពេកទេ។

●គ្រូធ្វើការពន្យល់ប្រាប់សិស្សដែលនៅជិតគាត់ថា អ្នកត្រូវតែនឹករកនូវល្បះមួយ ដែលពួកគេ ត្រូវខ្សឹបប្រាប់សិស្ស ឱ្យសិស្សផ្តល់ជា ឧទាហរណ៍ ល្បះមួយដើម្បីពិនិត្យមើលថា តើពួកគេបានយល់អំពីល្បែងដែរឬទេ។ នៅពេលដែលសិស្សបាន ត្រៀមខ្លួនរួចរាល់ ព្រមទាំងមានល្បះទៀតនោះ ដូច្នេះពួកគេអាចអាចចាប់ផ្តើមលេងបាន។

●គ្រូធ្វើការពន្យល់ប្រាប់សិស្សដែលនៅជិតគាត់ថា អ្នកត្រូវតែនឹករកនូវល្បះមួយ ដែលពួកគេ ត្រូវខ្សឹបប្រាប់សិស្ស គ្រូខ្សឹបល្បះមួយប្រាប់សិស្ស ដែលនៅខាងស្តាំជាប់នឹងគាត់ នៅខណៈពេលដែលសិស្សនៅខាងឆ្វេងដៃរបស់គាត់ កំពុងខ្សឹបល្បះមួយប្រាប់សិស្សដែលនៅខាងឆ្វេងដៃរបស់ពួកគេ។ ពួកគេត្រូវតែប្រាកដថាសិស្សដទៃទៀត មិនអាចឮអ្វីដែលពួកគេកំពុងខ្សឹបគ្នា។ អ្នកកំពុងស្តាប់ល្បះ អាចស្នើសុំឱ្យគេនិយាយល្បះនោះបានម្តងទៀត។

សិស្សពីរនាក់ផ្សេងទៀត ដែលទទួលបានល្បះដែលគេខ្សឹប ត្រូវខ្សឹបបន្តដល់សិស្ស ដែលស្ថិតនៅជិតពួកគេ។ ល្បែងនេះបន្តរហូតដល់សិស្សទាំងអស់គ្នាបានខ្សឹប នូវល្បះសម្ងាត់ទៅវិញទៅមក ហើយចំពោះល្បះដែលបានមកពីគ្រូបានទៅដល់សិស្សដែលស្ថិតនៅជិតគាត់ហើយល្បះដែលបានមកពីសិស្សទី១បានទៅដល់គ្រូដែលជាមនុស្សចុងក្រោយនឹងទទួលបានល្បះនេះ។

● គ្រូចែករំលែកនិងប្រៀបធៀបល្បះដែលទទួលបានពីការខ្សឹបគ្នានេះ ទៅនឹងល្បះដើម។ សិស្សធ្វើការចែករំលែកល្បះរបស់ពួកគេហើយប្រៀបធៀបល្បះទាំងនេះទៅនឹងល្បះដើម។ នៅពេលដែលសកម្មភាពនេះបញ្ចប់សួរសិស្សថា៖

តើមានអ្វីកើតឡើងចំពោះល្បះដែលបានមកពីការខ្សឹបគ្នានេះ? ហេតុអ្វីបានជាអ្នកគិតថា វាកើតឡើង?
តើល្បែងនេះ វាទាក់ទងដូចម្តេចទៅនឹងពាក្យថា "ការរក្សាការសម្ងាត់"?

✎គ្រូសរសេរ៖ ការរក្សាការសម្ងាត់ នៅលើក្តារខៀន។

ចំពោះសកម្មភាពនេះបង្ហាញនូវអ្វីដែលអាចកើតឡើង នៅពេលដែលយើងធ្វើការចែករំលែករឿងរ៉ាវឬព័ត៌មានអំពីមនុស្សដទៃ ជាមួយនឹងក្រុមធំ។ នៅពេលដែលយើងចែករំលែក ជួនកាលព័ត៌មាននោះ អាចនឹងបាត់បង់ ឬខុសពីព័ត៌មានដើម។ នៅពេលដែលព័ត៌មានចែកទៅមានការខុសឆ្គងនោះនាំឱ្យមនុស្សដទៃទទួលនូវការខូចខាតឬផលអាក្រក់ ។ ដូច្នេះក្នុងមេរៀនថ្ងៃនេះ យើងនឹងធ្វើការសិក្សាអំពីសារៈសំខាន់នៃការជឿជាក់គ្នាទៅវិញទៅមកនឹងការរក្សាការសម្ងាត់ លើរឿងដែលយើងបានចែករំលែក ហើយប្រាកដថា សិស្សទាំងអស់យល់អំពីសារៈសំខាន់នៃការជឿជាក់របស់អ្នកដទៃមកលើខ្លួនយើង។

● គ្រូសួរសិស្សៈ តើអ្នកទាំងអស់គ្នាមានសំណួរអ្វីទាក់ទងនឹងមេរៀនថ្ងៃនេះឬទេ?

## សកម្មភាពសំខាន់។ 🕑 ៦០ នាទី

👄 យើងនឹងបង្កើតបញ្ជីវិន័យមួយ ដើម្បីជួយយើងទាំងអស់គ្នាបង្កើននូវភាពជឿជាក់ ដើម្បីឱ្យយើងទាំងអស់គ្នាអាចចែករំលែកគំនិត ដោយបើកចំហ និងស្មោះត្រង់រវាងគ្នា។

● បង្ហាញរូបដើមឈើ ដល់សិស្សទាំងអស់ រួចសួរ៖

តើយើងទាំងអស់គ្នាអាចធ្វើអ្វីបានខ្លះ ដើម្បីឱ្យដើមឈើនេះអាចដុះលូតលាស់ មានសុខភាពល្អ មានផ្លែប្រកបដោយឱជារស និងមានម្លប់ត្រឈឹងត្រឈៃដល់យើងទាំងអស់គ្នាបាន?

បន្ទាប់ពីឱ្យសិស្សពីរបីនាក់បានចែករំលែកនូវគំនិតរបស់ពួកគេរួច ហើយគ្រូសួរពួកគេម្តងទៀត។

ប្រសិនបើយើងស្រមើស្រមៃថា ថ្នាក់រៀនយើងដូចជាដើមឈើមួយដើម *"តើយើងអាចធ្វើអ្វីបានខ្លះ ដើម្បីថែរក្សាថ្នាក់រៀនយើង ឱ្យក្លាយជាកន្លែងមួយ សម្រាប់ការពារយើង និងធ្វើឱ្យយើងមានសុវត្ថិភាព ដែលអាចជួយឱ្យក្រុមរបស់យើងខ្លាំងនិងអាចបញ្ចេញគំនិតល្អៗ ដោយគ្មានការភ័យខ្លាច។"*

● គ្រូសរសេរសំណួរនេះនៅលើក្តារខៀន។

សិស្សមិនចាំបាច់ឆ្លើយសំណួរនេះទេផ្ទុយទៅវិញចូរប្រាប់ពួកគេថាយើងនឹងឆ្លើយសំណួរនេះដោយធ្វើការអនុវត្តជាសកម្មភាពតូចមួយ។

● គ្រូចែកសិស្សជាគូ ឬជាក្រុមដែលមានគ្នា ៤នាក់ ប្រសិនបើថ្នាក់រៀនមានចំនួនធំ។

● គ្រូឱ្យបណ្ណដែលមានពណ៌ចំនួន២ដុំ ទៅគូ/ក្រុមនីមួយៗ

គ្រូប្រាប់សិស្សថានៅលើប័ណ្ណនីមួយៗ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាសរសេរគំនិតមួយដែលឆ្លើយតបទៅនឹងសំណួរនៅលើក្តារខៀន។គំនិតដែលមាននៅលើប័ណ្ណនីមួយៗគួរតែខុសគ្នា។ មុនពេលអ្នកសម្រេចចិត្តថាត្រូវសរសេរអ្វីចូរគិតត្រឡប់ទៅរកអ្វីដែលយើងបានពិភាក្សាកាលពី២មេរៀនមុន។អ្នកទាំងអស់គ្នាក៏អាចប្រើប្រាស់សៀវភៅកត់ត្រារបស់អ្នកដើម្បីជាការរំឭកអ្នក។ ចូរពិភាក្សាបញ្ហានេះជាមួយនឹងដៃគូរ/ក្រុមរបស់អ្នក មុននឹងអ្នកសរសេរដាក់ចូល។ ការពិភាក្សាគ្នាបណ្ណមានសារៈសំខាន់ដូចការសរសេរដែរ។ចូរគិតជាមួយគ្នាអំពីអ្វីដែលយើងគួរតែធ្វើនិងអ្វីដែលយើងមិនគួរធ្វើ។ នៅពេលដែលអ្នកទាំងអស់គ្នាពិភាក្សារួច អ្នកអាចសរសេរគំនិតអ្វី ដែលយើងទាំងអស់គ្នាគួរតែធ្វើ និងអ្វីដែលយើងមិនគួរធ្វើដាក់ក្នុងប័ណ្ណ ដើម្បីធ្វើឱ្យថ្នាក់រៀនយើងមានការរីកចម្រើនកាន់តែខ្លាំង និងក្លាយទៅជាកន្លែងមួយដែលមានសុវត្ថិភាពផងដែរ។

នៅអំឡុងពេលសិស្សទាំងអស់គ្នាកំពុងធ្វើការពិភាក្សា ចូរគ្រូដើរជុំវិញដើម្បីត្រួតពិនិត្យមើលការយល់ដឹងរបស់សិស្សចំពោះកិច្ចការនេះ ហើយជម្រុញឱ្យពួកគេប្រើប្រាស់នូវអ្វីដែលពួកគេបានរៀនកាលពីមេរៀនមុនៗ។

● គ្រូបិទក្រដាសផ្ទាំងធំ ហើយគូសបែងចែកជា២ជួរ ដោយមួយផ្នែកសរសេរអ្វីដែលគួរធ្វើ និងមួយផ្នែកទៀតសរសេរអ្វីដែលមិនគួរធ្វើ។

នៅពេលដែលសិស្សទាំងអស់បានបញ្ចប់កិច្ចការនេះរួចរាល់ គ្រូឱ្យសិស្សឡើងមកបិទបណ្ណ័ទាំងអស់នោះនៅក្នុងជួរនីមួយៗ ឱ្យបានត្រឹមត្រូវ។

● គ្រូជួយសិស្សក្នុងការបិទប័ណ្ណរបស់ពួកគេ។ បន្ទាប់មកឱ្យសិស្សឡើងអាននូវអ្វីដែលមាននៅលើក្រដាសផ្ទាំងធំ។ នៅពេលដែលពួកគេកំពុងអានគំនិតរបស់ពួកគេ ចូរនាំគ្នាពិភាក្សានូវចំនុចដែលមិនច្បាស់លាស់ ហើយកគំនិតទាំងឡាយណាដែលជាន់គ្នាឬដកចេញនូវគំនិតដែលមិនត្រឹមត្រូវ នឹងបំពេញបន្ថែមនូវចំនុចដែលខ្វះខាត។ គ្រូត្រូវប្រាកដថានៅ ក្នុងបញ្ជី "អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ" គឺមានរួមបញ្ចូលនូវគំនិតដែលមានក្នុងកំណត់ត្រារបស់គ្រូ។

● គ្រូឱ្យសិស្សចម្លងបញ្ជី "អ្វីគួរធ្វើ និងអ្វីមិនគួរធ្វើ" ចូលក្នុងសៀវភៅរបស់ពួកគេ។

**បញ្ចប់មេរៀន** ១៥ នាទី

តើមានអ្វីកើតឡើង ប្រសិនបើយើងទាំងអស់គ្នាធ្វើខុសវិន័យខាងលើ?

*សម្គាល់៖ គ្រូឱ្យសិស្សនឹករកនូវគំនិតមួយចំនួន ដែលស្តីអំពីវិធីដើម្បីធ្វើឱ្យប្រាកដថា យើងប្រកាន់បានខ្ជាប់ខ្ជួននូវវិន័យជាមូលដ្ឋានរបស់យើងដូចជា៖ ធ្វើការរំឭកគ្នាទៅវិញទៅមកពីវិន័យដោយលក្ខណៈមិត្តភក្តិ, បិទវិន័យនៅក្នុងថ្នាក់z, ពេល ចាប់ផ្តើមបង្រៀន ឬបញ្ចប់មេរៀនមួយធ្វើការត្រួតពិនិត្យឡើងវិញ តើវិន័យណាដែលយើងបានអនុវត្តតាមហើយ មានវិន័យណាដែលយើងមិនបានគោរព និងមូលហេតុអ្វី។*

ឥឡូវនេះយើងនាំគ្នាអនុវត្តវិន័យនេះទាំងអស់គ្នា។ ក្រឡេកមើលវិន័យទាំងអស់ដែលមាននៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ តើមាន វិន័យណាមួយដែលអ្នកគិតថា អនុវត្តទៅបានល្អប្រសើរសម្រាប់ថ្ងៃនេះ? តើមានវិន័យណាមួយដែលអ្នកមិនបានអនុវត្ត នៅថ្ងៃនេះ ហើយចង់ធ្វើឱ្យបានល្អនៅមេរៀនក្រោយ? អ្នកអាចសរសេរនូវគំនិតរបស់អ្នកក្នុងសៀវភៅកត់ត្រារបស់អ្នក ប្រសិនបើអ្នកចង់ឬក៏អ្នកគ្រាន់តែគិតអំពីវារយៈពេលពីរបីនាទី។

ក) ខ្ញុំគិតថា ខ្ញុំអាចធ្វើតាមវិន័យមូលដ្ឋានរបស់យើងអំពី...
ខ) ខ្ញុំគិតថា នៅក្នុងមេរៀនក្រោយ ខ្ញុំអាចបង្កើនវិន័យមូលដ្ឋានអំពី...។

ប្រសិនបើសិស្សមួយចំនួនបានបញ្ចប់មុនសិស្សដទៃទៀត គ្រូអនុញ្ញាតឱ្យពួកគេធ្វើការចែករំលែកនូវល្បះរបស់ពួកគេជាមួយគ្នា ឬក៏ជាមួយនឹងមិត្តរួមថ្នាក់ទាំងអស់។

## ខ្លឹមសារសំខាន់

- ការរក្សាការសម្ងាត់មានន័យថា រឿងរ៉ាវផ្ទាល់ខ្លួនដែលបានចែករំលែកនៅក្នុងក្រុម គឺត្រូវរក្សាទុកនៅក្នុងក្រុម មិនត្រូវចែករំលែកចេញទៅក្រៅជាដាច់ខាត។
- ការរក្សាការសម្ងាត់ ក៏ត្រូវការជាចាំបាច់នូវការគោរពគ្នាទៅវិញទៅមកផងដែរ។
- វិន័យជាមូលដ្ឋានគួរតែរួមបញ្ចូល នូវចំណុចមួយចំនួនដូចខាងក្រោម៖

១) ការគោរពពេលវេលា - ការមកទាន់ពេលវេលា គឺបង្ហាញនូវការគោរពចំពោះ អ្នកដទៃ។
២) ការបង្ហាញពីការយកចិត្តទុកដាក់ចំពោះគ្នានៅក្នុងក្រុម - ព្យាយាមយល់ពីអារម្មណ៍របស់អ្នកដទៃ តើពួកគេមានអារម្មណ៍ដូចម្តេច ហើយហេតុអ្វីបានជាគេបង្ហាញអាកប្បកិរិយាបែបនេះ។
៣)ហ៊ាននិយាយចេញ - កុំភ័យខ្លាចក្នុងការនិយាយនូវអ្វីដែលអ្នកគិត - គំនិតរបស់យើងទាំងអស់គ្នា គឺសុទ្ធតែមានតម្លៃ។
៤) ក្លាហានដើម្បីបង្កើតកំហុស/សារភាពថា យើងមិនដឹងអ្វីមួយ - ការបង្កើតកំហុស និងការសារភាពអំពីកំហុសដែលយើងមិនបានដឹង វាជាមធ្យោបាយមួយដ៏ល្អបំផុតដើម្បីធ្វើការសិក្សារៀនសូត្រ។ ការសារភាពនូវកំហុសរបស់យើង គឺសញ្ញាមួយដែលយើងកំពុងតែធ្វើការសិក្សា។
៥) ស្តាប់គ្នាទៅវិញទៅមក - នេះ គឺជាសញ្ញានៃការគោរពគ្នាទៅវិញទៅមក។ តើយើងអាចរៀន ពីមនុស្សដទៃទៀត ឬក៏ជួយមនុស្សដទៃទៀតដោយវិធីណា ប្រសិនបើយើងមិនដឹងនូវអ្វី ដែលពួកគេកំពុងតែនិយាយ។
៦) លើកទឹកចិត្តឱ្យគ្នាទៅវិញទៅមក- ហាមស្តីបន្ទោស ធ្វើការវិនិច្ឆ័យ ឬក៏សើចចំអកដល់អ្នកដទៃ។
៧) មានភាពសប្បាយរីករាយ! - យើងកាន់តែរីករាយជាមួយនឹងអ្វីដែលយើងធ្វើ គឺយើងកាន់តែសិក្សាបានច្បាស់ពីវាផងដែរ។
៨) រក្សាការសម្ងាត់ឱ្យគ្នា - ចូរចងចាំថា យើងទាំងអស់គ្នានៅទីនេះ គឺដើម្បីគាំទ្រ និងជួយគ្នាទៅវិញទៅមក ដើម្បីឱ្យមានភាពរីកចម្រើនទាំងអស់គ្នា ដូច្នេះ យើងចាំបាច់ត្រូវតែជឿជាក់ថា មនុស្សទាំងអស់ គឺចង់ផ្តល់អ្វីដែលល្អបំផុតសម្រាប់ពួកយើង ហើយយើងនឹងបង្ហាញថា យើងក៏ផ្តល់អ្វីដែលល្អបំផុតសម្រាប់ពួកគេផងដែរ។

*គោរពអ្នកដទៃ ឱ្យដូចទៅនឹងរបៀបដែលយើងចង់ឱ្យគេគោរពយើងវិញដែរ។*



# មេរៀនទី ៥: ពិភពខាងក្នុងរបស់ខ្ញុំ

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត
- ខ្សែ

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ប្រាប់អំពីសារៈសំខាន់នៃពិភពខាងក្នុងរបស់ខ្លួន និងមានអារម្មណ៍កាន់តែជឿជាក់អំពី ការឆ្លុះបញ្ចាំងមកលើខ្លួនយើង
- បង្ហាញថា ការអប់រំ គឺនិយាយអំពីការស្វែងរក មិនត្រឹមតែការពិតនឹងពិភពខាងក្រៅទេ ថែមទាំងពិភពខាងក្នុងនៃអារម្មណ៍ និងផ្លូវចិត្តទៀត។

## រំឭកមេរៀនចាស់ 🕑 ៣០ នាទី

- គ្រូសួរសិស្ស "តើសិស្សទាំងអស់អាចចែករំលែកនូវអ្វី ដែលយើងបានរៀនកាលពីមេរៀនមុនបានទេ?"
- គ្រូឱ្យសិស្សពីរបីនាក់មានប្រុសមានស្រី ឡើងចែករំលែកនូវគំនិតរបស់ពួកគេជាមួយនឹងមិត្តរួមថ្នាក់។

## ចំណងជើងមេរៀនទី ៥: ពិភពខាងក្នុងរបស់ខ្ញុំ

## សេចក្តីផ្តើម

●គ្រូប្រាប់សិស្សថាៈកាលពីមេរៀនមុន យើងក៏បានសិក្សាអំពីសារៈសំខាន់នៃការមានវិន័យជាមូលដ្ឋាន ដើម្បីជួយយើងឱ្យធ្វើការងារបានល្អជាមួយគ្នា និងដើម្បីបង្កើនបរិយាកាសនៃការជឿជាក់នៅក្នុងថ្នាក់រៀនរបស់យើង។ ជាពិសេស យើងទាំងអស់គ្នាក៏បានរៀនផងដែរអំពីការរក្សាការសម្ងាត់ និងសារៈសំខាន់នៃការមិនចែករំលែកអំពីព័ត៌មានរបស់អ្នកដទៃ ដែលយើងបានរៀននៅក្នុងមេរៀននៅក្នុងមធ្យោបាយមួយ ដែលនឹងធ្វើឱ្យពួកគេឈឺចាប់។ ថ្ងៃនេះ យើងនឹងបន្ត ដំណើររបស់យើងដើម្បីធ្វើការស្វែងយល់ពីខ្លួនរបស់យើងផ្ទាល់ផងដែរ។

● គ្រូប្រាប់សិស្សថា ពួកគេនឹងលេងល្បែងមួយ។ គ្រូដាក់ខ្សែមួយនៅលើឥដ្ឋ ដើម្បីបែងចែកថ្នាក់រៀន។ ចំពោះសកម្មភាពនេះអាចធ្វើនៅខាងក្រៅប្រសិនបើថ្នាក់រៀនតូច។ គ្រូប្រាប់សិស្សទៀតថាអ្នកទាំងអស់គ្នានឹងអានល្បះមួយចំនួន។ ប្រសិនបើ ពួកគេឈរនៅខាងស្តាំដៃនៃខ្សែ គឺមានន័យថាពួកគេយល់ស្របនឹងល្បះនោះហើយប្រសិនបើពួក

គេឈរនៅខាងឆ្វេងដៃនៃខ្សែ គឺមានន័យថាពួកគេមិនយល់ស្របនឹងល្បះនោះ។ ប្រសិនបើពួកគេមិនច្បាស់ពួកគេអាចឈរនៅចំកណ្តាលខ្សែ (គឺជើងម្ខាងនៅខាងស្តាំ និងជើងម្ខាងទៀតនៅខាងឆ្វេងនៃខ្សែ)។

ចូរប្រាកដថា គ្រូអានល្បះឮ ដែលមានក្នុងកំណត់សម្គាល់សម្រាប់គ្រូឱ្យលឿនៗ ដើម្បីឱ្យសកម្មភាពមានភាពរលូននិងសិស្សមានភាពសកម្មភាពក្នុងការផ្លាស់ប្តូរ។ ក្នុងដំណាក់កាលនេះគ្រូមិនចាំបាច់ពិភាក្សាចម្លើយនៅក្នុងចំណុចនេះទេ។ អ្វីដែលសំខាន់ៗនៅជំហាននេះគឺ ឱ្យសិស្សទាំងអស់គ្នាចេះរៀនស្តាប់និងបញ្ចេញគំនិតរបស់ពួកគេនិងគោរពនូវគំនិតរបស់គ្នាទៅវិញទៅមក។ លោកគ្រូ/អ្នកគ្រូអាចកត់សម្គាល់គំនិតមួយចំនួនរបស់សិស្សទុកពិភាក្សានៅពេលក្រោយនៃមេរៀន។

នៅពេលសកម្មភាពត្រូវបានបញ្ចប់គ្រូសួរសិស្សថា"តើពាក្យថាការអប់រំមានអត្ថន័យដូចម្តេចចំពោះអ្នកទាំងអស់គ្នា?តើវានិយាយអំពីការសិក្សាតែពិភពខាងក្រៅឬក៏ជាការសិក្សាអំពីពិភពខាងក្នុងនៃអារម្មណ៍និងផ្លូវចិត្តរបស់យើង ?

● គ្រូសរសេរសំណួរនៅលើក្តារខៀន ហើយប្រាប់សិស្សឱ្យសរសេរចូលក្នុងសៀវភៅរបស់ពួកគេ។
● គ្រូប្រាប់សិស្សថា ពួកគេនឹងមើលសំណួរនេះម្តងទៀតនៅចុងបញ្ចប់នៃមេរៀន។
តើអ្នកទាំងអស់គ្នាមានសំណួរអ្វីទៀតទេចំពោះមេរៀនថ្ងៃនេះ?

## សកម្មភាពសំខាន់។ 🕑 ៦០ នាទី

◈ តើការធ្វើដំណើរដោយមធ្យោបាយជាមួយអ្នកណាដែលអ្នកធ្លាប់បានធ្វើដំណើរកាលពីពេលមុន? តើការធ្វើដំណើរប្រភេទណាដែលអ្នកចូលចិត្ត?

● គ្រូឱ្យសិស្សចែករំលែកឧទាហរណ៍នៃការធ្វើដំណើរមួយចំនួន ដែលពួកគេបានធ្វើពីមុនមក។ សិស្សទាំងអស់គ្នាក៏អាចធ្វើជាបញ្ជីមួយនៃប្រភេទការធ្វើដំណើរតាមនាវា (ការធ្វើដំណើររបស់សាលាក្រុមគ្រួសារការធ្វើដំណើរទៅក្រៅប្រទេស នៅក្នុងប្រទេសកម្ពុជា) ការធ្វើដំណើរតាមទូក ។ល។

យើងទាំងអស់គ្នានឹងបន្តការធ្វើដំណើររបស់យើងនៅពេលឥឡូវនេះ។ តើអ្នកទាំងអស់គ្នាត្រៀមហើយ ឬនៅ?
●គ្រូប្រាប់សិស្សឱ្យបិទភ្នែករបស់ពួកគេ ហើយចាប់ផ្តើមចូលទៅកាន់ទីតាំងមួយ ដែលមានជាសុកភាព។ ប្រសិនបើពួកគេចង់ ពួកគេក៏អាចដាក់ក្បាលរបស់ពួកគេចុះនៅលើតុ។ ប្រាប់ពួកគេថា ពួកគេត្រូវនាំគ្នាស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីដែលគ្រូកំពុងតែនិយាយ បើទោះបីជាភ្នែករបស់ពួកគត បោនបិទក៏ដោយ។ ពួកគេត្រូវបន្តបិទភ្នែករបស់ពួកគេដដែលនៅគ្រប់ពេលទាំងអស់រហូតដល់អ្នកប្រាប់ពួកគេថាពេលណាដែលពួកគេអាចបើកវិញបាន។ ប្រើសម្លេងដ៏ស្រទន់ហើយនិយាយយឺតៗ ដោយឈប់បន្តិចផងដែរ ដើម្បីឱ្យសិស្សអាចមានពេលដើម្បីធ្វើការគិត។

អ្នកទាំងអស់គ្នានឹងបន្តនូវការធ្វើដំណើរដ៏វែងឆ្ងាយមួយ។ ជាដំបូងអ្នកត្រូវយកអីវ៉ាន់របស់អ្នក។ ចំពោះភ្នែករបស់អ្នកត្រូវបិទដដែល ក៏ប៉ុន្តែតើអ្នកអាចមើលអីវ៉ាន់របស់អ្នកដែរឬទេ? យកវាមក។ តើវាធ្ងន់ទេ? តើវាស្រាលទេ? ដាក់វានៅលើខ្នង ប្រសិនបើវាជា សាក់កាដូ។ នាំគ្នាចាប់ផ្តើមឥឡូវនេះតែម្តងទៅ។
"ចាប់ផ្តើមដើរ--- ដឹងថាផ្លូវគឺស្ថិតនៅក្រោមជើងរបស់អ្នក ក្រលេកមើលជុំវិញអ្នកហើយមើលទស្សនីយភាព។ វាជាថ្ងៃមួយដែលស្រស់ថ្លា មិនក្តៅពេក មានខ្យល់បក់រំភើយៗ ដែលអ្នកអាចដឹងតាមរយៈមុខរបស់អ្នក។ ខ្យល់អាកាសមានខ្លិនស្រស់ថ្លាហើយត្រជាក់។ ស្រូបវាចូលហើយរីករាយជាមួយនឹងវា។

អ្នកទាំងអស់គ្នាបានដើរមួយសន្ទុះធំ ហើយកាបូបរបស់អ្នកចាប់ផ្ដើមមានអារម្មណ៍ថាធ្ងន់ទៅៗ។ នៅតាមផ្លូវមានទឹក ហើយវានៅជុំវិញកជើងរបស់អ្នក។ អ្នកទាំងអស់គ្នាអាចដឹងថា មានទឹកនៅជុំវិញជើងរបស់អ្នក ហើយក៏មានល្បាប់ទន់ៗនៅជុំវិញម្រាមជើងរបស់អ្នកផងដែរ។ ទឹកកាន់តែខ្ពស់ៗឡើង គឺវាកំពុងតែកើនឡើង ហើយឥឡូវនេះអ្នកអាចដឹងថាទឹកគឺកំពុងនៅជុំវិញជង្គង់របស់អ្នក...វាចេះតែកើនឡើងតទៅទៀត ហើយពេលនេះអ្នកអាចដឹងថា វាស្ថិតនៅជុំវិញស្មារបស់អ្នក...ក៏ប៉ុន្តែថាមួយភ្លែតទឹកក៏កំពុងតែស្រកចុះម្ដងបន្តិចៗ។ បាទ/ចាស ឥឡូវនេះទឹក គឺនៅជុំវិញកជើងរបស់អ្នកម្ដងទៀតហើយ។ ឥឡូវវាក៏បានស្រកអស់ហើយដែរហើយអ្នកក៏អាចដឹងថាឥឡូវនេះផ្លូវគឺស្ថិតនៅក្រោមជើងរបស់អ្នកម្ដងទៀត។

ភ្លាមៗនោះអ្នកក៏បានឮសូរផ្គរលាន់ខ្យល់ក៏កាន់តែត្រជាក់។ ខ្យល់បក់ខ្លាំងឡើងៗ ហើយកាបូបរបស់អ្នកក៏កាន់តែធ្ងន់ឡើងៗ ។ ភ្លៀងក៏ចាប់ផ្ដើមធ្លាក់ ហើយអ្នកបានទទឹក។ ភ្លៀងកាន់តែខ្លាំង។ ចំណែកឯកាបូបរបស់អ្នកក៏ទទឹកភ្លៀងផងដែរ ហើយវាក៏កាន់តែធ្ងន់ថែមទៀតហើយអ្នកនៅតែតស៊ូទៅមុខទៀត។ អ្នកបានគិតថាវាពិតជាពិបាកណាស់ដើម្បីមើលអ្វីដែលនៅពីមុខរបស់អ្នក ដូច្នេះហើយអ្នកក៏បានលាដៃរបស់អ្នក។

ភ្លាមៗនោះ អ្នកក៏បានប៉ះនឹងជញ្ជាំងខ្ពស់មួយ។ តើអ្នកអាចចេញពីជញ្ជាំងនេះទៅផ្នែកម្ខាងទៀតដោយរបៀបណា? ពេលនោះអ្នកបានរកឃើញទ្វារមួយ ហើយក៏ព្យាយាមបើកវា។ អ្នក ក៏បានដើរចូលមកខាងក្នុង ហើយឥឡូវនេះអ្នកស្ថិតនៅក្នុងសួនច្បារមួយ។ តើអ្នកអាច ឃើញអ្វីខ្លះនៅក្នុងសួនច្បារ? តើវាជាសួនច្បារដ៏ធំ ឬតូចមួយ? តើមានរុក្ខជាតិកំពុងរីកលូតលាស់នៅទីនោះដែរឬទេ? តើមានសត្វបក្សាបក្សីដែរឬទេ? តើអ្នកមានបានឮពួកវាច្រៀងដែរឬទេ? អ្នកចាប់ផ្ដើមដើរ ជុំវិញសួនច្បារហើយធ្វើការរុករកមើលនៅទីនោះ។ ចំពោះភ្លៀងក៏បានឈប់ផងដែរ ហើយវាក៏មានកំដៅម្ដងទៀត។

រំពេចនោះ អ្នកបានប្រទះនឹងរណ្ដៅមួយនៅក្នុងដី។ វាជារណ្ដៅតូចមួយ ក៏ប៉ុន្តែវាមានទំហំធំល្មមសម្រាប់អ្នកចូលទៅខាងក្នុងវាបាន។ អ្នកដឹងថា រណ្ដៅនោះនឹងនាំអ្នកទៅកាន់កន្លែងមួយ ដែលអ្នកចង់ទៅ។ ប៉ុន្តែពេលដែលអ្នកចូលក្នុងរណ្ដៅនោះ អ្នកដឹងថាកាបូបអ្នក គឺធំជាងរណ្ដៅនោះ។

អ្នកក៏បានយករបស់របរទាំងអស់ចេញពីក្នុងកាបូបរបស់អ្នក ហើយអ្នកបានក្រលេកមើលរបស់ទាំងនោះ ។ អ្នកត្រូវជ្រើសរើសយករបស់តែមួយប៉ុណ្ណោះ ដើម្បីយកទៅជាមួយអ្នក ពេលចូលទៅក្នុងរណ្ដៅនោះ។ យកវាមក ហើយទុកឱ្យបានត្រឹមត្រូវ ហើយចាប់ផ្ដើមចូលទៅក្នុងរណ្ដៅ។

មានពន្លឺមួយនៅខាងមុខអ្នក។ លូនទៅមុខ ដោយសារតែអ្នកកំពុងនៅក្នុងរូង។ អ្នកក៏បាន ទៅដល់កន្លែងដែលជា គោលបំណងរបស់អ្នក ហើយឥឡូវនេះអ្នកបានស្ថិតនៅក្នុងរូងវេទមន្តរបស់ហនុមាន។ ប៉ុន្តែតើអ្នកមានអ្វីនៅក្នុងដៃរបស់អ្នក? វាជារបស់ដែលអ្នកបានយកចេញពីកាបូបរបស់អ្នកដូច្នេះអ្នកក្រោកឈរឡើងហើយយកវាចេញមកក្រៅ។

ឥឡូវនេះអ្នកអាចបើកភ្នែករបស់អ្នកបានហើយ!

? តើអ្នកមានអារម្មណ៍ដូចម្ដេចដែរ?

ឥឡូវនេះ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាដើរជុំវិញថ្នាក់រៀន ហើយធ្វើការចែករំលែកនូវអ្វី ដែលអ្នក មាននៅក្នុងដៃរបស់អ្នកជាមួយនឹងសិស្សទាំងអស់គ្នា។ ប្រាប់សិស្សទាំងអស់គ្នាថាវាគឺជារបស់អ្វីហើយហេតុអ្វីបានជាអ្នកជ្រើសយករបស់នេះមកជាមួយ។

បន្ទាប់ពីសិស្សចែករំលែកគ្នារួច។

- គ្រូឱ្យសិស្សអង្គុយទៅតាមកន្លែង ហើយបើកសៀវភៅរបស់ពួកគេ។ គ្រូឱ្យសិស្សគូររូបភាព ដែលគេកាន់មកជាមួយចូលក្នុងសៀវភៅរបស់ពួកគេរៀងៗខ្លួន។

● គ្រូសរសេរសំណួរខាងក្រោមនេះ នៅលើក្តារខៀនហើយប្រាប់សិស្សឱ្យចម្លងចូលក្នុងសៀវភៅរបស់ពួកគេ ៖

a) តើអ្នករកឃើញសកម្មភាពនេះដោយវិធីណា? តើវាពិបាកឬងាយស្រួល ហើយហេតុអ្វី?

b) តើអ្នកអាចនឹកឃើញនូវរបស់មួយចំនួនផ្សេងទៀត ដែលមាននៅក្នុងកាបូបរបស់អ្នកដែរ ឬទេ?

c) ហេតុអ្វីបានជាអ្នកជ្រើសរើសរបស់ ដែលអ្នកទើបតែគូរក្នុងសៀវភៅរបស់អ្នក មករក្សាទុក?

d) តើអ្នកមានបានរៀនអ្វីខ្លះទាក់ទងនឹងខ្លួនរបស់អ្នកផ្ទាល់ ពីសកម្មភាពនេះហើយដែលអ្នកមិនដែលធ្លាប់បានគិតពីមុនមក?

● គ្រូផ្តល់ឱ្យសិស្សនូវពេលវេលាមួយចំនួន ដើម្បីគិត និងសរសេរនូវចម្លើយរបស់ពួកគេ ហើយបន្ទាប់មក ឱ្យពួកគេចែករំលែកជាមួយអ្នកព្រមទាំងមិត្តរួមថ្នាក់ទាំងអស់គ្នាវិញ។ បង្កើតការពិភាក្សាមួយជុំវិញការរុករកពិភពខាងក្នុងខ្លួនរបស់សិស្ស ដោយផ្អែកទៅលើចម្លើយរបស់ពួកគេ។ ចូរប្រាកដថាការពិភាក្សាត្រូវមានបញ្ចូលគំនិត ដែលមាននៅក្នុងកំណត់ហេតុរបស់គ្រូ។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

● គ្រូសួរៈ តើអ្នកមានបានចាំល្បះមួយចំនួន ដែលយើងបានប្រើក្នុងសកម្មភាពទី១ ដែរឬទេ?

● គ្រូឱ្យសិស្សរកនឹកពីល្បះទាំងនោះ ហើយសរសេរវាលើក្តារខៀន។

តើចម្លើយរបស់ល្បះនីមួយៗផ្អែកទៅលើអ្វី? ឧទាហរណ៍ ៖ ចូរមើលល្បះនេះ ៖ "តើអ្នកសប្បាយរីករាយដែរទេ? "តើចម្លើយផ្អែកទៅលើអ្វី?វាអាស្រ័យទៅលើអារម្មណ៍របស់យើង ថាតើ យើងមានអារម្មណ៍ដូចម្តេចនៅពេលនោះ។ ដោយឡែកចំពោះល្បះនេះវិញ៖ "ក្មេងប្រុសគួរតែ ធ្វើការងារផ្ទះបន្ថែម"។ ល្បះនេះចម្លើយរបស់វា គឺអាស្រ័យទៅ លើគំនិតរបស់យើង ហើយគំនិត របស់យើងទាំងអស់នោះ ក៏អាស្រ័យទៅលើអ្វីដែលជឿជាក់ផងដែរ។

តើយើងទាំងអស់គ្នាមានអារម្មណ៍ដូចគ្នា នៅក្នុងពេលតែមួយ ដែរឬទេ?

តើយើងទាំងអស់គ្នាមានគំនិតដូចគ្នាដែរឬទេ?

● គ្រូឱ្យសិស្សទាំងអស់នៅក្នុងថ្នាក់ពិភាក្សានូវសំណួរខាងលើ។ បន្ទាប់មកធ្វើការពិនិត្យមើលល្បះនីមួយៗ ដែលចម្លើយរបស់វា អាស្រ័យទៅលើគំនិត (មើលឯកសារសម្រាប់សិស្ស)។ អានល្បះ ទាំងនោះ ហើយសិស្សពិភាក្សាគ្នាថាតើពួកគេយល់ស្រប ឬមិនយល់ស្រប។ ធ្វើការពិភាក្សា បែបនេះ នៅរាល់ល្បះនីមួយៗ។

👄 គ្រូប្រាប់សិស្ស អ្នកក៏អាចផ្លាស់ប្តូរចិត្តរបស់អ្នកបានផងដែរ អំពីល្បះនីមួយៗ ដោយអាស្រ័យ ទៅលើអ្វីដែលអ្នកបានឮថ្ងៃនេះនៅក្នុងថ្នាក់។

◈ តើអ្នកទាំងអស់គ្នាមានចាំសំណួរ ដែលយើងបានសរសេរនៅក្នុងសៀវភៅរបស់យើងដែរឬទេ បន្ទាប់ពីសកម្មភាពទី១នៅថ្ងៃនេះ?

តើពាក្យថាការអប់រំមានអត្ថន័យដូចម្តេចចំពោះអ្នកទាំងអស់គ្នា? តើវានិយាយអំពីការសិក្សាភាពពិតពីពិភពខាងក្រៅ ឬក៏ជាការសិក្សាអំពីពិភពខាងក្នុងនៃអារម្មណ៍ និងផ្លូវចិត្តរបស់យើង"?

👄 អ្នកទាំងអស់គ្នាអាចសរសេរចម្លើយចូលក្នុងសៀវភៅរបស់អ្នក ប្រសិនបើអ្នកចង់ ឬអ្នកគ្រាន់តែគិតពីចម្លើយទៅនឹងសំណួរនេះ ពីរបីនាទីក៏បាន។

● គ្រូសួរទៅថ្នាក់ទាំងមូល និងជ្រើសរើសសិស្សស្រី/ប្រុស ដើម្បីចែករំលែកចម្លើយរបស់ពួកគេ ជាមួយគ្នាមួយមិត្តរួមថ្នាក់ទាំងអស់ ប្រសិនបើពួកគេមានអារម្មណ៍រីករាយ ក្នុងការធ្វើបែបនោះ។

*អរគុណសិស្សទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកទាំងអស់ក្នុងពេលឆាប់ៗនេះ នៅក្នុងមេរៀនក្រោយទៀត។*

## ខ្លឹមសារសំខាន់

ការធ្វើដំណើរដែលមានការណែនាំ

● វា មានលក្ខណៈពិបាក ដើម្បីពិនិត្យមើលផ្នែកខាងក្នុងរបស់យើង ប្រសិនបើយើងមិន ធ្លាប់បានធ្វើពីមុន។
● ពួកយើងទាំងអស់គ្នា គឺមានលក្ខណៈខុសៗគ្នាទាំងអស់ ហើយអ្នកខ្លះ អាចឃើញថាវាមានភាពងាយស្រួល ក្នុងការពិនិត្យមើលផ្នែកខាងក្នុង ជាងមនុស្សមួយចំនួន។
● ការឆ្លុះបញ្ចាំង និងលទ្ធភាពក្នុងការនិយាយអំពីខ្លួនយើង គឺជាជំនាញមួយ ដែលយើងអាចបង្កើន និងសិក្សាវាបាន។
● ព្យាយាមនិយាយឱ្យបានច្បាស់ៗថា តើយើងមានអារម្មណ៍ដូចម្តេច ក៏ជាជំនាញមួយ ដែលនឹង ត្រូវបង្កើនក្រៅម៉ោង ជាមួយនឹងការអនុវត្ត។
● បើទោះបីជាយើងគិតថា យើងមិនបានរៀនអ្វីថ្មីអំពីខ្លួនយើងបន្ទាប់ពីការឆ្លុះបញ្ចាំងក៏ដោយ ក៏ជួនកាល យើងនឹងដឹងនៅពេលក្រោយថា នេះគឺជារឿងមួយថ្មីសម្រាប់អ្នក។
● វា អាចជាសកម្មភាពសប្បាយរីករាយក្នុងការស្វែងយល់ពីខ្លួនយើងថាជានរណា ប្រសិនយើងធ្វើវាក្នុងបរិកាសមួយ ប្រកបដោយសុវត្ថិភាព ហើយយើងជឿទុកចិត្តទៅនឹងមនុស្សដែលយើងធ្វើការជាមួយ។

ការឆ្លុះបញ្ចាំង

● ពួកយើងទាំងអស់គ្នា គឺខុសគ្នា ហើយក៏មានអារម្មណ៍ និងគំនិតខុសៗគ្នាផងដែរ នៅគ្រប់ពេលទាំងអស់។
● គំនិតរបស់យើងទាំងអស់គ្នាអាចត្រូវបានផ្លាស់ប្តូរផងដែរ ដោយអាស្រ័យទៅលើ អ្វីដែលយើង បានរៀនអំពីខ្លួនយើង និង រៀនពីគ្នាទៅវិញទៅមក។
● ការអប់រំ គឺមិនមែនត្រឹមតែជាការសិក្សាអំពីការពិត និងរូបរាង ដែលកើតចេញពីពិភពខាងក្រៅ នោះទេ។
● ការអប់រំ ក៏និយាយអំពីការសិក្សាពីពិភពខាងក្នុងរបស់យើង ហើយក៏អាចពន្យល់ពីពិភពនេះ ដោយមានការជឿជាក់ផងដែរ។
● យើងគ្រាន់តែអាចធ្វើការចែករំលែកនូវពិភពខាងក្នុងរបស់យើង ប្រសិនបើយើងរៀនស្តាប់ ដើម្បីបង្ហាញពីខ្លួនយើង ហើយក៏ដើម្បីគោរពគំនិតរបស់អ្នកដទៃផងដែរ។ ការរក្សាការសម្ងាត់ គឺជាការរក្សារឿងផ្ទាល់ខ្លួនទាំងអស់ ដែលបាននិយាយនៅក្នុងក្រុម គួរតែរក្សាការនិយាយនោះក្នុងក្រុមដដែល។
● កាលដែលយើងទាំងអស់គ្នាកំពុងតែសប្បាយរីករាយឬលេងល្បែងផ្សេងៗ គឺមិនមែនមានន័យថា យើងមិនរៀននោះទេ។ ការសិក្សាគឺជាវិធីផ្ទាល់ខ្លួនដែលយើងអាចរៀនតាមមធ្យោបាយផ្សេងៗគ្នា។ អាថ៌កំបាំង គឺជាការស្វែងរកវិធីណាមួយដែលសាកសមបំផុតសម្រាប់យើង។





តើខ្ញុំត្រូវឈរនៅល្បះមួយណា/តើខ្ញុំត្រូវជ្រើសរើសល្បះណាមួយ?

- ថ្ងៃនេះជាថ្ងៃមួយដ៏ស្រស់ស្អាត។ (អារម្មណ៍)
- ខ្ញុំមានអារម្មណ៍សប្បាយរីករាយនៅថ្ងៃនេះ។ (អារម្មណ៍)
- ខ្ញុំមានអារម្មណ៍ងងុយដេក។ (អារម្មណ៍)
- ខ្ញុំឃ្លាន។ (អារម្មណ៍)
- ក្មេងប្រុសគួរតែធ្វើការងារផ្ទះបន្ថែម។ (គំនិត)
- សកលវិទ្យាល័យ គឺសម្រាប់ក្មេងប្រុសរៀន មិនមែនក្មេងស្រីទេ។ (គំនិត)
- កិច្ចការផ្ទះ គឺសំខាន់ជាងការលេង។ (គំនិត)
- ស្ត្រីមិនអាចក្លាយជានាយកមន្ត្រីនៃប្រទេសមួយបានទេ។ (គំនិត)
- ការអប់រំ គឺមានសារៈសំខាន់ចំពោះក្មេងប្រុស និងស្រី។ (គំនិត)
- ការអប់រំ គឺនិយាយអំពីការសិក្សាការពិត និងពិភពខាងក្រៅ ដែលយើងកំពុងតែរស់ នៅ។ (គំនិត)
- ការសាកល្បង គឺជាមធ្យោបាយល្អបំផុតមួយ ដើម្បីធ្វើការសិក្សា។ (គំនិត)
- ខ្ញុំចូលចិត្តលេងល្បែងនៅសាលារៀន។ (អារម្មណ៍)
- យើងពិតជាមិនអាចរៀនបានច្រើនទេ ពីល្បែងទាំងអស់នោះ។ (គំនិត)
- ឥឡូវនេះអ្វីដែលយើងកំពុងធ្វើត្រូវ គឺជាល្បែងដ៏សប្បាយរីករាយមួយ។ (គំនិត)
- ឥឡូវនេះអ្វីដែលយើងកំពុងធ្វើត្រូវ គឺជាការសិក្សាមួយ។ (គំនិត)

---

តើខ្ញុំត្រូវឈរនៅល្បះមួយណា

- វាជាថ្ងៃមួយដ៏ស្រស់ស្អាត។ (អារម្មណ៍)
- ខ្ញុំមានអារម្មណ៍សប្បាយរីករាយនៅថ្ងៃនេះ។ (អារម្មណ៍)
- ខ្ញុំមានអារម្មណ៍ងងុយដេក។ (អារម្មណ៍)
- ខ្ញុំឃ្លាន។ (អារម្មណ៍)
- ក្មេងប្រុសគួរតែធ្វើការងារផ្ទះបន្ថែម។ (គំនិត)
- សកលវិទ្យាល័យ គឺសម្រាប់ក្មេងប្រុសរៀន មិនមែនក្មេងស្រីទេ។ (គំនិត)
- កិច្ចការផ្ទះ គឺសំខាន់ជាងការលេង។ (គំនិត)
- ស្ត្រីមិនអាចក្លាយជានាយកមន្ត្រីនៃប្រទេសមួយបានទេ។ (គំនិត)
- ការអប់រំ គឺមានសារៈសំខាន់ចំពោះក្មេងប្រុស និងស្រី។ (គំនិត)
- ការអប់រំ គឺនិយាយអំពីការសិក្សាការពិត និងពិភពខាងក្រៅ ដែលយើងកំពុងតែរស់ នៅ។ (គំនិត)
- ការសាកល្បង គឺជាមធ្យោបាយល្អបំផុតមួយ ដើម្បីធ្វើការសិក្សា។ (គំនិត)
- ខ្ញុំចូលចិត្តលេងល្បែងនៅសាលារៀន។ (អារម្មណ៍)
- យើងពិតជាមិនអាចរៀនបានច្រើនទេ ពីល្បែងទាំងអស់នោះ។ (គំនិត)
- ឥឡូវនេះអ្វីដែលយើងកំពុងធ្វើត្រូវ គឺជាល្បែងដ៏សប្បាយរីករាយមួយ។ (គំនិត)
- ឥឡូវនេះអ្វីដែលយើងកំពុងធ្វើត្រូវ គឺជាការសិក្សាមួយ។ (គំនិត

# មេរៀនទី ៦: តើខ្ញុំជានរណា?

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ហ្វឺត ឬក៏ដីស
- ក្ដារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត
- ខ្មៅដៃពណ៌

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- អភិវឌ្ឍចំណេះដឹងខ្លួនឯងលើបុគ្គលិកលក្ខណៈ គំនិត និងអារម្មណ៍ នៅក្នុងជីវិតរបស់ពួកគេ
- យល់ច្បាស់ពីខ្លួនរបស់ពួកគេ ហើយចែករំលែកនូវរឿងរ៉ាវជីវិតរបស់ពួកគេ ដោយកាន់តែមាន ភាពជឿជាក់។

## រំឭកមេរៀនចាស់ 🕑 ២៥ នាទី

◈ គ្រូសួរ "តើសិស្សទាំងអស់អាចចែករំលែកនូវអ្វី ដែលយើងបានរៀនកាលពីមេរៀនមុនបានទេ?"
គ្រូឱ្យសិស្សពីរបីនាក់មានប្រុសមានស្រី ឡើងចែករំលែកនូវគំនិតរបស់ពួកគេជាមួយនឹងមិត្តរួមថ្នាក់។

## ចំណងជើងមេរៀនទី ៦: តើខ្ញុំជានរណា?

## សេចក្ដីផ្ដើម

កាលពីមេរៀនមុន យើងក៏បានសិក្សាអំពីសារៈសំខាន់នៃការពិនិត្យមើលផ្នែកខាងក្នុងរបស់យើង ហើយក៏បានយល់ដឹងផងដែរថាការអប់រំ គឺមិនត្រឹមតែជាការសិក្សាអំពីការពិត និង ការជឿជាក់នៅពិភពខាងក្រៅនោះទេ ប៉ុន្តែវារួមបញ្ចូលទាំងការស្វែងរកថា តើយើងជានរណា។ ការពិតនិងការជឿជាក់ គឺគ្មានប្រយោជន៍ប្រសិនបើយើងមិនដឹងពីវិធីដើម្បីយកវាទៅអនុវត្តចំពោះខ្លួនយើង និងអ្វីដែលយើងចង់ធ្វើជាមួយនឹងជីវិតរបស់យើង! ក៏ប៉ុន្តែដើម្បីអនុវត្តចំណេះដឹងណាមួយ ដែលជួយយើង ឱ្យមានការអភិវឌ្ឍ គឺយើងត្រូវតែដឹងថាខ្លួនយើងជានរណាសិន!

● គ្រូប្រាប់សិស្សថ្ងៃនេះយើងទាំងអស់គ្នានឹងបន្តការធ្វើដំណើររុករកអំពីខ្លួនយើង ហើយយើងក៏នឹងបន្តស្វែងរកព័ត៌មានបន្ថែមថា តើយើងជានរណា។

● ចែកក្រដាស A4 ចំនួនមួយសន្លឹក និងខ្មៅដៃពណ៌មួយឱ្យសិស្ស (គ្រូអាចឱ្យសិស្សប្រើប្រាស់ក្រដាសសៀវភៅ និងខ្មៅដៃផ្ទាល់ខ្លួនរបស់សិស្ស)។

នៅលើក្រដាសមួយសន្លឹកនេះ គ្រូចង់ឱ្យអ្នកទាំងអស់គ្នាគូររូបរបស់អ្នក។ ចូរស្រមើស្រមៃថា អ្នកកំពុងតែមើល ទៅកញ្ចក់។ តើអ្នកបានឃើញអ្វីខ្លះ? នៅពេលអ្នកទាំងអស់គ្នាបានបញ្ចប់ការគូររូបភាព ចូរគិតអំពីព្រឹត្តិការណ៍សំខាន់ៗចំនួន៣នៅក្នុងជីវិតរបស់អ្នកដែលអ្នកមានមោទនភាព។សរសេរចំណុចទាំងនេះនៅពីក្រោមរូបគំនូដែលអ្នកបានគូរ ។

នៅពេលដែលសិស្សបានបញ្ចប់រួចរាល់ គ្រូប្រមូលរូបភាពគំនូររបស់ពួកគេ។ ចូរប្រាប់ពួកគេថា ពួកគេនឹងត្រូវមើលរូបគំនូរនេះម្តងទៀតនៅចុងបញ្ចប់នៃមេរៀននេះ ហើយត្រូវប្រាកដថា អ្នកបានធ្វើអ្វីមួយសម្រាប់ខ្លួនអ្នកផងដែរ!

◈ តើអ្នកទាំងអស់គ្នាមានសំណួរអ្វីចំពោះមេរៀនថ្ងៃនេះដែរទេ?

## សកម្មភាពសំខាន់ៗ

⏲ ៦០ នាទី



● សរសេរពាក្យថា "ខ្ញុំជានរណា?" នៅលើក្តារខៀន។

● គ្រូសួរៈ តើនេះគឺជាសំណួរងាយស្រួលដើម្បីឆ្លើយដែរឬទេ?
តើអ្នកគិតដូចម្តេចដែរ?តើអ្នកមានចម្លើយចំពោះសំណួរនេះដែរឬទេ?

● គ្រូឱ្យសិស្សទាំងអស់គ្នាចែករំលែកគំនិតរបស់ពួកគេ ហើយលើកទឹកចិត្តឱ្យពួកគេរៀបរាប់ពីខ្លួនគេតាមវិធីរៀងៗខ្លួន ដូចជាៈ ភេទ គ្រួសារ អ្វីដែលគេចូលចិត្ត និងអ្វីដែលគេមិនចូលចិត្តធ្វើ។ល។

●គ្រូប្រាប់សិស្សទាំងអស់ថា សកម្មភាពបន្តិចទៀតនេះ គឺនឹងជួយពួកគេឱ្យស្វែងយល់អំពីខ្លួនពួកគេជា មនុស្សប្រភេទណាឱ្យបានស៊ីជម្រៅ។ ដើម្បីធ្វើសកម្មភាពនេះបាន អ្នកត្រូវមានពេលវេលាគ្រប់គ្រាន់ ពេលវេលានៅស្ងៀមស្ងាត់ និងបរិយាកាសសុវត្ថិភាពមួយ។ យើងបានបង្កើត សកម្មភាពនេះនៅក្នុងថ្នាក់រៀនរបស់យើង។

●គ្រូចែកឯកសារសម្រាប់សិស្ស/ឯកសារបន្ថែម ៥.១ ដល់សិស្ស (ប្រសិនបើលោកគ្រូ/អ្នកគ្រូមិនអាចចម្លងក្រដាសនេះបាន អ្នកអាចចម្លងខ្លឹមសារដាក់លើក្រដាសផ្ទាំងធំ ហើយអាចឱ្យសិស្សចម្លងវាចូលក្នុងសៀវភៅរបស់ពួកគេ)។

នៅក្នុងសកម្មភាពនេះ អ្នកទាំងអស់គ្នាមានសំណួរមួយចំនួនដែលត្រូវឆ្លើយ ហើយក៏មានល្បះមួយចំនួនត្រូវបំពេញផងដែរ។ ខ្ញុំនឹងដើរជុំវិញអ្នកទាំងអស់គ្នាដើម្បីជួយ ប្រសិនបើមានអ្នកទាំងអស់គ្នាមានចម្ងល់ ។ ព្យាយាមឆ្លើយសំណួរដោយស្មោះត្រង់ចំពោះខ្លួនឯង។ អ្នកមិនចាំបាច់សរសេរចម្លើយចូលភ្លាមៗនោះទេ។ វាកាន់តែល្អ ប្រសិនបើអ្នកបានអានសំណួរ និងល្បះទាំងអស់មុន ហើយគិតអំពីអ្វីដែលអ្នកចង់សរសេរ។ បន្ទាប់មកចាប់ផ្តើមសរសេរចម្លើយចូល។ អ្នកទាំងអស់គ្នាមិនត្រូវចែករំលែកចម្លើយទាំងរបស់ពួកគេជាមួយនឹងអ្នកដទៃនោះទេ ប្រសិនបើអ្នកមិនចង់។ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ អ្នកត្រូវឆ្លើយចម្លើយពិតអំពីខ្លួនរបស់អ្នក ទៅនឹងសំណួរទាំងនេះ។ (ទុកពេល២០នាទី)

● គ្រូសួរៈ តើអ្នកទាំងអស់គ្នាបានរៀនអ្វីខ្លះពីសកម្មភាពនេះ? តើវាគួរឱ្យចាប់អារម្មណ៍ឬសំខាន់សម្រាប់អ្នកដែរឬទេក្នុងការស្វែងយល់ពីខ្លួនឯង? ហេតុអ្វី?
តើអ្នកមានអារម្មណ៍ដូចម្តេច នៅពេលដែលប្រាប់រឿងរបស់ខ្លួន ទៅអ្នកដទៃ?
តើអ្នកទាំងអស់គ្នាគិតថាការចំណាយពេលធ្វើការស្វែងយល់ពីជីវិតអារម្មណ៍និងគំនិតរបស់ខ្លួនអាចផ្តល់ប្រយោជន៍ដែរឬទេ? ហេតុអ្វី?
តើការស្គាល់ខ្លួនឯងជួយដល់ចំណងទំនាក់ទំនងរវាងអ្នក និងអ្នកដទៃដូចម្តេចខ្លះ?

● គ្រូឱ្យសិស្សរង្វេបនូវចំណុចសំខាន់ៗដែលទាក់ទង និងបន្ថែមនូវគំនិតដែលសិស្សមិនបានលើកឡើងក្នុងឯកសារបន្ថែម។ ចែកឯកសារបន្ថែម "ការស្គាល់ខ្លួនឯង" ឬឱ្យសិស្សចម្លងចំណុចសំខាន់ៗពីក្តារខៀន/ក្រដាសផ្ទាំងធំ ប្រសិនបើមិនមានឯកសារថតចម្លង។

**បញ្ចប់មេរៀន** ⌚ ១៥ នាទី

●គ្រូសួរៈ តើអ្នកទាំងអស់គ្នាមានចងចាំ តើយើងបានធ្វើអ្វីនៅពេលចាប់ផ្តើមមេរៀនេះឬទេ?គឺយើងទាំងអស់គ្នាបានគូររូបគំនូរអំពីខ្លួនរបស់យើងហើយសរសេរអំពីពេលវេលាមួយដែលធ្វើឱ្យយើងមានមោទនភាពនៅក្នុងជីវិតរបស់យើង។

●គ្រូប្រាប់សិស្សទាំងអស់គ្នាថា ឥឡូវនេះយើងនឹងចែករំលែកនូវចំណុចទាំងអស់នេះ ដោយធ្វើការព្យាយាមទាយថា តើរូបមួយណាត្រូវនឹងមនុស្សម្នាក់ណា។ អាចធ្វើការបង្ហាញនូវរូបភាពនីមួយៗម្តងមួយៗ ឬក៏ព្យួររូបភាពទាំងអស់នោះ ហើយឱ្យសិស្សទាំងអស់ដើរជុំវិញ និងទាយដោយរួមបញ្ចូលទាំងរូបភាពរបស់អ្នកផងដែរ!

⚲ តើអ្នកបានរៀនអ្វីខ្លះ អំពីនរណាម្នាក់ផ្សេងទៀតក្នុងថ្នាក់នៅថ្ងៃនេះ ដែលអ្នកមិនបានស្គាល់ពីមុនមក?

*អរគុណអ្នកទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកទាំងអស់ក្នុងមេរៀនក្រោយទៀត។*

# ខ្លឹមសារៈសំខាន់

● មេរៀននេះ គឺនិយាយអំពីអារម្មណ៍ទូទៅរបស់មនុស្សទាំងស្រី ទាំងប្រុស។ តួនាទីរបស់គ្រូ គឺត្រូវជួយសិស្សទាំងអស់គ្នា មានឱកាសបញ្ចេញអារម្មណ៍ដែលកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃក្នុងជីវិតរបស់ពួកគេ។

● ចងចាំថា នៅក្នុងមេរៀនមុន យើងទាំងអស់គ្នាបានពិភាក្សាគ្នាថា មនុស្សខ្លះចូលចិត្ត ហើយឃើញថាមានភាពងាយស្រួលក្នុងការបង្ហាញពីអារម្មណ៍របស់ពួកគេ ប៉ុន្តែអ្នកខ្លះមានការពិបាកក្នុងការធ្វើបែបនេះ។ ដូច្នេះ មនុស្សយើងទាំងអស់គ្នាសុទ្ធតែមានលក្ខណៈពិសេសខុសៗគ្នា ហើយភាពខុសគ្នានេះ វាជារឿងធម្មតា។ ការពិតនោះ គឺជាអ្វីដែលធ្វើឱ្យមានការធ្វើការងារជាមួយនឹងគ្នា ឱ្យកាន់តែមានការចាប់អារម្មណ៍!

● មើលត្រឡប់ទៅកាន់វិន័យ ដែលយើងបានបង្កើតឡើងកាលពីបីមេរៀនមុន។ រំឭកសិស្សអំពីវិន័យជាមូលដ្ឋាន តើវាមានសារៈសំខាន់ដូចម្តេចក្នុងកំឡុងពេលសិក្សាមេរៀននេះ។

● ចូរប្រាកដថា អ្នកដើរតួជាគំរូក្នុងការគោរពវិន័យជាមូលដ្ឋាននេះ។ ត្រូវសុភាពរាបសា យកចិត្តទុកដាក់ បង្ហាញការយល់ចិត្ត និងការគោរព។

● សំខាន់បំផុតនោះ គឺបង្ហាញការចាប់អារម្មណ៍។ សួរសិស្ស នៅពេលដែលពួកគេកំពុងធ្វើការចែករំលែកនូវរឿងរ៉ាវរបស់ខ្លួនពួកគេផ្ទាល់។

● ធ្វើការចង្អុលបង្ហាញថា ក្នុងមេរៀននេះ គឺមិនមែនដើម្បីបង្ហាញថា គេជា "មនុស្សល្អ" នោះទេ! ជាការពិតណាស់ យើងទាំងអស់គ្នា គឺសុទ្ធតែចង់ក្លាយទៅជាមនុស្សល្អ ហើយយើងក៏ការស្វែងរកនូវការយល់ស្របពីអ្នកដទៃផងដែរ។ ក៏ប៉ុន្តែក្នុងមេរៀននេះវិញ គឺមានបំណងឱ្យសិស្សទាំងអស់ មានភាពស្មោះត្រង់ចំពោះខ្លួនឯងនូវអ្វីដែលគេគិត និងមានអារម្មណ៍ មិនមែនព្យាយាមនិយាយដើម្បីបង្ហាញថា យើងជាមនុស្សល្អនោះទេ។ យើងក៏បានដឹងហើយផងដែរថា យើងទាំងអស់គ្នា គឺសុទ្ធតែជាមនុស្សល្អ។

● ការមានអារម្មណ៍អវិជ្ជមានចំពោះជីវិត ដូចជាខឹង ខ្លាច ក្រៀមក្រំ គឺជារឿងធម្មតានៅក្នុងជីវិត ហើយអារម្មណ៍ទាំងអស់នេះ គឺសុទ្ធតែជាអារម្មណ៍ធម្មតាដែលយើងទាំងអស់គ្នាមាន។ អ្វីដែលសំខាន់នោះគឺ ការទទួលស្គាល់អារម្មណ៍ និងកត់សម្គាល់ពីឥទ្ធិពលនៃអារម្មណ៍ទាំងអស់នោះ មកលើជីវិតនិងអាកប្បកិរិយារបស់យើង។

● តួនាទីរបស់គ្រូ គឺត្រូវឱ្យសិស្សពិភាក្សាគ្នាអំពីអារម្មណ៍អវិជ្ជមាននៅក្នុងបរិយាកាសមួយ ដែលមានសុវត្ថិភាព។ មិនត្រូវឱ្យសិស្ស មានអារម្មណ៍ថា ពួកគេកំពុងត្រូវបានស្តីបន្ទោស ចំពោះការគិត ឬការដែលគេមានអារម្មណ៍បែបនោះទេ។

● គ្រូត្រូវចេះប្រើសប្រាស់សំណួរប្រដេញ ដើម្បីជួយឱ្យសិស្សអាចបង្ហាញអារម្មណ៍របស់ពួកគេ។ ឧទាហរណ៍: ប្រសិនបើសិស្សទាំងអស់នាំគ្នានិយាយ "ខ្ញុំខ្លាចខុសណាស់"។ ចូរសួរពួកគេថា "តើការធ្វើខុសធ្វើឱ្យប្អូនមានអារម្មណ៍ដូចម្តេច?"។ ប្រើប្រាស់សំណួរទាំងអស់ ដើម្បីជីកសួរឱ្យកាន់តែស៊ីជម្រៅចូលទៅក្នុងបញ្ហាទាំងអស់នោះ។


របស់មួយដែលធ្វើឱ្យខ្ញុំ ខឹង គឺ...
ខ្ញុំមានអារម្មណ៍រំភើបនៅពេល...
តើអ្វីដែលអ្នក មិនសប្បាយ រីករាយ ឬមិនចូលចិត្តនៅក្នុង ជីវិតរបស់អ្នក
ខ្ញុំមានអារម្មណ៍ធុញថប់នៅ ពេល...
ខ្ញុំស្អប់វានៅពេល...
តើអ្វីដែលអ្នកសប្បាយ រីករាយ ឬ ចូលចិត្ត
របស់មួយ ដែលខ្ញុំចង់ឱ្យ អ្នកដទៃដឹងអំពីខ្លួនខ្ញុំ
របស់មួយដែលធ្វើអោយ ខ្ញុំខឹង គឺ...
ខ្ញុំសប្បាយរីកនៅ
ខ្ញុំឯកោនៅពេល...
ខ្ញុំមិនសប្បាយ រីករាយល់...

តើអ្វីដែលអ្នកចាត់ទុកថា ជាភាពខ្លាំងរបស់អ្នក? (ឧទាហរណ៍ ទេពកោសល្យ ការសម្រេចបានស្នាដៃ ជំនាញ សមត្ថភាព ។ល។)

---

---

---

តើអ្វីដែលអ្នកចង់បង្កើន ឬចង់ឱ្យកាន់តែពូកែខាងផ្នែកអ្វីមួយ?(ឧទាហរណ៍ ជំនាញ និងសមត្ថភាពដែលអ្នកខ្វះខាត ហើយអ្នកចង់មានវា។)

---

---

---

មេរៀនទី៥ : តើខ្ញុំជានរណា? ឯកសារចែកសិស្ស/ឯកសារបន្ថែម

<u>តើការយល់ដឹងដោយខ្លួនឯងអាចជួយខ្ញុំដោយរបៀបណា?</u>

ដោយជួយខ្ញុំឱ្យយល់ដឹងអំពីជីវិតរបស់ខ្ញុំ អំពីអ្វីដែលកើតឡើងចំពោះខ្ញុំ ការទំនាក់ទំនងដែលខ្ញុំមានជាមួយនឹងមិត្តភក្តិ និងក្រុមគ្រួសាររបស់ខ្ញុំ។

ដោយជួយខ្ញុំឱ្យយល់ដឹងអំពីអ្វី ដែលខ្ញុំគិត និងមានអារម្មណ៍ ហើយនឹងហេតុអ្វី បានជាខ្ញុំគិត និងមានអារម្មណ៍បែបនោះ។

ដោយជួយខ្ញុំឱ្យបានយល់ថា អ្វីដែលខ្ញុំគិត និងធ្វើ ព្រមទាំងមានអារម្មណ៍ គឺប៉ះ ពាល់មកលើខ្ញុំ និងមានឥទ្ធិពលមកលើរបៀបដែលខ្ញុំប្រព្រឹត្ត និងអ្វីដែលខ្ញុំធ្វើ។

ដោយជួយខ្ញុំឱ្យបានយល់ដឹងអំពីចរិកលក្ខណរបស់ខ្ញុំបានកាន់តែប្រសើរ ដែល នេះអាចជួយខ្ញុំអាចធ្វើការសម្រេចចិត្តអំពីជីវិត និងការទំនាក់ទំនងរបស់ខ្ញុំ ដែលសាកសម្បទៅនឹងប្រភេទនៃមនុស្សដែលខ្ញុំមាន។

ដោយជួយខ្ញុំអាចនិយាយ និងធ្វើការទំនាក់ទំនងបានច្បាស់នូវអារម្មណ៍ តម្រូវការ និងគំនិតរបស់ខ្ញុំ ដូច្នេះការទំនាក់ទំនងរបស់ខ្ញុំក៏អាចមានការរីកចម្រើនផងដែរ។

ដោយជួយខ្ញុំឱ្យបានយល់ដឹងអំពីអ្នកដទៃកាន់តែច្បាស់។ បើទោះបីជា យើងទាំង អស់គ្នាមានលក្ខណប្លែក និងខុសគ្នាក៏ដោយ ក៏មនុស្សយើងទាំងអស់គ្នា មានលក្ខណប្រហាក់ប្រហែលគ្នាគ្រប់គ្រាន់ សម្រាប់ឱ្យយើងធ្វើការសិក្សាពីអារម្មណ៍ និងចិត្តរបស់យើងឱ្យយល់បានកាន់តែច្បាស់ផងដែរ ។

# មេរៀនទី ៧: ការផ្លាស់ប្តូរអត្តចរិតផ្ទាល់ខ្លួន

🕑 រយៈពេលបង្រៀន ៖ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ហ្វឺត ឬក៏ដីស
- ក្តារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ពណ៌នាអំពីលក្ខណៈសម្បត្តិ និងចរិតលក្ខណៈផ្ទាល់ខ្លួន ដែលពួកគេស្គាល់នៅក្នុងខ្លួនរបស់ពួកគេផ្ទាល់។
- កំណត់លក្ខណៈសម្បត្តិ និង ចរិតលក្ខណៈ ដែលពួកគេចង់អភិវឌ្ឍ នៅក្នុងខ្លួនរបស់ពួកគេផ្ទាល់។

## រំឭកមេរៀនចាស់

🕑 ២៥ នាទី

● គ្រូសួរ"តើអ្នកអាចចែករំលែកនូវខ្លឹមសារសំខាន់ៗ ដែលអ្នកបានរៀនកាលពីមេរៀនមុនបានទេ?"

សួរទៅថ្នាក់ទាំងមូល និងជ្រើសរើសសិស្សប្រុសស្រី ពីរបីនាក់ ឡើងចែករំលែកនូវគំនិតរបស់ពួកគេជាមួយនឹងមិត្តរួមថ្នាក់ ។

## ចំណងជើងមេរៀនទី ៧: ការផ្លាស់ប្តូរចរិតផ្ទាល់ខ្លួន

### សេចក្តីផ្តើម

● គ្រូប្រាប់សិស្សកាលពីមេរៀនមុនយើងក៏បានសិក្សាអំពីសារៈសំខាន់នៃការស្គាល់ខ្លួនឯង។ យើងទាំងអស់គ្នាក៏បានរៀនពីការចែក រំលែកពីបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ការយល់ឃើញ ការគិត និងអារម្មណ៍របស់យើងជាមួយនឹងអ្នកដទៃ។ ពេលដែលយើងអនុវត្តចែករំលែកជាមួយអ្នកដទៃកាន់តែច្រើន ដូច្នេះភាពងាយស្រួលក៏កាន់តែកើតមានឡើង ហើយអភិវឌ្ឍន៍ខ្លួនយើងក្លាយជាមនុស្ស ដែលមានការទំនាក់ទំនងកាន់តែប្រសើរក្នុងសង្គម។ ឆ្លងតាមរយៈការចែករំលែករបស់យើងកាលពីមេរៀនមុនយើងទាំងអស់គ្នាក៏បានរៀននូវអ្វីថ្មីៗមួយចំនួនទៀតអំពីមិត្តរួមថ្នាក់របស់យើង និងអំពីខ្លួនខ្ញុំ គ្រូរបស់អ្នកផងដែរ ការធ្វើបែបនេះ អាចជួយយើងឱ្យយល់ពីគ្នាទៅវិញទៅមកកាន់តែប្រសើរ។

នៅថ្ងៃនេះ យើងនឹងបន្ត ធ្វើការកំណត់ និងពិភាក្សាគ្នាថា តើយើងជានរណា ហើយស្វែងរកមធ្យោបាយមួយ ដែលអាចធ្វើឱ្យយើងក្លាយទៅជាមនុស្សម្នាក់ដែលកាន់តែល្អជាងខ្លួនយើង ក្នុងពេលបច្ចុប្បន្ន។ ចូរចងចាំថា ដើម្បីធ្វើការបង្កើនចំណុចទាំងនេះបាន យើងចាំបាច់ត្រូវធ្វើការចែករំលែកបទពិសោធ ហើយដើម្បីធ្វើការចែករំលែកបាន យើងចាំបាច់ត្រូវមានភាពជឿជាក់រវាងគ្នាទៅវិញទៅមក។

● គ្រូរៀបចំសិស្សឱ្យធ្វើការងារជាគូៗ ដើម្បីសម្តែងតួដោយមានសិស្សម្នាក់ដើរតួជាសមាជិករបស់គ្រួសារឬមិត្តស្និទ្ធស្នាល ហើយចំណែកសិស្សម្នាក់ទៀត អាចដើរតួធ្វើជាខ្លួនឯងផ្ទាល់។ ឧទាហរណ៍៖ សូលីន អាចដើរតួជាឪពុក ហើយដៃគូរបស់គេម្នាក់ទៀតឈ្មោះ សម្បត្តិ អាចដើរតួធ្វើជាខ្លួនឯងផ្ទាល់។ សូលីន ត្រូវនិយាយពីអារម្មណ៍ និងការយល់ឃើញរបស់គេចំពោះ"កូនប្រុសគឺសម្បត្តិ"។ ពួកគេអាចនិយាយបានមួយបែបទៀត គឺគេនិយាយពីខ្លួនរបស់គេតាមរយៈតួអង្គ ឪពុក។ សម្បត្តិស្តាប់ហើយសួរសំណួរដើម្បីលើកទឹកចិត្តគេឱ្យនិយាយបន្ថែមទៀតតើគេយល់ ឃើញដូចម្តេចទៀត ចំពោះ "កូនប្រុសរបស់គាត់" ។ បន្ទាប់ពីសិស្សពីរនាក់បាន បញ្ចប់ការសម្តែង ពួកគេត្រូវធ្វើការប្តូរតួគ្នាសម្តែង។ ឥឡូវនេះ សម្បត្តិដើរតួជាសមាជិកម្នាក់ របស់គ្រួសារ។ ឧទាហរណ៍ អាចជាបងប្រុស ឬបងស្រី។ បន្ទាប់មកគាត់ត្រូវតែនិយាយអំពីខ្លួនរបស់គាត់ក្នុងនាមជាបងប្រុសឬបងស្រី។ បន្ទាប់ពីសិស្សបញ្ចប់ការសម្តែងហើយ គ្រូសួរសំណួរមួយចំនួនដូចខាងក្រោម៖
តើការលេងល្បែងនេះ អ្នកមានអារម្មណ៍ដូចម្តេចដែរ? តើអ្នកទាំងអស់គ្នាបានសិក្សាអ្វីខ្លះ ចំពោះវិធីដែលមនុស្សដទៃធ្វើការវិនិច្ឆ័យមកលើខ្លួនអ្នក?តើរាល់គំនិតទាំងអស់របស់អ្នកដទៃគឺសុទ្ធតែត្រឹមត្រូវឬយ៉ាងណា? តើវាមានការពិបាកដែរឬទេ ក្នុងការវិនិច្ឆ័យមកលើខ្លួនយើង? តើវាមានការពិបាកឬទេ ក្នុងការមើលខ្លួនយើងតាមរយៈកែវភ្នែករបស់អ្នកដទៃ?

គ្រូជុំរុញការពិភាក្សា ចំពោះសំណួរខាងលើទាំងអស់នេះ គ្រូអាចប្រើប្រាស់ព័ត៌មានពីកំណត់សម្គាល់សម្រាប់គ្រូដើម្បីជាជំនួយក្នុងការដឹកនាំការពិភាក្សាជាមួយសិស្ស។

? តើអ្នកទាំងអស់គ្នាមានសំណួរឬចម្ងល់អ្វីដែរឬទេ ទាក់ទងនឹងមេរៀនថ្ងៃនេះ?

## សកម្មភាពសំខាន់។ ⏲ ៦០ នាទី

● គ្រូសរសេរពាក្យថា "នរណាដែលល្អឥតខ្ចោះ?" នៅលើក្តារខៀន។
តើសិស្សទាំងអស់យល់ឃើញដូចម្តេចចំពោះឃ្លានេះ? តើអ្នកមានចម្លើយសម្រាប់សំណួរនេះដែរឬទេ?

● គ្រូបញ្ជាក់ប្រាប់សិស្សថា គ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ! សូម្បីតែអ្នកគ្រូ/លោកគ្រូរបស់អ្នកទាំងអស់គ្នា! យើងទាំងអស់គ្នា គឺសុទ្ធតែមានចំណុច ដែលយើងចូលចិត្តអំពីខ្លួនរបស់យើង និងចំណុចដែលមិនចូលចិត្តហើយចង់ធ្វើការផ្លាស់ ឬធ្វើវាឱ្យប្រសើរជាងមុន។
គ្រូបែងចែកសិស្សទៅជាក្រុមតូចៗ ដែលមានគ្នា៥នាក់។ អ្នកទាំងអស់គ្នា ត្រូវតែគិតរឿងដែលអ្នកពេញចិត្តចំពោះខ្លួនឯង ចំនួនពីរ ហើយចែករំលែករឿងនេះជាមួយ នឹងក្រុមរបស់អ្នក។ ឧទាហរណ៍: ខ្ញុំពេញចិត្តចំពោះ...
តើមានអ្នកណាអាចផ្តល់ជាឧទាហរណ៍បានឬទេ?
● បន្ទាប់មកឱ្យសិស្សម្នាក់ៗគិតពីចំណុចដែលគេចង់ផ្លាស់ប្តូរ ដូចជាទាក់ទងនឹង ទម្លាប់ អាកប្បកិរិយា ឬអារម្មណ៍របស់គេ ចំនួនពីរ។ ឧទាហរណ៍: ខ្ញុំចង់ធ្វើការផ្លាស់ប្តូរ...

តើមានអ្នកណាអាចផ្តល់ជាឧទាហរណ៍បានឬទេ?
● គ្រូផ្តល់ពេលវេលាឱ្យសិស្សទាំងអស់គិត និងពិភាក្សាគ្នា។ បន្ទាប់ពីគិតពីចម្លើយរួច កុំឱ្យសិស្សចែករំលែកនូវចម្លើយរបស់ពួកគេភ្លាមៗ។

ឥឡូវអ្នកទាំងអស់គ្នា ម្នាក់ៗត្រូវតែធ្វើការជ្រើសរើសចំណុចមួយក្នុងចំណោមចំណុចទាំងពីរ ដែលអ្នកចង់ធ្វើការផ្លាស់ប្តូរអំពីខ្លួនរបស់អ្នក។

● គ្រូឱ្យសិស្សរៀបចំជារូបតំណាង ដែលបង្ហាញនូវចំណុចមួយ ដែលគេចង់ធ្វើការផ្លាស់ប្តូរ។ ឧទាហរណ៍ ៖ ប្រសិនបើខ្ញុំចង់ផ្លាស់ប្តូររបៀប ដែលខ្ញុំខឹងជាមួយនឹងប្អូនប្រុសរបស់ខ្ញុំ ពេលនោះខ្ញុំអាចរៀបចំសិស្សដទៃទៀតបង្ហាញពីភាពភ័យខ្លាចឬក៏កំពុងយំឱ្យឈរនៅទីតាំងខឹង។ អ្នកដែលឈរនោះតំណាងប្អូនប្រុសរបស់ខ្ញុំ។(នេះគឺហេតុការណ៍កើតឡើងពិតប្រាកដរវាងប្អូនប្រុសរបស់អ្នក)

● គ្រូឱ្យសិស្សនៅស្ងៀមមួយឬពីរនាទី។ បន្ទាប់មកទៀត ឱ្យសិស្សរៀបចំរូបតំណាងថ្មី ដែលបង្ហាញពីរបៀបដែលគេចង់ផ្លាស់ប្តូរ។ ឧទាហរណ៍ ៖ រូបតំណាងដែលនៅស្ងៀមទីពីររបស់ខ្ញុំអាចជាមនុស្ស ដែលមានទឹកមុខញញឹម កំពុងតែលេងជាមួយប្អូន និងជួយគ្នាទៅវិញទៅមក។ នេះគឺជារបៀបដែលខ្ញុំចង់ធ្វើការផ្លាស់ប្តូរ ពីរបៀបដែលខ្ញុំធ្វើការទំនាក់ទំនងជាមួយនឹងបងប្អូនរបស់ខ្ញុំ។

● គ្រូសួរត្រឡប់ទៅសិស្សនូវសំណួរខាងក្រោម ដើម្បីបញ្ជាក់ថាសិស្សយល់នូវអ្វីដែលត្រូវធ្វើៈ

តើរូបតំណាងចំនួនប៉ុន្មាន ដែលអ្នកទាំងអស់គ្នា នឹងត្រូវបង្កើត?

តើរូបតំណាងទីមួយរបស់អ្នក នឹងត្រូវធ្វើការបង្ហាញអំពីអ្វី? (អាចជាអ្វីមួយអំពីខ្លួនខ្ញុំ ដែលខ្ញុំចង់ផ្លាស់ប្តូរ)

តើរូបតំណាងទីពីររបស់អ្នក នឹងត្រូវធ្វើការបង្ហាញអំពីអ្វី? (តើខ្ញុំអាចផ្លាស់ប្តូរបានដោយ របៀបណា?)

បន្ទាប់ពីរយៈពេល២០ ឬ៣០នាទី គ្រូបញ្ឈប់សកម្មភាពក្រុមសិន។ គ្រូឱ្យអ្នកស្ម័គ្រចិត្ត ឱ្យឡើងបង្ហាញរូបតំណាងទាំងពីររបស់ពួកគេ ទៅកាន់មិត្តរួមថ្នាក់ទាំងអស់។ ជម្រុញការជជែកពិភាក្សាជុំវិញរូបតំណាងដែលសិស្សបានបង្ហាញ ហើយលើកទឹកចិត្តដល់សិស្សដទៃៗទៀតក្នុងការសួរសំណួរផងដែរ។គ្រូអាចស្វែងរកគំនិតសំខាន់ៗបន្ថែមក្នុងសេចក្តីណែនាំរបស់គ្រូ។

● គ្រូធ្វើសេចក្តីសន្និដ្ឋានលើសកម្មភាព ដោយឱ្យសិស្សទាំងអស់គ្នាធ្វើជារូបតំណាងខ្លួនពួកគេផ្ទាល់ ពីអ្វីដែលគេពេញចិត្តចំពោះខ្លួនគេ។ អ្នកគ្រូ/លោកគ្រូ ក៏អាចចូលរួម បានផងដែរ។

● គ្រូឱ្យសិស្សទាំងអស់ទះដៃអបអរសារទរ។ យើងទាំងអស់គ្នា គឺមិនមែនសុទ្ធតែល្អែតខ្ចោះនោះទេ ប៉ុន្តែយើងនៅមានអ្វីៗជាច្រើនទៀត ដែលយើងពេញចិត្តចំពោះខ្លួនយើង!

**បញ្ចប់មេរៀន** ១៥ នាទី

● គ្រូប្រាប់សិស្សទាំងអស់ ឱ្យសរសេរសំណួរខាងក្រោមចូលក្នុងសៀវភៅរបស់ពួកគេ។

តើខ្ញុំអាចប្តូរខ្លួនរបស់ខ្ញុំទៅជានរណាបានឬទេ? តើអ្នកគិតថា អ្នកអាចផ្លាស់ប្តូរខ្លួនអ្នកទៅជានរណាផ្សេងទៀតបានដែរឬទេ? តើនរណាដែល ជាមនុស្សល្អបំផុត ដែលកំណត់ថា អ្នកគួរឬមិនគួរផ្លាស់ប្តូរខ្លួនរបស់អ្នក?

● គ្រូប្រាប់សិស្សថាៈ

យើងទាំងអស់គ្នា ប្រហែលជាមិនអាចធ្វើការផ្លាស់ប្តូរខ្លួនយើងទាំងស្រុង ទៅជានរណាផ្សេងបានទេ ក៏ប៉ុន្តែវាគឺសំខាន់សម្រាប់យើង ដែលត្រូវចងចាំថា យើងក៏អាចធ្វើការផ្លាស់ប្តូររបៀបដែលយើងធ្វើអ្វីមួយ ហើយនឹងរបៀបដែលយើងបញ្ចេញអាកប្បកិរិយាចំពោះអ្នកដទៃ។ វាក៏សំខាន់ផងដែរដែលត្រូវចងចាំថា អ្វីៗទាំងអស់ ដែលយើងចូលចិត្តអំពីខ្លួនរបស់យើងហើយនិងអ្វីដែលយើងសប្បាយចិត្តដូច្នេះយើងមិនចង់ធ្វើការផ្លាស់ប្តូរចំណុចនេះអំពីខ្លួនរបស់យើងបានទេ!ខ្លួនរបស់អ្នកផ្ទាល់គឺជាមនុស្សដែលល្អបំផុតដើម្បីធ្វើការកំណត់នូវអ្វីដែលនិយាយអំពីខ្លួនរបស់អ្នកដែលអ្នកចង់ធ្វើការផ្លាស់ប្តូរ និងអ្វីដែលអ្នកចូលចិត្តអំពីខ្លួនរបស់អ្នក។

 តើអ្នកទាំងអស់គ្នាអាចចងចាំបានទេនូវវិន័យជាមូលដ្ឋាន ដែលយើងបានបង្កើតរួមគ្នានៅក្នុងមេរៀនទី២? តើអ្នកអាចគិតនូវអ្វី ដែលអ្នកបានធ្វើនៅថ្ងៃនេះអំឡុងពេលរៀនមេរៀននេះ ដែលអ្នកចង់ធ្វើឱ្យខុសប្លែក ដោយអាស្រ័យទៅលើវិន័យមូលដ្ឋានទាំងអស់នេះ?

គិតអំពីសំណួរដែលអ្នកបានសរសេរចូលក្នុងសៀវភៅរបស់អ្នក ហើយក៏គិតអំពីអ្វីដែលយើងទើបតែបានពិភាក្សាគ្នានិងអំពីវិន័យមូលដ្ឋាន។ បន្ទាប់មកឆ្លើយនូវសំណួរទាំងនេះ។

- គ្រូផ្តល់ពេលវេលា ៥នាទី ក្នុងការឆ្លើយនូវសំណួរនេះ។ បន្ទាប់ពីសិស្សឆ្លើយរួច គ្រូហៅសិស្សស្ម័គ្រចិត្ត ប្រុស/ស្រី ពីរបីនាក់ឡើងចែករំលែកចម្លើយទៅមិត្តរួមថ្នាក់ទាំងអស់។

*អរគុណអ្នកទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកទាំងអស់គ្នាក្នុងពេលឆាប់ៗនេះ នៅក្នុងមេរៀនក្រោយ។*

# ខ្លឹមសារសំខាន់/សង្ខេប

តើខ្ញុំគិតថា ខ្ញុំជានរណា?

● សកម្មភាពនេះអាចត្រូវបានឆ្លើយតប ដោយសារតែសិស្សទាំងអស់គ្នា កំពុងត្រូវបានស្នើសុំឱ្យធ្វើការបង្ហាញពីខ្លួនរបស់ពួកគេ តាមរយៈខ្សែភ្នែករបស់អ្នកដទៃ។ បើទោះបីជា វាជួយពួកគេ ឱ្យគិតអំពីវិធីដែលអ្នកដទៃមើលទៅកាន់ពួកគេក៏ដោយ តែវាបានឆ្លុះបញ្ចាំងនូវអ្វី ដែលបានកើតមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ គ្រូត្រូវស្តាប់ដោយយកចិត្តទុកដាក់ហើយមិនត្រូវឆ្លើយតបបែបអវិជ្ជមានមកកាន់សិស្សនោះទេបើទោះបីជាអ្នកមានការភ្ញាក់ផ្អើលចំពោះអ្វីដែលអ្នកបានឮក៏ដោយ។ ចូរកុំនិយាយកាត់ឬក៏ធ្វើការរិះគន់ ធ្វើជាអ្នកស្តាប់ដល់ល្អរហូតដល់សិស្សបានបញ្ចប់នូវការបង្ហាញរបស់ពួកគេ។

● សិស្សទាំងអស់គ្នាប្រហែលបង្ហាញថា សកម្មភាពនេះពិបាកក្នុងការធ្វើ ក៏ប៉ុន្តែជារឿយៗវាមានភាពងាយស្រួលក្នុងការនិយាយអំពីខ្លួនរបស់អ្នកនៅពេលអ្នកកំពុងតែសម្តែងតួខុសៗគ្នា។ គ្រូជំរុញលើកទឹកចិត្តសិស្សឱ្យមានភាពស្មោះត្រង់និងបើកទូលាយ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន នៅពេលធ្វើការពណ៌នាអំពីខ្លួនរបស់ពួកគេ ។

●ជួនកាលយើងមានអារម្មណ៍ឬគិតថាមនុស្សមួយចំនួនកំពុងតែធ្វើការវិនិច្ឆ័យមកលើយើងប៉ុន្តែត្រូវចាំថាមិនមែនគ្រប់ការគិតរបស់យើងសុទ្ធតែត្រូវដូចគេគិតនោះទេ។ យើងគិតថាមនុស្សទូទៅមើលមកយើងនៅក្នុងផ្លូវវិជ្ជមាន ឬអវិជ្ជមានហើយយើងនៅតែមិនពេញចិត្តដោយសារយើងយល់ច្រឡំពីវា។ ជួនកាលយើងក៏គិតផងដែរថាទស្សនៈរបស់យើងមួយនេះ គឺត្រឹមត្រូវ បើទោះបីជាយើងមិនចូលចិត្តអ្វីដែលយើងបានឃើញក៏ដោយ! ដូច្នេះវា ពិបាកធ្វើការវិនិច្ឆ័យខ្លួនរបស់យើង សូម្បីតែពេលដែលយើងសម្តែងតួខុសៗគ្នា តែទោះជាយ៉ាងណាក៏វាមានប្រយោជន៍ក្នុងការធ្វើដូច្នោះព្រោះដោយសារតែ វាជួយយើងឱ្យស្វែងយល់ពីខ្លួនយើង ថាជានរណា។

ខ្ញុំចង់ផ្លាស់ប្តូរ អំពីខ្លួនរបស់ខ្ញុំ

● គ្រូរំឮកសិស្សជានិច្ចថា "គ្មាននរណាម្នាក់ ដែលល្អឥតខ្ចោះនោះទេ"។ យើងទាំងអស់គ្នា គឺសុទ្ធតែមានទម្លាប់ ឬអារម្មណ៍មួយចំនួនដែលយើងចង់ធ្វើការផ្លាស់ប្តូរ។ ការចម្រើនវ័យ ប្រកបដោយភាពសប្បាយរីករាយ គឺអាស្រ័យយ៉ាងច្រើនទៅលើ សមត្ថភាពរបស់យើងក្នុងការវិនិច្ឆ័យខ្លួនឯង។ យើងទាំងអស់គ្នាគឺសុទ្ធតែមានចំណុចដែលយើងពេញចិត្តចំពោះខ្លួនឯងនិងចំណុចដែលយើងមិនពេញចិត្តចង់ផ្លាស់ប្តូរឬចង់ឱ្យកាន់តែប្រសើរឡើងអំពីខ្លួនរបស់យើងផ្ទាល់ ។

●ជាការសំខាន់ណាស់សម្រាប់យើង ដើម្បីថយក្រោយមួយជំហាន និងក្រឡេកមកមើលខ្លួនរបស់យើង។វិធីនេះជួយឱ្យយើងអាចស្វែងរកអ្វីទាក់ទងនឹងខ្លួនរបស់យើង ដែលយើងចង់ធ្វើការផ្លាស់ប្តូរ។ អ្វីទាំងអស់នេះអាចជាចំណុចដែលធ្វើឱ្យយើងមិនសប្បាយចិត្ត ឬក៏ក្រៀមក្រំចំពោះអ្វីមួយ ឬក៏ធ្វើឱ្យមនុស្សដទៃទៀតមិនសប្បាយរីករាយ ឬក្រៀមក្រំ។

●វាមានសារៈសំខាន់ណាស់ ក្នុងការទទួលស្គាល់ចំណុច ដែលយើងចូលចិត្តអំពីខ្លួនរបស់យើង ហើយនិងចំណុចដែលយើងមិនពេញចិត្ត។ ការធ្វើបែបនេះគឺជាផ្នែកដ៏ធំមួយ ថាខ្ញុំជានរណា។

●វាកាន់តែល្អប្រសើរថែមទៀត ប្រសិនបើគ្រូចូលរួមគ្រប់សកម្មភាព/លំហាត់ តាមដែលអាចធ្វើទៅបាន។ ឧទ ហរណ៍ៈ លោកគ្រូ/អ្នកគ្រូ ចូលរួមចែករំលែកជាមួយនឹងសិស្សក្នុងថ្នាក់ទាំងអស់ នូវចំណុចដែលអ្នកចង់ស្ថាបនាខ្លួនឱ្យកាន់តែប្រសើរ។ ឧ. គ្រូចូលចិត្តអ្នកគោរពពេលវេលា ឬគ្រូចូលចិត្ត/ចង់ញុំារបស់ដែលមានជាតិផ្អែមតិច។

● កាន់តែប្រសើរជាងនេះ នៅចុងបញ្ចប់នៃមេរៀននេះ គ្រូគួរតែផ្តល់រូបភាពជាវិជ្ជមានសម្រាប់សិស្ស ដូចជាៈ ចំពោះការនិយាយអំពីចំណុចដែលវិជ្ជមាន ឱ្យសិស្សសម្តែងពីអ្វីដែលគេមានមោទភាពចំពោះខ្លួនគេ។

# មេរៀនទី ៨: ការបង្ហាញអារម្មណ៍

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ហ្វឺត ឬក៏ដីស
- ក្ដារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត

☼ លទ្ធផលរំពឹងទុក:

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ស្វែងយល់ពីអារម្មណ៍ពិបាកមួយចំនួន ដែលខ្លួនធ្លាប់ជួបប្រទះ
- កំណត់សកម្មភាពវិជ្ជមាន ដែលអាចជួយខ្លួនក្នុងការដោះស្រាយ អារម្មណ៍ពិបាកៗទាំងនោះ។

## រំឭកមេរៀនចាស់ 🕑 ២៥ នាទី

- គ្រូសួរ: "តើអ្នកអាចចែករំលែក ដែលអ្នកបានរៀនកាលពីមេរៀនមុនបានទេ?"
- គ្រូឱ្យសិស្សពីរបីនាក់ ធ្វើការចែករំលែកនូវគំនិតសំខាន់ៗកាលពីមេរៀនមុន ដល់មិត្តរួមថ្នាក់ ។

## ចំណងជើងមេរៀនទី ៨: ការបង្ហាញអារម្មណ៍

### សេចក្ដីផ្ដើម

- គ្រូប្រាប់សិស្សកាលពីមេរៀនមុន យើងបានចែករំលែក និងពិភាក្សាគ្នាអំពីអារម្មណ៍ និង គំនិតរបស់គ្នាទៅវិញទៅមក។ យើងក៏បានរៀនផងដែរថា តាមរយៈការចែករំលែកការគិតនិងអារម្មណ៍ទាំងនេះធ្វើឱ្យទំនាក់ទំនងរបស់យើងកាន់តែរឹងមាំ និងការជឿជាក់។ យើងបានសិក្សាបន្ថែមទៀតថា ការស្ដាប់ដែលមានប្រសិទ្ធភាព គឺជាការស្ដាប់ដោយមានការលើកទឹកចិត្តអ្នកដទៃឱ្យចែករំលែកអ្វីមួយ ហើយវាមិនមែនជាការវិនិច្ឆ័យ ឬប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីធ្វើឱ្យគេឈឺ ចាប់ខូចខាតនោះទេ។ ថ្ងៃនេះយើង នឹងបន្តស្វែងយល់អារម្មណ៍ពិបាកៗមួយចំនួនដែលធ្លាប់ជួបប្រទះ ហើយដែលធ្វើឱ្យយើងមានអារម្មណ៍មិនល្អ។

- គ្រូចែកសិស្សជាក្រុម ដែលក្រុមនីមួយៗមានគ្នា ៥ ទៅ ៦នាក់ ។ គ្រូចែកបណ្ណចំនួនមួយសន្លឹកដល់សិស្ស ដែល

សរសេរពាក្យបង្ហាញពីអារម្មណ៍ដូចជា៖ ខឹង ភ័យខ្លាច និងក្រៀមក្រំ...។ អាចមានក្រុមច្រើន ពិភាក្សាពាក្យដូចគ្នា។ ប្រាប់សិស្សទាំងអស់ កុំឱ្យបង្ហាញបណ្ណនេះទៅកាន់ក្រុមដទៃ។

● គ្រូឱ្យសិស្សក្រុមនីមួយៗ បង្កើតរូបតំណាងមួយ ដែលតំណាងឱ្យអារម្មណ៍ ដែលមាននៅលើបណ្ណ។ នៅពេលដែលគ្រូទះដៃ២ដង គ្រូឱ្យក្រុមនីមួយៗសម្តែងរូបតំណាងទាំងនោះ ហើយត្រូវនៅឱ្យស្ងៀម។

● គ្រូទុកពេលឱ្យសិស្ស ១០នាទី ក្នុងការរៀបសម្តែងរូបតំណាងរបស់ពួកគេ។ បន្ទាប់ពីសិស្សរៀបចំរួច គ្រូទះដៃ ២ ដង។ បន្ទាប់មកឱ្យសម្តែងអារម្មណ៍ ដែលមាននៅលើបណ្ណរបស់ខ្លួន ម្តងមួយក្រុមៗ ហើយក្រុមដទៃទៀតធ្វើជាអ្នកសង្កេតហើយទាយថាតើរូបតំណាងនោះតំណាងឱ្យអារម្មណ៍ដូចម្តេច។

បន្តធ្វើដូច្នេះរហូតដល់ក្រុមនីមួយៗ មានឱកាសដើម្បីបង្ហាញរូបតំណាងរបស់ពួកគេ ហើយឱ្យសិស្សដទៃទៀតទស្សន៍ទាយ។ ចូរទះដៃសម្រាប់ក្រុមនីមួយៗ។

● គ្រូសួរៈ តើអ្នកទាំងអស់គ្នាមានសំណួរអ្វីទេ ចំពោះមេរៀននៅថ្ងៃនេះ?

## សកម្មភាពសំខាន់។ 🕑៦០ នាទី

● គ្រូសួរៈតើអារម្មណ៍ទាំង៣ ដែលយើងបានពិភាក្សានៅក្នុងចំណុចដំបូងមានអ្វីខ្លះ?(ខឹង ភ័យខ្លាច និងក្រៀម ក្រំ)

● គ្រូៈ សរសេរអារម្មណ៍ទាំងអស់នេះនៅផ្នែកខាងលើនៃក្រដាសផ្ទាំងធំ ដោយបែងចែកជា៣ជួរ។ អារម្មណ៍មួយស្ថិតនៅក្នុងជួរនីមួយៗ។

●គ្រូសួរៈ តើមាននរណាខ្លះ ធ្លាប់មានអារម្មណ៍បែបនេះនៅក្នុងជីវិតរស់នៅរបស់ខ្លួនដែរឬទេ? តើមាននរណាចង់មានអារម្មណ៍ទាំងនេះដែរឬទេ?

●គ្រូពន្យល់សិស្សទាំងអស់ថា អារម្មណ៍ទាំងនេះជាការរំជួលចិត្ត ពិបាកចិត្តរបស់យើង ហើយយើងមុខជាមិនចង់មានអារម្មណ៍បែបនេះឡើយ ប៉ុន្តែទោះជាយ៉ាងណាអារម្មណ៍ទាំងនេះជាអារម្មណ៍ធម្មតាដែលមនុស្សគ្រប់គ្នាមានវាជាផ្នែកមួយនៃជីវិតរបស់យើង ហើយយើងចាំបាច់ត្រូវយល់ពីអារម្មណ៍ទាំងនេះ។ យើងនឹងនាំគ្នាពិភាក្សាពីអារម្មណ៍ទាំង អស់នេះម្តងមួយៗ ក៏ប៉ុន្តែដំបូងចូរចាប់ផ្តើមជាក្រុមជាមួយនឹងអារម្មណ៍ ខឹងជាមុនសិន។

● គ្រូសួរៈតើមានស្ថានភាពអ្វីខ្លះ ដែលបង្កឱ្យមនុស្សមានអារម្មណ៍ខឹង? តើអ្នកណាខ្លះអាចផ្តល់ជាឧទាហរណ៍បាន? (ឱ្យសិស្សផ្តល់មូលហេតុផ្សេងៗគ្នាមួយចំនួន ដែលបង្កឱ្យមានអារម្មណ៍ខឹង ដូចជាដែលអាចកើតចេញពីផ្ទះ ឬក៏ស្ថានភាពណាមួយជាមួយនឹងមិត្តភក្តិ ឬក៏នៅឯសាលារៀន "នៅពេលគ្រូស្តីបន្ទោសឱ្យខ្ញុំនៅមុខនរណាម្នាក់ធ្វើឱ្យខ្ញុំមានអារម្មណ៍មិនល្អ"។)

● គ្រូសួរៈ តើនៅពេលដែលមនុស្សខឹង ពួកគេជ្រើសរើសធ្វើអ្វីខ្លះ? តើពួកគេអាចមានអាកប្បកិរិយាដូចម្តេចខ្លះ ? (ប្រាប់សិស្សថា៖ អ្នកគ្រូ/លោកគ្រូ ក៏ចង់ដឹងគំនិតពីអ្នកទាំងអស់គ្នា។)

ពេលដែលសិស្សទាំងអស់គ្នាកំពុងតែចែករំលែកគំនិតរបស់ពួកគេគ្រូសរសេរចម្លើយទាំងនោះដាក់ខាងក្រោមជួរនៃពាក្យ ខឹង ដែលមាននៅលើក្រដាសផ្ទាំងធំ។ (ចម្លើយអាចមានដូចជា៖ ស្រែកខ្លាំងៗដាក់គេ, ដើរចេញទៅឱ្យឆ្ងាយ ឬក៏ទៅកន្លែងណាមួយស្ងប់ស្ងាត់និងព្យាយាមសម្រួលអារម្មណ៍, ជជែកជាមួយមិត្តភក្តិរបស់អ្នក, សង្កត់អារម្មណ៍ឱ្យស្ងប់ ហើយព្យាយាមបំភ្លេចចោលនូវអ្វីដែលបានកើតឡើង, ពិភាក្សាជាមួយអ្នកដែលបានធ្វើឱ្យខ្លួនខឹង តាមសម្រួលដើម្បីស្វែងយល់ពីស្ថានការណ៍។ល។)

● គ្រូសួរៈតើមានផលវិបាកចេញពីការប្រព្រឹត្តនេះដែរឬទេ? អ្វីខ្លះ?(សំដៅទៅលើបញ្ជីដែលមាននៅក្នុងក្រដាផ្ទាំងធំ)

តើយើងអាចបែងចែកការប្រព្រឹត្តនៅលើបញ្ជីរបស់យើងបានដែរឬទេ? ឧទាហរណ៍ៈ តើសកម្មភាពណាមួយដែលជួយយើងឱ្យមានអារម្មណ៍កាន់តែល្អ ហើយសកម្មភាពនោះមិនធ្វើឱ្យខ្លួនឯង និងអ្នកដទៃឈឺចាប់?

ពេលដែលសិស្សទាំងអស់ កំពុងកំណត់សកម្មភាពដែលមិនប៉ះពាល់ដល់ដល់ខ្លួនឯង និងអ្នកដទៃនៅលើក្រដាសផ្ទាំងធំ គ្រូគូសរង្វង់ជុំវិញសកម្មភាពនោះ។ (ប្រសិនបើសិស្សជ្រើសរើស "ការសង្កត់អារម្មណ៍ ឬបំភ្លេចចោល" ជាសកម្មភាពមួយដែលមិនប៉ះពាលដល់ខ្លួនឯងនិងអ្នកដទៃចូរពន្យល់សិស្សថា នៅពេលដែលយើងប្រានចោល អារម្មណ៍ ឬអ្វី មួយចោល នោះមិនមែនមានន័យថា យើងបានដោះស្រាយជាមួយវារួចហើយនោះទេ។ អារម្មណ៍ នឹងកើតឡើងម្តង ទៀតនៅពេលក្រោយ ព្រោះមិនទាន់មានដំណោះស្រាយចំពោះស្ថានភាពនោះនៅឡើយ។)

● គ្រូសួរៈ តើយើងអាចហៅសកម្មភាពដែលយើងអាចធ្វើបាន ហើយមិនប៉ះពាល់ដល់ខ្លួនឯងនិងអ្នកដទៃថាជាសកម្មភាពយ៉ាងដូចម្តេច? (ជាសកម្មភាពវិជ្ជមាន)

● គ្រូសរសេរពាក្យថា សកម្មភាពវិជ្ជមាននៅលើក្តារខៀន ហើយនិងពាក្យស្លោកមួយទៀត "កុំឆ្លើយតបក្នុងលក្ខណៈសងសឹក"។

● គ្រូសរសេរសំណួរខាងក្រោមនៅលើក្តារខៀនៈ

ក) តើស្ថានការណ៍អ្វីដែលបណ្តាលឱ្យប៉ះពាល់ដល់អារម្មណ៍ ដែលអ្នកកំពុងតែផ្តោត ទៅលើ?

ខ) តើប្រភេទសកម្មភាពអ្វីខ្លះ ដែលមនុស្សធ្វើ នៅពេលដែលពួកគេមានអារម្មណ៍ ដូច្នោះ?

គ) តើសកម្មភាពទាំងអស់នេះ មួយណាដែលជាសកម្មភាពវិជ្ជមាន? គូសរង្វង់ជុំវិញសកម្មភាពនោះ។

● គ្រូបែកចែកសិស្សក្នុងថ្នាក់ជាពីរក្រុមតូចៗ។ ពាក់កណ្តាលនៃក្រុមតូចនេះនឹងឆ្លើយសំណួរអំពី ភាពភ័យខ្លាច ហើយពាក់កណ្តាលផ្សេងទៀត ពិភាក្សាអំពីអារម្មណ៍ក្រៀមក្រំ។ គ្រូពន្យល់ថា ពួកគេចាំបាច់ត្រូវធ្វើបទបង្ហាញអ្វីដែលពួកគេបានពិភាក្សា។ គ្រូត្រួតពិនិត្យការយល់ដឹងអំពីកិច្ចការនេះ។

● គ្រូផ្តល់ក្រដាសផ្ទាំងធំ ដែលជាសម្ភារៈសម្រាប់សិស្ស និងហ្វឺត ប៊ិក ហើយប្រាប់ក្រុមទាំងអស់ឱ្យចាប់ផ្តើមឆ្លើយសំណួរទាំងអស់នោះ។

បន្ទាប់ពីពួកគេបានបញ្ចប់ គ្រូឱ្យតំណាងក្រុមធ្វើបទបង្ហាញអំពីអារម្មណ៍ភ័យខ្លាច ឬក្រៀមក្រំ។ ប្រសិនបើក្រុមដទៃទៀតមានគំនិតដែលត្រូវបន្ថែម ពួកគេអាចបន្ថែមបាន។

● គ្រូបញ្ចប់សកម្មភាពដោយសង្ខេបចំណុចសំខាន់ៗ ដែលគ្រូនឹងមើលនៅក្នុងសេចក្តី ណែនាំសម្រាប់គ្រូ។

**បញ្ចប់មេរៀន** ១៥ នាទី

● គ្រូឱ្យសិស្សទាំងអស់អង្គុយក្នុងរង្វង់ជាមួយគ្នា។ នៅថ្ងៃនេះយើងទាំងអស់គ្នាក៏បានសិក្សាអំពីសកម្មភាពវិជ្ជមាន ហើយយើងនឹងបញ្ចប់ជាមួយនឹងសកម្មភាពវិជ្ជមានផងដែរ។

● គ្រូសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

១) ប្រសិនបើខ្ញុំខឹង...ខ្ញុំ...

២) ប្រសិនបើខ្ញុំមានអារម្មណ៍ភ័យខ្លាច...ខ្ញុំ...

៣) ប្រសិនបើខ្ញុំក្រៀមក្រំ...ខ្ញុំ...

យើងនឹងជួយគ្នាឱ្យមានការទាក់ទងទៅនឹងអារម្មណ៍ដែលពិបាកទាំងអស់នេះ ក៏ប៉ុន្តែគ្រាន់តែជាអារម្មណ៍ធម្មតាក្នុងមធ្យោបាយវិជ្ជមានមួយ។

● ជ្រើសរើសសិស្ស ដើម្បីចាប់ផ្តើមអនុវត្តសកម្មភាព។ គ្រូនិយាយល្បះទីមួយឱ្យបានឮៗហើយឱ្យឈប់នៅពេលដែលនិយាយពាក្យថាខឹងរួច។ បន្ទាប់មក បន្តល្បះជាមួយនឹងពាក្យថា "គួរតែ" ហើយបន្ទាប់មកបំពេញល្បះនោះជាមួយនឹងសកម្មភាពវិជ្ជមាន។ ហើយបន្ទាប់មកគ្រូចាប់ផ្តើមជាមួយល្បះថ្មីមួយបន្ទាប់ទៀត ហើយសិស្សដែលនៅជិតបំពេញល្បះនោះជាមួយនឹងសកម្មភាពវិជ្ជមាន។សិស្សទាំងអស់ត្រូវជៀសវាងការនិយាយជាន់គ្នាទៅនឹងអ្វីដែលសិស្សដទៃបាននិយាយរួច ដូច្នេះបំណិនស្តាប់ គឺពិតជាសំខាន់ណាស់!

កុមារទី ១៖ ប្រសិនបើខ្ញុំខឹង...

កុមារទី ២៖ អ្នកគួរតែគិតអំពីមូលហេតុដែលធ្វើឱ្យអ្នកមានអារម្មណ៍ដូច្នោះ។ ប្រសិនបើខ្ញុំ ភ័យខ្លាច...

កុមារទី ៣៖ អ្នកគួរតែនិយាយទៅកាន់នរណាម្នាក់អំពីភាពភ័យខ្លាចរបស់អ្នក។ ប្រសិនបើខ្ញុំក្រៀមក្រំ...

កុមារទី ៤៖ អ្នកគួរតែគិតអំពីរឿងដែលសប្បាយៗនៅក្នុងជីវិតរបស់អ្នក។ ប្រសិនបើខ្ញុំខឹង...

កុមារទី ៥៖ អ្នកគួរតែ...

ហើយបន្តបែបនេះរហូតដល់គ្រូត្រឡប់ទៅកាន់កុមារទី១ ដែលជាអ្នកបានចាប់ផ្តើម ហើយក៏ជាអ្នកដែលឥឡូវនេះគួរតបំពេញល្បះ។

*អរគុណអ្នកទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកទាំងអស់នៅក្នុងពេលឆាប់ៗនេះនៅមេរៀនបន្ទាប់។*

# ខ្លឹមសារសំខាន់

គោលបំណងនៃមេរៀននេះ គឺដើម្បីជួយមនុស្សវ័យក្មេងឱ្យមានការរីកចម្រើន និង មានទំនាក់ទំនងជាមួយនឹងអារម្មណ៍តាមវិធីដែលពោរពេញទៅដោយការរីកចម្រើន។

● មនុស្សវ័យក្មេងទាំងអស់ត្រូវដឹងថា ការមានអារម្មណ៍ពិបាក អវិជ្ជមានដូចជាអារម្មណ៍ ភ័យខ្លាច ខឹង ឬក្រៀមក្រំ គឺជារឿងធម្មតាក្នុងជីវិតរស់នៅរបស់មនុស្ស។

● អារម្មណ៍របស់យើង គឺមានឥទ្ធិពលយ៉ាងខ្លាំងមកលើជីវិតរបស់យើង ដូចជាទៅលើការសម្រេចចិត្ត និងរបៀបពីការប្រព្រឹត្តរបស់យើង។ ការស្គាល់អំពីអារម្មណ៍របស់យើង និងការនិយាយចេញពីអារម្មណ៍ទាំងនោះបាន គឺវាជួយឱ្យយើងសម្រេចចិត្តបានកាន់តែល្អប្រសើរ ហើយធ្វើអ្វីមួយប្រកបដោយគិតពិចារណា។ ប្រសិនបើយើងប្រាប់មនុស្សវ័យក្មេងថា ពួកគេមិនគួរបង្ហាញអារម្មណ៍របស់ពួកគេ ឬក៏សម្តែង អារម្មណ៍ នោះពួកគេនឹង មិនមានឱកាស ដើម្បី បង្កើននិងរីកចម្រើនឡើង ហើយ នឹងរៀនគ្រប់គ្រងអារម្មណ៍របស់ពួកគេនៅ ក្នុងមធ្យោបាយ វិជ្ជមាន មួយបានឡើយ។



● ជាការត្រឹមត្រូវ ដែលយើងមានអារម្មណ៍ខឹង ក៏ប៉ុន្តែវាមិនត្រឹមត្រូវនោះទេក្នុងការយក កំហឹងទាំងនោះមកបញ្ចេញ លើអ្នកដទៃ ឬក៏ធ្វើឱ្យអ្នកដទៃមានការឈឺចាប់។ វាជារឿងធម្មតា ក្នុងការមានអារម្មណ៍ក្រៀមក្រំ ប៉ុន្តែកុំឱ្យភាពក្រៀមក្រំទាំងនេះ នាំអ្នកឱ្យប្រព្រឹត្តសកម្មភាពបំផ្លាញខ្លួនឯង និងអ្នកដទៃ។

● វាមានសារៈសំខាន់ណាស់ ក្នុងការទទួលស្គាល់ថា តើយើងកំពុងមានអារម្មណ៍យ៉ាងដូចម្ដេច និយាយវាចេញ ហើយរកវិធីក្នុងការដោះស្រាយជាមួយនឹងអារម្មណ៍ទាំងនោះ។

●វាកាន់តែល្អថែមទៀត ប្រសិនបើគ្រូអាចពិភាក្សាមេរៀននេះ ជាមួយនឹងគ្រូដទៃទៀត មុនពេលបង្រៀនដល់សិស្ស។ លោកគ្រូ/អ្នកគ្រូក៏អាចសាកល្បងមេរៀននេះជាមួយនឹងមិត្តរួមការងារ មុនអនុវត្តបង្រៀនជាមួយនឹងសិស្សនាំឱ្យលោកគ្រូ/អ្នកគ្រូមានអារម្មណ៍កាន់តែមានភាពជឿជាក់លើការពិភាក្សាចំពោះបញ្ហាទាំងអស់នេះ។ ជាងនេះទៅទៀតជួយឱ្យអ្នកបានឆ្លងកាត់នូវដំណើរការសិក្សាដូចគ្នាទៅនឹងសិស្សរបស់អ្នក។

● ចំណុចសំខាន់ក្នុងមេរៀននេះ គឺថាសិស្សគ្រប់គ្នាត្រូវទទួលស្គាល់នូវអារម្មណ៍ពិបាកឬអវិជ្ជមានរបស់ខ្លួន ហើយត្រូវដោះស្រាយជាមួយនឹងអារម្មណ៍អវិជ្ជមានឬពិបាកៗទាំងនោះ នៅពេលណាមួយក្នុងជីវិតរបស់ពួកគេ ។ អារម្មណ៍ទាំងអស់នេះ គឺអាចបណ្តាលឱ្យយើង ធ្វើសកម្មភាពអ្វីមួយឱ្យកាន់តែអាក្រក់ និងមិនល្អ។ ដូច្នេះយើងត្រូវសិក្សាអំពីទង្វើវិជ្ជមាន ដែលមិនធ្វើឱ្យខ្លួនឯង និងអ្នកដទៃទទួលការឈឺចាប់ ហើយក៏ធ្វើឱ្យយើងមានអារម្មណ៍កាន់តែល្អ។

# មេរៀនទី ៩: ការគ្រប់គ្រងអារម្មណ៍

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)។

📖 សម្ភារឧបទេស/ធនធានដែលត្រូវការ

- ហ្វឺត ឬក៏ដីស
- ក្ដារខៀនពណ៌ស ឬពណ៌ខ្មៅ

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ដឹងយល់ពីអារម្មណ៍ពិបាកៗមួយចំនួនដែលយើងធ្លាប់ជួបប្រទះ
- ដឹងសកម្មភាពវិជ្ជមាន ដែលអាចជួយយើងក្នុងការដោះស្រាយនូវអារម្មណ៍ពិបាកៗទាំងនោះ

## រំឭកមេរៀនចាស់ 🕑 ២៥ នាទី

- គ្រូសួរៈ "តើអ្នកអាចចែករំលែក នូវអ្វីដែលបានរៀនកាលពីមេរៀនមុនបានទេ?"
- គ្រូឱ្យសិស្សពីរបីនាក់ ធ្វើការចែករំលែកនូវគំនិតសំខាន់ៗកាលពីមេរៀនមុន ដល់មិត្តរួមថ្នាក់ ។

## ចំណងជើងមេរៀនទី ៩: ការគ្រប់គ្រងអារម្មណ៍

### សេចក្ដីផ្ដើម

● គ្រូប្រាប់សិស្សកាលពីមេរៀនមុន យើងមានឱកាសពិភាក្សាពីអារម្មណ៍ភ័យខ្លាច ខឹង និងក្រៀមក្រំ។ យើងក៏បាន ជជែកគ្នាទៀតថាអារម្មណ៍ទាំងនេះជាអារម្មណ៍ធម្មតាដែលមនុស្សគ្រប់គ្នាតែងតែជួបប្រទះហើយយើងក៏បានពិភាក្សា គ្នាផងដែរពីវិធីផ្សេងៗ ដើម្បីដោះស្រាយជាមួយអារម្មណ៍ពិបាកទាំងនេះ ហើយវាសំខាន់ណាស់ក្នុងការស្វែងរក សកម្មភាពវិជ្ជមានក្នុងការដោះស្រាយជាមួយនឹងអារម្មណ៍ទាំងនេះដោយមិនធ្វើឱ្យអ្នកដទៃ និងខ្លួនឯងឈឺចាប់ហើយក៏ កាន់តែធ្វើ ឱ្យយើងមានអារម្មណ៍ធូរស្រាលផងដែរ។ ថ្ងៃនេះយើងនឹងបន្តស្វែងរកអារម្មណ៍ពិបាកៗទាំងនេះ ហើយស្វែងរក វិធី ដើម្បី គ្រប់គ្រងអារម្មណ៍ទាំងនោះផងដែរ។

● គ្រូ ដើរជុំវិញ ហើយដាក់ក្រដាស A4 ពណ៌ចំនួនមួយសន្លឹក និងខ្មៅដៃពណ៌នៅលើតុ។

● គ្រូសរសេរនៅលើក្តារខៀន នូវផ្នែកទាំង៣របស់អារម្មណ៍ ៖
ក) ពេលមិនសប្បាយ/ពេលសប្បាយ
ខ) ពេលមួយដែលខ្ញុំខឹង/ ពេលមួយដែលខ្ញុំសប្បាយ/
គ) ពេលមួយដែលខ្ញុំភ័យខ្លាច/ពេលមួយដែលខ្ញុំសប្បាយរីករាយ

● គ្រូជ្រើសរើសចំណុចមួយក្នុងចំណោមចំណុច ៣ របស់អារម្មណ៍ ឧ. ចំណុច(ខ)។ គ្រូនឹងគូររូបភាព២នៅលើក្រដាស។ ដោយរូបភាពទី១ តំណាងឱ្យអារម្មណ៍ទី១ ចំណែកឯរូបភាពទី២តំណាងឱ្យអារម្មណ៍ ទី២។ ចូររំឭកប្រាប់សិស្សថា ការចងចាំទាំង ២ នេះ គឺមិនមានទាក់ទងគ្នានោះទេ។ គ្រូត្រូវត្រួតពិនិត្យមើលថា សិស្សយល់ច្បាស់ហើយ ឬនៅ។

ឧទាហរណ៍ថា អ្នកជ្រើសរើសយកចំណុច (ខ) ដូច្នេះតើរូបភាពចំនួន២អ្វីខ្លះ ដែលអ្នកនឹងគូ? (រូបភាពទី១ គឺៈ បង្ហាញពីពេលវេលានៅក្នុងជីវិតរបស់ខ្ញុំដែលជាពេលវេលាខ្ញុំខឹងហើយរូបភាពទី២ៈជាពេលវេលាមួយក្នុងជីវិតរបស់ខ្ញុំដែលខ្ញុំសប្បាយរីករាយ។

● គ្រូលើកទឹកចិត្តសិស្សឱ្យអង្គុយឆ្ងាយពីគ្នា ប្រសិនបើពួកគេចង់។ នេះ គឺមិនមែនជាមេរៀនដែល ត្រូវគូររូបភាពនោះទេ ដូច្នេះសិស្សទាំងអស់គ្នា មិនគួរព្រួយបារម្មណ៍អំពីគុណភាព នៃការគូររបស់ពួកគេនោះទេ ប៉ុន្តែអ្វីដែលសំខាន់នោះគឺ ពួកគេមានឱកាសបង្ហាញអារម្មណ៍ដែលពួកគេធ្លាប់មាន នៅពេលដែលពួកគេជ្រើសរើសគូអារម្មណ៍ណាមួយមកធ្វើការគូ។

● គ្រូលើកទឹកចិត្តសិស្សឱ្យអង្គុយស្ងៀមស្ងាត់រយៈពេលមួយសន្ទុះសិន មុនពេលដែលពួកគេ ចាប់ផ្តើមគូររូបភាពទាំងនោះ។ ជំរុញពួកគេឱ្យប្រើប្រាស់ពណ៌ និងប្រើប្រាស់រូបរាងខុសៗគ្នា ដើម្បីតំណាងឱ្យអារម្មណ៍របស់ពួកគេ។ ផ្តល់ឱ្យពួកគេនូវរយៈពេលប្រហែលជា២០នាទី។

នៅពេលសិស្សទាំងអស់បានបញ្ចប់ការគូរសរបស់ពួកគេគ្រូឱ្យពួកគេរក្សាទុករូបសិនសម្រាប់ការប្រើប្រាស់សកម្មភាពបន្ទាប់ទៀត។

## សកម្មភាពសំខាន់។

🕑 ៦០ នាទី

● គ្រូសរសេរនៅលើក្រដាសផ្ទាំងធំថា ៖ "៣ ជំហានជួយយើងដើម្បីឱ្យគ្រប់គ្រងអារម្មណ៍ពិបាកៗ"

កាលពីមេរៀនមុន យើងទាំងអស់គ្នាបានជជែកគ្នាអំពីទង្វើវិជ្ជមាន ដែលជួយយើងឱ្យដោះស្រាយនូវអារម្មណ៍ដែលពិបាកៗ។ នៅក្នុងសកម្មភាពដែលទើបនឹងបានអនុវត្តមុននេះ យើងទាំងអស់គ្នាបានចាប់ផ្តើមកំណត់ និងស្វែងយល់ពីអារម្មណ៍ដែលកើតឡើងផ្ទាល់ក្នុងជីវិតរបស់យើង។ ការធ្វើបែបនេះ គឺជួយយើងកាន់តែយល់ពីអារម្មណ៍របស់ខ្លួនដោយសារតែយើងទាំងអស់គ្នាបានប្រើប្រាស់បទពិសោធជីវិតពិតនៅក្នុងជីវិតរបស់យើង។ បន្ទាប់នេះ ខ្ញុំនឹងអានរឿងមួយឱ្យអ្នកទាំងអស់គ្នាស្តាប់ ហើយខ្ញុំចង់ឱ្យអ្នកធ្វើការស្រមើស្រមៃខ្លួនរបស់អ្នកទៅជាផ្នែកមួយនៃរឿងនោះផងដែរ។ ចំពោះអារម្មណ៍ដែលអ្នកមាន គឺគ្រាន់តែបង្ហាញនៅលើក្រដាស។ តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួចហើយ ឬ នៅ?

● គ្រូអានរឿងប្រាប់សិស្សទាំងអស់គ្នា។ (មើលឯកសរសម្រាប់សិស្ស/ឯកសារបន្ថែម)

● គ្រូសរសេរសំណួរខាងក្រោម ហើយឱ្យសិស្សពិភាក្សានៅក្នុងក្រុមតូចមួយ។
ក) តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលដែលនរណាម្នាក់កុហកអ្នក?
ខ) តើអ្នកមានអារម្មណ៍ដូចម្តេច ចំពោះការបាត់បង់មិត្តភក្តិ?

គ) តើអ្នកធ្លាប់មានបទពិសោធជួបនូវស្ថានការណ៍បែបនេះពីមុនមកដែរឬទេ?

● គ្រូឱ្យសិស្សទាំងអស់គ្នាធ្វើការពិភាក្សាសំណួរជាមួយគ្នា ហើយបន្ទាប់មកឱ្យសួរពួកគេនូវអ្វីដែលពួកគេបានពិភាក្សា ជំហានទី១ នៅក្នុងការពិបាកគ្រប់គ្រងអារម្មណ៍គឺៈ

សរសេរជំហានទី១ ៖ តើខ្ញុំកំពុងតែមានអារម្មណ៍អ្វី?

ចូរធ្វើការពន្យល់សិស្សថាជំហានដំបូងគឺត្រូវតែស្គាល់ពីរបៀបដែលយើងទាំងអស់គ្នាមានអារម្មណ៍និងត្រូវទទួលស្គាល់នូវអារម្មណ៍ដែលពិបាកៗឬអារម្មណ៍អវិជ្ជមានដែលយើងកំពុងមានដោយត្រឡប់ទៅមើលសកម្មភាពទី១ ដែលយើងបានធ្វើ។ នេះគឺជាឧទាហរណ៍គំរូមួយដែលបង្ហាញអំពីការព្យាយាមក្នុងការបញ្ចេញនូវអារម្មណ៍ដែលយើងមាន។ កុំព្យាយាមលាក់ទុក និងគេចវេសមិនទទួលស្គាល់អារម្មណ៍របស់ខ្លួន(មើលសេចក្តីណែនាំសម្រាប់គ្រូ)

● គ្រូសួរសិស្សថា តើ "របៀបដែលខ្ញុំមានអារម្មណ៍" មានន័យដូចម្តេច? ចំណុចសំខាន់ ដែលពួកគេគួរតែយល់គឺមានន័យថា យើងទាំងអស់គ្នាចាំបាច់ត្រូវតែធ្វើការពិព៌ណនាថា តើយើងទាំងអស់គ្នាមានអារម្មណ៍ដូចម្តេចនៅពេលយើងគិតអំពីស្ថានការណ៍ពិត ឬក៏នៅពេលដែលយើងពិភាក្សាជាមួយនឹងអ្នកដទៃ។ នោះគឺគ្រាន់តែជាមធ្យោបាយមួយតែប៉ុណ្ណោះដែលយើងអាចឆ្លើយចំពោះសំណួរ "តើខ្ញុំកំពុងមានអារម្មណ៍អ្វី?"។

● គ្រូឱ្យសិស្សទាំងអស់ធ្វើការពិភាក្សាគ្នានូវគំនិតទាំងអស់នេះរយៈពេលមួយសន្ទុះ ហើយសួរ សំណួរមួយចំនួនប្រសិនបើចាំបាច់ ហើយបន្ទាប់មកប្រាប់ពួកគេឱ្យកត់ត្រានូវ ជំហានទី១៖ តើខ្ញុំកំពុងតែមានអារម្មណ៍អ្វី? ចូលក្នុងសៀវភៅរបស់ពួកគេហើយនៅខាងក្រោម ចំណុចនេះពួកគេសរសេរចូលនូវគំនិតរបស់ពួកគេផ្ទាល់ ដែលនិយាយពីអ្វីដែលពួកគេចង់មានន័យចំពោះចំណុចនោះ។

● គ្រូសរសេរជំហានទី២ ៖ ហេតុអ្វីបានជាខ្ញុំមានអារម្មណ៍ដូច្នោះ?

ចូរពន្យល់ប្រាប់សិស្សថា ជំហានបន្ទាប់ គឺត្រូវសួរខ្លួនឯងថា "ហេតុអ្វី?" ដើម្បីព្យាយាមយល់ពីអ្វីបានកើតឡើងដែលធ្វើឱ្យយើងមានអារម្មណ៍មានអារម្មណ៍ដូចនេះ(មើលសេចក្តីណែនាំសម្រាប់គ្រូ)។យើងអាចធ្វើដូច្នោះបានដោយការព្យាយាមយល់ពីទង្វើរបស់អ្នកដទៃ។ ឧទាហរណ៍ ៖ ហេតុអ្វីបានជាគាត់/នាង សម្តែងអាកប្បកិរិយា/ធ្វើសកម្មភាពបែបនេះដែលធ្វើឱ្យយើងមានអារម្មណ៍ទៅនឹងសកម្មភាពនេះ។ ឧទាហរណ៍ ត្រឡប់ទៅមើលករណីក្នុងរឿងដែលអ្នក/លោក គ្រូបានអានម្តងទៀត ហើយធ្វើការពន្យល់ថាវា គឺសំខាន់ដែលយើងព្យាយាមយល់អំពីមូលហេតុ ដែលមិត្តភក្តិរបស់យើងមានអារម្មណ៍ថា នាង/គាត់ចាំបាច់ត្រូវតែកុហកយើងក្នុងពេលនោះ។

●គ្រូសួរពួកគេថា តើ"ការព្យាយាមយល់នូវទង្វើរបស់អ្នកដទៃ" មានន័យថាដូចម្តេច? ចំណុចសំខាន់ ដែលពួកគេគួរតែយល់ គឺថានៅពេលដែលយើងព្យាយាមដាក់ខ្លួនរបស់យើងទៅក្នុងស្ថានភាពរបស់នរណាម្នាក់ គឺមានន័យថាយើង "យល់ចិត្ត" របស់អ្នកដទៃ។ ការយល់ចិត្ត គឺជាជំនាញដ៏សំខាន់មួយដើម្បីជួយយើងឱ្យរៀបចំនូវអារម្មណ៍ដែលពិបាកៗ។ វាមិនមានន័យថាយើងត្រូវតែយល់ស្របជាមួយនឹងអាកប្បកិរិយារបស់បុគ្គលទាំងអស់នោះឬក៏មានអារម្មណ៍ដូចពួកគេនោះទេ ប៉ុន្តែយ៉ាងហោចណាស់ក៏យើងអាចព្យាយាមយល់ពីពួកគេផងដែរ។ រំឭកពួកគេ នូវអ្វីដែលពួកគេបានធ្វើនៅក្នុងសកម្មភាពទី១ ដើម្បីព្យាយាមយល់ពីអារម្មណ៍របស់ពួកគេ-ពួកគេបានគូររូបភាពជាច្រើន។ ឱ្យពួកគេនឹករកនូវគំនិតចំពោះវិធីផ្សេងៗទៀតដែលពួកគេអាចធ្វើដូច្នេះបាន។ (មើលសេចក្តីណែនាំសម្រាប់គ្រូ)

●គ្រូអនុញ្ញាតឱ្យសិស្សធ្វើការពិភាក្សាជាមួយគ្នាអំពីគំនិតទាំងអស់នេះរយៈពេលមួយសន្ទុះ ហើយសួរសំណួរពួកគេប្រសិនបើចាំបាច់ ហើយបន្ទាប់មកប្រាប់ពួកគេឱ្យចម្លងជំហានទី២ ៖ ហេតុអ្វីបានជាខ្ញុំមានជាអារម្មណ៍ដូច្នោះ? ចូលក្នុងសៀវភៅរបស់ពួកគេ។ នៅខាងក្រោមចំណុចនេះពួកគេសរសេរចូលនូវពាក្យរបស់ពួកគេ ដែលជាអ្វីដែលពួកគេចង់មានន័យចំពោះ ចំណុចនោះ។

● គ្រូសួរពួកគេថាតើអ្វីដែលពួកគេគិតថាជំហានទី៣នឹងនិយាយអំពីដោយផ្អែកទៅលើសាច់រឿងក្នុងករណីសិក្សា

នាំគ្នាត្រឡប់ទៅកាន់រឿងនោះម្តងទៀត - យើងទាំងអស់គ្នាដឹង ឬយ៉ាងហោចណាស់ ក៏យើងគិតថាមិត្តភក្តិរបស់យើងបានកុហកពួកយើង។ យើងដឹងថា គេមិនដែលធ្វើដូច្នោះទេ ពីមុនមក ហើយអ្នកដទៃក៏ប្រហែលជាមិនជឿយើងដែរ។ ចំពោះអារម្មណ៍ដែលយើងមានអំពីស្ថានការណ៍ គឺត្រូវបានជឿជាក់ និងខ្វះខាតការជឿជាក់នៅក្នុងមិត្តភាពរបស់យើង។យើងមានអារម្មណ៍ដូច្នេះគឺដោយសារតែមិត្តភក្តិរបស់យើងបានកុហកពួកយើង។នៅក្នុងរឿងនេះផងដែរ យើងបានព្យាយាមបំភ្លេចអំពីរឿងរ៉ាវដែលបានកើតឡើង។

តើនោះគឺជារឿងត្រឹមត្រូវដែលត្រូវធ្វើឬ? ហេតុអ្វី? (វាធ្វើឱ្យយើងខឹង ហើយក៏បានបញ្ចប់ នូវមិត្តភាពរបស់យើង) ដូច្នេះតើអ្វីដែលល្អសម្រាប់យើងដើម្បីធ្វើនៅក្នុងស្ថានការណ៍នេះ?(ប្រឈមមុខជាមួយនឹងបញ្ហា ហើយនិយាយវានៅក្នុងមធ្យោបាយវិជ្ជមាន)។ តើយើងអាចធ្វើដូចម្តេច? (មានតែវិធីមួយគត់ ដែលអាចនិយាយទៅកាន់មិត្តរបស់យើង ហើយពិភាក្សាគ្នាអំពី វិធីដែលយើងមានអារម្មណ៍)។

ដូច្នេះជំហានទី៣ គឺត្រូវតែស្វែងរកនូវទង្វើវិជ្ជមាន។

● គ្រូសរសេរជំហានទី៣ ៖ ជ្រើសរើសនូវមធ្យោបាយមួយ ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ល្អ និងមិនធ្វើឱ្យអ្នកដទៃមានការឈឺចាប់។ឱ្យសិស្សទាំងអស់គ្នាពិភាក្សាគ្នាអំពីគំនិតទាំងអស់នេះរយៈពេលមួយសន្ទុះហើយធ្វើការសួរសំណួរ ប្រសិនបើចាំបាច់ ហើយបន្ទាប់មកប្រាប់ពួកគេឱ្យចម្លងជំហានទី៣ ៖ " ជ្រើសរើស មធ្យោបាយមួយ ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ ល្អ និងមិនធ្វើឱ្យអ្នកដទៃមានការឈឺចាប់"ចូល ក្នុងសៀវភៅរបស់ពួកគេ។ នៅពីក្រោមចំណុចនេះ ពួកគេត្រូវសរសេរនូវពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដែលជាអ្វីដែលពួកគេចង់មានន័យចំពោះចំណុចនោះ។

បញ្ចប់សកម្មភាពដោយធ្វើការសង្ខេបនូវចំណុចសំខាន់ៗ ដែលអ្នកនឹងស្វែងរក នៅក្នុងសេចក្តីណែនាំសម្រាប់គ្រូ និងធ្វើការត្រួតពិនិត្យនូវអ្វីដែលពួកគេបានវិភាគចំណុចទាំងអស់នេះនៅក្នុង កំណត់ត្រារបស់ពួកគេ។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

នាំគ្នាត្រឡប់ទៅមើលរូបភាពរបស់យើង ដែលបានគូរនៅក្នុងសកម្មភាពទី១។

ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាក្រលេកទៅមើលរូបភាព ដែលអ្នកបានគូរនៅក្នុងសកម្មភាពទី១ ដែលបង្ហាញអំពីអារម្មណ៍ខុសៗគ្នាដែលអ្នកបានធ្វើការស្វែងរក។ បន្ទាប់មកខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាយកជំហានទាំង៣នោះមកអនុវត្តជាមួយនឹងអារម្មណ៍នេះ។

តើជំហានទាំង៣នោះមានអ្វីខ្លះ?

● គ្រូឱ្យសិស្សរយៈពេលប្រហែលជា១០ ទៅ ១៥នាទី ដើម្បីគិតអំពីសំណួរនេះដោយស្ងៀមស្ងាត់ ។ ពួកគេមិនបាច់សរសេរអ្វីចូលនោះទេ។ ប្រសិនបើសិស្សមួយចំនួនបានបញ្ចប់ ហើយចង់ធ្វើការចែករំលែកទៅវិញទៅមក ឬក៏ជាមួយនឹងមិត្តរួមថ្នាក់ទាំងអស់ពួកគេក៏ធ្វើដូច្នោះបានដែរ។ផ្ទុយទៅវិញ ចំពោះសិស្សដែលមិនចង់ធ្វើការចែករំលែកនូវរូបភាព ឬក៏គំនិតរបស់ពួកគេ ដូច្នេះពួកគេមិនចាំធ្វើការចែករំលែកក៏បានដែរ។ រំឭកពួកគេថា អ្វីដែលសំខាន់នោះគឺថា ពួកគេបានឆ្លុះបញ្ចាំង និងបង្ហាញពី អារម្មណ៍របស់ពួកគេនៅក្នុងមធ្យោបាយមួយចំនួន។



*អរគុណអ្នកទាំងអស់គ្នា ហើយខ្ញុំទន្ទឹងរង់ចាំជួបអ្នកក្នុងពេលឆាប់ៗ នេះនៅមេរៀនលើក ក្រោយ។*

## ខ្លឹមសារៈសំខាន់

● គោលបំណងនៃមេរៀននេះ គឺត្រូវតែជួយមនុស្សវ័យក្មេង ឱ្យចេះគ្រប់គ្រងអារម្មណ៍ពិបាកៗរបស់ពួកគេនៅក្នុងមធ្យោបាយវិជ្ជមាន។ ចំពោះមេរៀននេះ ទាមទារឱ្យមានការពិភាក្សាគ្នាឱ្យបានច្រើន ហើយគ្រូគួរតែមានអារម្មណ៍ជឿជាក់ក្នុងការដឹកនាំការពិភាក្សានេះ។ វាក៏នឹងអាចជួយគ្រូ ឱ្យអានកំណត់ត្រាទាំងអស់របស់គ្រូពីមេរៀនមុន។

● នៅក្នុងសកម្មភាពទី១ ចូរប្រាកដប្រជាថា សិស្សទាំងអស់យល់ថា ដំបូងពួកគេគួរតែគូររូបភាពដែលបង្ហាញពីអារម្មណ៍ដែលពិបាកៗ ហើយទី២ គឺរូបភាពបង្ហាញពីអារម្មណ៍វិជ្ជមាន។ សំខាន់ត្រូវនឹកឃើញនូវការចងចាំទាំងឡាយណាដែលសប្បាយៗ ដែលយើងមាននៅពេលដែលយើងកំពុងពិភាក្សាគ្នា អំពីទិដ្ឋភាពនៃជីវិតរបស់ពួកយើង។

● ចូរប្រាកដថា សិស្សទាំងអស់ដឹងថា គុណភាពរបស់គំនូរ គឺវាមិនសំខាន់នោះទេ។ អ្វីដែល សំខាន់នោះ គឺការបង្ហាញពីរបៀបដែលពួកគេកំពុងមានអារម្មណ៍នៅក្នុងពេលទាំង២នេះ។ នេះមិនមែនជាមេរៀនជាថ្នាក់បង្រៀនគូរនោះទេ! ចូរប្រាកដថា ពួកគេទាំងអស់គ្នាមិនត្រូវនិយាយអំពីគំនូររបស់ពួកគេនោះទេ ប្រសិនបើពួកគេមិនចង់។

● នៅពេលពិភាក្សាគ្នា "ជំហានទី១ ៖ តើខ្ញុំកំពុងមានអារម្មណ៍អ្វី?" ចូរប្រាកដថា អ្នកធ្វើការ សន្និដ្ឋានចំណុចនេះ គឺនៅពេលដែលយើងទាំងអស់គ្នាមានអារម្មណ៍ពិបាកៗ និងរឹងមាំដែលយើងក៏ប្រហែលជាគិតថាយើងទាំងអស់គ្នាគឺជាមនុស្សអាក្រក់ចំពោះអារម្មណ៍ទាំងអស់នេះ។ ប៉ុន្តែយើងទាំងអស់គ្នា គឺគ្រាន់តែជាមនុស្ស ហើយមនុស្សទាំងអស់គឺសុទ្ធតែមានបទពិសោធន៍ ទាក់ទងនឹងអារម្មណ៍មួយចំនួនដូចជា ភ័យខ្លាច ក្រៀមក្រំ ខឹង ប្រច័ណ្ឌ ចាញ់ប្រាល។ល។ ដូច្នេះយើងចាំបាច់ ត្រូវតែប្រឈមមុខជាមួយនឹងពួកគេជាជាងគេចចេញពីពួកគេ។ ការគេចចេញមួយរយៈ ប្រហែលជាអាចល្អនោះទេ ក៏ប៉ុន្តែការធ្វើបែបនេះ គឺមិនមែនជាការដោះស្រាយបញ្ហានោះទេ។

●ពេលធ្វើការពិភាក្សា"ជំហានទី២ៈ ហេតុអ្វីបានជាខ្ញុំមានអារម្មណ៍ដូច្នោះ?" ពន្យល់ថា មានហេតុផលមួយសម្រាប់រាល់អារម្មណ៍ទាំងអស់ហើយយើងក៏ចាំបាច់ត្រូវធ្វើការស្វែងរកវា ដើម្បី ឱ្យយើងអាចធ្វើការវិភាគនូវវិធីដែលអារម្មណ៍របស់យើងមានឥទ្ធិពលមកលើអាកប្បកិរិយារបស់យើង និងមកលើអ្វីដែលយើងសម្រេចចិត្តធ្វើ។ ប្រសិនបើអ្នកនិយាយខ្លាំងៗដាក់សមាជិក គ្រួសារម្នាក់ ឬក៏មិត្តភក្តិម្នាក់ គឺពួកគេច្បាស់ជាបានធ្វើអ្វីមួយដែលធ្វើឱ្យយើងមានអារម្មណ៍បែបនោះឬនរណាម្នាក់ផ្សេងទៀតបានរៀបចំបានល្អនូវអារម្មណ៍ឬតាមពិតវាអាចកើតចេញមកពីសកម្មភាពផ្ទាល់ខ្លួនរបស់យើង។ ក្នុងគោលបំណងដើម្បីធ្វើបែបដូច្នោះបាន យើងទាំងអស់គ្នាត្រូវតែស្វែងរកនូវកន្លែងស្ងប់ស្ងាត់មួយ ឬវិធី ដើម្បីធ្វើការផ្លេះបញ្ចាំង។ ចំពោះការធ្វើ បែបនេះ គឺអាចការដើរកំសាន្ត ការនិយាយជាមួយនឹងមិត្តភក្តិដែលយើងជឿជាក់សរសេរអ្វីមួយឬក៏គូររូបភាព។ល។ យើងទាំងអស់គ្នា គឺសុទ្ធតែខុសគ្នាហេតុដូច្នេះហើយទើបយើងចាំបាច់ត្រូវធ្វើការស្វែងរកនូវវិធីផ្ទាល់ខ្លួនតែមួយគត់របស់យើងដើម្បីធ្វើឱ្យមានការទាក់ទងជាមួយនឹងរឿងទាំងអស់នោះ ។

● ពេលពិភាក្សា "ជំហានទី៣" រំឭកពួកគេថាមានភាពខុសគ្នាមួយរវាងអារម្មណ៍ និងអាកប្បកិរិយា។ វាមិនមានបញ្ហាអ្វីទេក្នុងការមានអារម្មណ៍ខឹងក៏ប៉ុន្តែវាមិនត្រឹមត្រូវទេដែលយើងមានភាពឃោរឃៅឬក៏ធ្វើឱ្យនរម្នាក់មានអារម្មណ៍មិនល្អ។ ទង្វើវិជ្ជមាន គឺជាទង្វើទាំងឡាយណា ដែលមិនធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ ឬក៏ខ្លួន របស់យើងហើយដែលធ្វើឱ្យយើង មានអារម្មណ៍ល្អផងដែរ។

រឿង : ចូរអ្នកស្រមើស្រមៃថា មិត្តភក្តិរបស់អ្នកកុហកអ្នក។ ពេលនោះអ្នកក៏បានដឹងថា មិត្តភក្តិរបស់អ្នកកុហកអ្នកហើយ អ្នកក៏មានអារម្មណ៍ខឹង។ ផ្ទុយទៅវិញអ្នកចូលចិត្តមិត្តរបស់អ្នកណាស់។ មិត្តនោះជាធម្មតាមិនកុហកទេហើយអ្នកក៏មិនចង់ឱ្យអ្នកដទៃគិតថាអ្នកកំពុងបង្កអោយមាបបញ្ហាផងដែរ។ ដូច្នេះអ្នកក៏សម្រេចចិត្តថាមិនធ្វើអ្វីចំពោះបញ្ហានេះទេហើយ អ្នកក៏បានបញ្ចុះបញ្ចូលខ្លួនអ្នកថាវាគ្មានហេតុផលណាដែលចាំបាច់ត្រូវខឹងនោះទេ។អ្នកក៏បានច្រានអារម្មណ៍មិនល្អនោះចេញពីក្នុងចិត្តរបស់អ្នក ហើយព្យាយាមបំភ្លេចវា។ អ្នកធ្វើហាក់បីដូចជាអ្វីៗគ្រប់យ៉ាងធម្មតា ជាមួយនឹងមិត្តភក្តិរបស់អ្នក ហើយដូចជាគ្មានរឿងអ្វីកើតឡើង។ នៅថ្ងៃបន្ទាប់អ្នកកំពុងលេងបាល់ទះហើយអ្នកលេងវាមិនបានល្អនោះទេហើយ ពេលនោះមិត្តភក្តិរបស់អ្នកក៏បានប្រាប់អ្នកអញ្ចេះអញ្ចុះ។ អ្នកក៏មានអារម្មណ៍ខឹង ហើយក៏មិនដឹង ច្បាស់ដែរថាហេតុអ្វី។ អ្នកចងចាំថា ការកុហកដែលមិត្តរបស់អ្នកបានប្រាប់ ហើយដែលអ្នក បានព្យាយាមបំភ្លេច។ នៅពេលកំពុងតែលេង អ្នកក៏បានទាត់គាត់/នាងយ៉ាងខ្លាំង ហើយគេក៏បានដួលនៅលើដី។ ពេលនោះមិត្តភក្តិរបស់អ្នកក៏បានខឹងយ៉ាងខ្លាំង ហើយបានសួរថា "តើអ្នកឯងមានរឿងអ្វី? ហេតុអ្វីបានជាអ្នកលេងមិនល្អ? អ្នកកំពុងតែធ្វើដូចជាសម្លុត ខ្ញុំ ហើយថែមទាំងទាត់ខ្ញុំឱ្យដួលនៅលើដី!

អ្នកក៏បានឈ្លោះប្រកែកគ្នាយ៉ាងខ្លាំង ហើយអ្នកទាំងពីរក៏បានត្រឡប់ទៅផ្ទះ ទាំងអារម្មណ៍ខឹងហើយបានសម្រេចចិត្តថា អ្នកនឹងមិនចង់ធ្វើជាមិត្តភក្តិ ជាមួយគ្នាជារៀងរហូត។ អ្នកនៅតែមិនប្រាប់គេថា អ្នកគិតថានាង/គាត់ គឺកំពុងកុហកអ្នក។



# មេរៀនទី ១០: ការរួបរួមទាំងអស់គ្នា

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)។

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ហ្វឺត ឬក៏ដីស
- ក្តារខៀនពណ៌ស ឬពណ៌ខ្មៅ
- ខ្មៅដៃ សៀវភៅកត់ត្រា ក្រដាសលាតពណ៌ស (A4)
- ក្រដាសផ្ទាំងធំ ស្កុត

☼ លទ្ធផលរំពឹងទុក ៖

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាចៈ

- ពង្រឹងការសិក្សារបស់ពួកគេ ដោយវិភាគសំដីដែលបានដកស្រង់ ដើម្បីកំណត់ពីវិធីដែលពួកគបង្ហាញការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម។
- ពង្រឹងការសិក្សារបស់ពួកគេដោយបង្ហាញជំនាញយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម តាមរយៈការឆ្លើយតបរបស់ពួកគេចំពោះស្ថានកាណ៍ដែលបានផ្តល់ឱ្យ។

## រំឭកមេរៀនចាស់ 🕑 ២៥ នាទី

- គ្រូសួរ "តើនរណាអាចចែករំលែក នូវអ្វីដែលបានរៀនកាលពីមេរៀនមុនបានដែរឬទេ?"
- គ្រូឱ្យសិស្សពីរបីនាក់ ធ្វើការចែករំលែកនូវគំនិតសំខាន់ៗកាលពីមេរៀនមុន ដល់មិត្តរួមថ្នាក់ ។

## ចំណងជើងមេរៀនទី ១០: ការរួបរួមទាំងអស់គ្នា

### សេចក្តីផ្តើម

● គ្រូប្រាប់សិស្សនៅក្នុងមេរៀនមុនយើងបានសិក្សាពីជំហានទាំង៣ដែលអាចជួយយើងក្នុងការគ្រប់គ្រងអារម្មណ៍ដែលពិបាកៗ ព្រមទាំងជួយយើងឱ្យជៀសវាងការប្រព្រឹត្ត ឬធ្វើការសម្រេចចិត្ត ដែលអាចធ្វើឱ្យអ្នកដទៃ និងខ្លួនរបស់យើងមានការឈឺចាប់ ហើយថែមធ្វើឱ្យយើងមានអារម្មណ៍មិនល្អផងដែរ។ ថ្ងៃនេះ គឺជាមេរៀនចុងក្រោយរបស់យើង ហើយយើងទាំងអស់គ្នាក៏នឹងលេងល្បែងខុសៗគ្នាជាច្រើន ហើយប្រើប្រាស់ល្បែងទាំងអស់នោះ ដើម្បីទាញយកផលប្រយោជន៍ជាមួយគ្នាដែលយើងបានរៀនកាលពីប៉ុន្មានសប្តាហ៍មុន ស្តីពីការអភិវឌ្ឍផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម។ នាំគ្នាចាប់ផ្តើមដោយមានភាពសប្បាយរីករាយ! តើអ្នកទាំងអស់គ្នាត្រៀមខ្លួនរួច ហើយឬ នៅ?

● គ្រូឱ្យសិស្ស ក្រោកឈរឡើងទាំងអស់គ្នា ហើយនាំគ្នាបង្កើតជារង្វង់មួយ។ (គ្រូជ្រើសរើសសិស្សម្នាក់ ឱ្យឈរនៅម្ខាង និងជាអ្នកដែលមិនបានចូលរួមនៅក្នុងជំហានបន្ទាប់ ឧទាហរណ៍ ៖ ឈឿន)។ ចូរកាន់ដៃគ្នាដោយកុំឱ្យដាច់ចេញពីរង្វង់ ហើយអ្នកត្រូវដើរនៅខាងក្រោម និងខាងលើដៃរបស់ពួកគេម្នាក់ៗ ដើម្បីបង្កើតជាចំណងមួយ។ គោលបំណង នៃល្បែងនេះ គឺត្រូវតែស្រាយខ្លួនរបស់អ្នកចេញ ដើម្បីឱ្យអ្នកអាចត្រឡប់ទៅក្នុងរង្វង់វិញ។ អ្នកនឹងមិនអាចស្រាយខ្លួនរបស់អ្នកបានឡើយក៏ប៉ុន្តែ ឈឿន នឹងធ្វើជួយស្រាយ។

ឈឿនខំប្រឹងស្រាយចំណងនោះចេញ ដោយផ្តល់ជាការណែនាំទៅឱ្យសិស្សទាំងអស់គ្នា។ សិស្សដទៃទៀតគ្រាន់តែស្តាប់គាត់បានហើយ ដោយមិនចាំបាច់ឱ្យជាមតិយោបល់អ្វីនោះទេ។ នៅពេលដែលចំណងត្រូវបានស្រាយរួច រង្វង់មួយផ្សេងទៀតក៏ត្រូវបានបង្កើតឡើងប៉ុន្តែពេលនេះអ្នករាល់គ្នាត្រូវមានការជាប់ទាក់ទងគ្នាហើយក៏មិនមាននរណាម្នាក់ធ្វើជា "អ្នកណែនាំ/ប្រធាន"។ ជាថ្មីម្តងទៀតសិស្សត្រូវព្យាយាមស្រាយចំណងនោះជាមួយគ្នា។ នៅពេលដែលសិស្សទាំងអស់បានបញ្ចប់ លោកគ្រូ/អ្នកគ្រូអាចសួរ ៖

● គ្រូសួរៈ តើវិធីណាដែលធ្វើបានលឿនបំផុត? តើល្បែងនេះបានបង្រៀនអ្វីដល់យើង ហើយតើការធ្វើលំហាត់នេះទាក់ទងដូចម្តេចទៅនឹងការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម?

● គ្រូឱ្យសិស្សរិះរកគំនិតថ្មីរបស់ពួកគេ។

● គ្រូចែកក្រដាសពណ៌សA4 ហ្វ៊ីត និងប៊ិក ហើយឱ្យសិស្សទាំងអស់គ្នាសរសេរនូវចំណុចសំខាន់ៗ ។ ហៅសិស្សម្នាក់ឡើងសរសេរចម្លើយមិត្តរួមថ្នាក់ទាំងអស់។ (គ្រូក៏អាចសរសេរនូវចំណុចសំខាន់ទាំងអស់នោះផងដែរដោយអាស្រ័យទៅលើកម្រិតរបស់ថ្នាក់រៀន និងពេលវេលា។ល។)

● គ្រូបិទប័ណ្ណទាំងអស់នោះនៅក្នុងថ្នាក់រៀន។

## សកម្មភាពសំខាន់។

🕑 ៦០ នាទី

● គ្រូសួរៈ តើអ្នកទាំងអស់គ្នា មានដឹងអំពីពាក្យបុរាណ ឬក៏សុភាសិតណា ដែលទាក់ទងទៅនឹងការយល់ដឹងផ្ទាល់ខ្លួន និង ទំនាក់ទំនងសង្គមដែរឬទេ?

ព្រះពុទ្ធបានប្រើពាក្យទាំងអស់នេះ ដើម្បីឱ្យជីវិតរបស់មនុស្សទាំងអស់គ្នាមានន័យ ហើយពាក្យសំខាន់ៗមួយចំនួនរបស់ព្រះអង្គ គឺទាក់ទងទៅនឹងរបៀប ដែលយើងអាចស្វែងយល់ពីខ្លួនឯង តើយើងជានរណា ដើម្បីឱ្យយើងអាចរស់នៅក្នុងជីវិតមួយកាន់តែប្រសើរ និងមានទំនាក់ទំនងល្អ។ នៅក្នុងក្រុមទាំងអស់ គ្រូចង់ឱ្យអ្នកទាំងអស់គ្នាក្រលេកមើលសុភា សិតទាំង១០ របស់ព្រះពុទ្ធ។ នាំគ្នាពិនិត្យមើល ហើយជ្រើសរើស យកសុភាសិតមួយដែលអ្នកគិតថាជាការឆ្លុះបញ្ចាំងដ៏ល្អបំផុតចំពោះអ្វីដែលយើងបានរៀននៅក្នុងមេរៀនការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម ។ នៅក្នុងក្រុមរបស់ អ្នក ចូរជ្រើសរើសយកសុភាសិតចំនួន៥។ សម្រាប់សុភាសិតទាំង៥នេះ អ្នកត្រូវតែបង្ហាញពីរបៀបដែលសុភាសិតទាំងនេះមានការទាក់ទងទៅនឹងអ្វីដែលយើងបានសិក្សាកន្លងមក។ ចូរសរសេរចំណុចសំខាន់របស់សុភាសិតនីមួយៗ លើ ក្រដាសដែលមាននៅលើតុ។

● គ្រូចែកក្រដាសសុភាសិត(មួយសន្លឹកក្នុងមួយក្រុម) និងក្រដាសA4 សម្រាប់ក្រុមនីមួយៗ។ ឱ្យសិស្សទាំងអស់គ្នាអានសុភាសិតទាំងនោះ ហើយព្យាយាមរកនូវគំនិតដោះស្រាយ នូវអ្វីដែលសុភាសិតទាំងនោះចង់និយាយ។ គ្មាននរណាម្នាក់ចាំបាច់ត្រូវឆ្លើយនោះទេហើយនេះគឺអាស្រ័យទៅលើរបៀបដែលសិស្សទាំងអស់គ្នាធ្វើការបកស្រាយសុភាសិតទាំងនោះ។ ឱ្យពួកគេធ្វើដូច្នោះតែម្នាក់ឯង ប៉ុន្តែចូរលើកទឹកចិត្តពួកគេឱ្យបង្ហាញភស្តុតាងសម្រាប់គំនិតទាំងឡាយរបស់ពួកគេ។ គំនិតមួយចំនួន គឺត្រូវបានផ្តល់ឱ្យនៅខាងក្រោមកំណត់ត្រារបស់គ្រូ ក៏ប៉ុន្តែវាជាការល្អប្រសើរបំផុតដែល

ឱ្យសិស្សទាំងអស់ធ្វើការបកស្រាយសុភាសិតទាំងនោះ តាមការយល់ឃើញរបស់ពួកគេ។ នៅពេលដែលសិស្សកំពុងធ្វើបទបង្ហាញលោកគ្រូ/អ្នកគ្រូអាចបន្ថែមនូវចំណុចសំខាន់ ប្រសិនអ្នកយល់ថានៅខ្វះចន្លោះ។ បន្ទាប់ពីសិស្សទាំងអស់បានជ្រើសរើសនូវសុភាសិតទាំង៥របស់ពួកគេចេញពីក្នុងបញ្ជី ដូច្នេះក្រុមនីមួយៗនឹងត្រូវធ្វើបទបង្ហាញនូវសុភាសិតទាំនោះ ទៅកាន់មិត្តរួមថ្នាក់ទាំងអស់។

សិស្សទាំងអស់ចាំបាច់ត្រូវតែអាននូវសុភាសិតទាំងនោះ ព្រមទាំងអត្ថន័យក៏ដូចជារបៀបដែលវាមានទំនាក់ទំនងទៅនឹងអ្វីដែលពួកគេបានសិក្សាអំពីការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម។ ប្រសិនបើសិស្សពិភាក្សាចំណុចដូចគ្នាពួកគេបន្ថែមចម្លើយប្រសិនបើមាន។ ចំពោះចំណុចសំខាន់ៗគួរតែបិទនៅជុំវិញថ្នាក់បន្ទាប់ពីក្រុមនីមួយៗ បានធ្វើបទបង្ហាញរួច។ ធ្វើការទះដៃនូវរាល់ការធ្វើបទបង្ហាញនីមួយៗ។

## បញ្ចប់មេរៀន

🕑 ១៥ នាទី

ការបញ្ចប់មេរៀនដែលមានរយៈពេល១០សប្តាហ៍ ឥឡូវអ្នកទាំងអស់គ្នានឹងត្រូវធ្វើលំហាត់សរសេរមួយ។ ចំពោះគោលបំណងនៃលំហាត់នេះ គឺដើម្បីបង្ហាញអ្វីដែលអ្នកទាំងអស់គ្នាបានសិក្សានៅក្នុងកម្មវិធីដែលបានរៀបចំកន្លងមក។ ខ្ញុំនឹងផ្តល់ឱ្យអ្នកនូវស្ថានការណ៍មួយ។ គ្រូចង់ឱ្យអ្នកគិតអំពីស្ថានកាណ៍នេះហើយបន្ទាប់មកនាំគ្នាធ្វើរឿងពីរ។ទី១ គ្រូចង់ឱ្យអ្នកធ្វើការកំណត់អាកប្បកិរិយាដែលបង្ហាញអំពីការឆ្លើយតបអវិជ្ជមានមួយចំពោះស្ថានការណ៍នោះ ។ ទី២ គ្រូចង់ឱ្យ អ្នកកំណត់អាកប្បកិរិយា ដែលបង្ហាញអំពីការឆ្លើយតប វិជ្ជមានមួយចំពោះស្ថានការណ៍នោះ។ ចូរចងចាំថាអ្នកទាំងអស់គ្នាគួរតែព្យាយាមប្រើប្រាស់នូវជំនាញអ្វី ដែលអ្នកបានរៀននៅអំឡុងពេលសិក្សាមុខវិជ្ជានេះ។ តើអ្នកទាំង អស់គ្នាត្រៀមខ្លួនរួចហើយឬនៅ?

● គ្រូសរសេររៀបរាប់ពីស្ថានការណ៍ និងសំណួរប្រឡងនៅលើក្តារខៀន ហើយឱ្យសិស្សយចម្លងដាក់លើក្រដាសជាងអ្នកចែកឱ្យពួកគេ។

ការប្រឡងចុងក្រោយ

ស្ថានការណ៍ៈ អ្នកនឹងនៅក្នុងក្រុមមួយ ដែលទាមទារឱ្យមានការចូលរួមពីអ្នកទាំងអស់គ្នា។ គ្រូបានផ្តល់ការណែនាំជាច្រើន ហើយក្រុមការងារក៏បានចាប់ផ្តើម។ អ្នកគិតថា អ្នកមិនអាចនិយាយអ្វី ដែលអ្នកចង់និយាយ ឬចូលរួម ប៉ុន្តែដោយសារតែមានអ្នកផ្សេងនៅក្នុងក្រុមគ្រប់គ្រងលើការងារ។

១) តើអាកប្បកិរិយា/ទង្វើអ្វី ដែលអ្នកអាចពិពណ៌នាជាលក្ខណៈអវិជ្ជមានចំពោះស្ថានការណ៍មួយនេះ? (៤ពិន្ទុ)
២) តើអាកប្បកិរិយា/ទង្វើអ្វី ដែលអ្នកអាចពិពណ៌នា ជាលក្ខណៈវិជ្ជមានចំពោះស្ថានការណ៍ មួយនេះ?(៤ពិន្ទុ)
៣) តើអ្នកគិតដូចម្តេចដែរ ចំពោះអ្វីដែលអ្នកបានរៀនដោយផ្ទាល់ពីកម្មវិធីដែលបានរៀបចំនេះ ដើម្បីបង្កើននូវការយល់ដឹងពីខ្លួនរបស់អ្នក ដែលក្នុងនាមជាមនុស្សម្នាក់?(២ពិន្ទុ)
៤) តើអ្នកគិតដូចម្តេចដែរចំពោះអ្វីដែលអ្នកបានរៀនដោយផ្ទាល់ពីកម្មវិធីដែលបានរៀបចំនេះដើម្បីបង្កើនសមត្ថភាពរបស់អ្នក ក្នុងការពង្រឹងការទំនាក់ទំនងក្នុងសង្គមឱ្យកាន់តែមានភាពរឹងមាំ និងប្រសើរ?(២ពិន្ទុ)

ធ្វើការប្រមូលការប្រឡងទាំងអស់នៅចុងបញ្ចប់នៃមេរៀន។

បញ្ចប់ថ្នាក់រៀនទាំងមូល ដោយនិយាយថាមេរៀនសំខាន់បំផុតគឺឱ្យយើងដឹង ពីរបៀបនៃការឆ្លើយតបរបស់យើងចំពោះស្ថានការណ៍ទាំងអស់ ដែលអាចជះឥទ្ធិពលមកលើរបៀបដែលយើងប្រព្រឹត្ត និងការសម្រេចចិត្តដែលយើងធ្វើ។ ដោយការប្រើប្រាស់ ៣ជំហានដើម្បីគ្រប់គ្រងអារម្មណ៍ពិបាកៗរបស់យើងដោយគិតអំពីការឆ្លើយតបបែបវិជ្ជមាន។

នាំគ្នាឈរនៅក្នុងរង្វង់មួយ ដោយដាក់ដៃទាំងពីរនៅលើស្មារបស់បុគ្គលដែលនៅពីខាងមុខ អ្នក។ ចូរគិតនូវពាក្យមួយដែលតំណាងឱ្យអ្នកក្នុងទិដ្ឋភាពវិជ្ជមានមួយរបស់ផ្នែកនៃក្រុមនេះ។ ពេលខ្ញុំនិយាយថា "រួចរាល់" ចូរនិយាយពាក្យនេះចំនួនបី ដងទៀតហើយ បន្ទាប់មកនាំគ្នាទះដៃ។

● គ្រូៈ អរគុណចំពោះការបង្កើតឡើងកម្មវិធីមួយនេះ ដែលបានផ្តល់ជាបទពិសោធន៍សិក្សាដ៏ល្អ មួយសម្រាប់ខ្ញុំ ហើយខ្ញុំសង្ឃឹមថា អ្នកអាចបន្តបង្កើតនូវអ្វី ដែលយើងបានរៀន និងយកវា ទៅអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក។

## ខ្លឹមសារសំខាន់

●គោលបំណងនៃមេរៀននេះ គឺដើម្បីបង្រួមកម្មវិធីដែលបានបង្កើតឡើងរយៈពេល១០សប្តាហ៍។ បន្ទាប់ពីសកម្មភាពនីមួយៗ គ្រូត្រូវសួរនូវអ្វីដែលសិស្សបានរៀន អំពីការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គម។ ចំពោះមេរៀនដែលបានសិក្សា គឺត្រូវបានសរសេរនៅលើក្រដាស A4 ហើយបន្ទាប់មកបិទវានៅជុំវិញបន្ទប់រៀន។

ចំណែកឯសកម្មភាពចុងក្រោយ គឺជាការប្រឡង និងការរំឭកមេរៀន ដែលនឹងបង្រួមមេរៀនទាំងអស់។ អ្នកទាំងអស់គ្នានឹងអាចរៀនទាន់មេរៀន នៅពេលដែលធ្វើការប្រឡង។ គោលបំណង គឺត្រូវតែជួយពួកគេឱ្យ ធ្វើការវិភាគ និងសិក្សានូវអ្វី ដែលពួកគេបានរិះរកនៅក្នុងកម្មវិធីដែល រយៈពេល១០ សប្តាហ៍កន្លងមក និងមិនធ្វើឱ្យពួកគេមានអារម្មណ៍ថា ពួកគេត្រូវបានគម្រាមកំហែងដោយការប្រឡង។

●ការលេងល្បែងចងចំណាង ដោយមានការធ្វើការងារជាក្រុម គឺការធ្វើការងាជាមួយគ្នា ដែលអ្នកអាចដោះស្រាយបញ្ហាអ្វីមួយបានយ៉ាងឆាប់រហ័ស។វាក៏បានបង្ហាញអំពីតម្រូវការរបស់បំណិនស្តាប់ដ៏ល្អមួយនិងតម្រូវការនៃការប្រព្រឹត្តចំពោះអ្នកដទៃជាមួយនឹងការគោរព។

●ពាក្យស្លោកទាំងអស់អាចលើកឡើងនូវចំណុចជាច្រើន ដែលបានធ្វើការសិក្សាពេញ មេរៀនទាំងអស់។ ចំណុចសំខាន់មួយ ដែលគួរតែកើតមានឡើងគឺៈ

- ជឿជាក់មកលើខ្លួនអ្នក និងអ្នកដទៃ
- ភាពអាចំកំបាំង
- ការមើលទៅកាន់ខ្លួនរបស់អ្នក ហើយរកឱ្យឃើញថា អ្នកជានរណា-ការដឹងដោយខ្លួនឯង
- ការសិក្សាដើម្បីចែករំលែកពីអារម្មណ៍ និងបទពិសោធន៍របស់អ្នក
- ការគោរពខ្លួនអ្នក និងអ្នកដទៃ
- ទទួលស្គាល់ថា អារម្មណ៍ដែលពិបាកៗ គឺជារឿងធម្មតា ហើយកុំមានន័យថា អ្នកជាមនុស្សមិនល្អ
- ការស្គាល់ពីតម្រូវការ ដើម្បីស្តាប់អ្នកដទៃ
- ការសប្បាយរីករាយ ជាមួយនឹងអារម្មណ៍ដែលទង្វើវិជ្ជមានអាចបង្កើតឡើង។

មេរៀនទី១០ : ចូររួបរួមទាំងអស់គ្នា!

ឯកសារចែកសិស្ស/ឯកសារបន្ថែម ខ្លឹមសារ ដែលដកស្រង់ពីទស្សនៈព្រះពុទ្ធ

| |
|---|
| “អ្វីៗទាំងអស់ ដែលយើងមាន គឺជាលទ្ធផលនៃអ្វីដែលយើងបានគិត។ ចិត្ត គឺជាអ្វីទាំងអស់។ អ្វីដែលយើងគិត គឺនឹងកើតឡើង។” |
| “ការធ្វើខុសទាំងអស់បានកើតមានឡើង ដោយសារតែចិត្តរបស់យើង។ ប្រសិនបើចិត្តត្រូវ បានប្រែប្រួល តើការធ្វើខុសនៅតែកើតមានទៀតឬទេ ?” |
| “ទៀនរាប់ពាន់អាចត្រូវបានដុតបំភ្លឺចេញពីទៀនតែមួយ ហើយជីវិតរបស់ទៀននឹងមិនត្រូវបានធ្វើអោយខ្លីឡើយ។ សុភមង្គលមិនដែលធ្លាក់ចុះដោយការចែករំលែកនោះទេ។” |
| “កុំអាស្រ័យទៅលើអតីតកាល កុំសុបិន្តសម្រាប់អនាគត ចូរសញ្ជឹងគិតពីពេលវេលាបច្ចុប្បន្ន។” |
| “បើទោះបីជាអ្នកបានអានពាក្យស័ក្តសិទ្ធជាច្រើនបើទោះបីជាអ្នកនិយាយច្រើនតើចំនុចល្អអ្វីដែលពួកគេនឹងធ្វើប្រសិនបើអ្នកមិនបានប្រព្រឹត្តដោយពឹងផ្អែកទៅលើពួកគេ ?” |
| “សូម្បីតែការស្លាប់ គឺមិនត្រូវបានធ្វើឱ្យភ័យខ្លាច ដោយបុគ្គលដែលបានរស់នៅយ៉ាងស្អុកស្គម្ភ។” |
| “សន្តិភាព គឺកើតចេញមកពីខាងក្នុង។ កុំស្វែងរកវានៅខាងក្រៅ។” |
| “នៅលើមេឃ គឺមិនមានអ្វីសំគាល់ខាងកើត និងខាងលិចទេ ក៏ប៉ុន្តែមនុស្សបង្កើតការ សំគាល់ទាំងនោះចេញពីក្នុងចិត្តរបស់ពួកគេផ្ទាល់ ហើយបន្ទាប់មកក៏គិតថា ពួកគេ គឺពិត។” |
| “ប្រសិនបើយើងអាចមើលឃើញច្បាស់អព្ភូហេតុរបស់ផ្កាមួយទងនោះជីវិតរបស់ យើងនឹងអាចមានការផ្លាស់ប្តូរ។” |
| “មានតែបរាជ័យពិតក្នុងជីវិតទេ ដែលមិនពិតចំពោះអ្វីមួយល្អបំផុតដែលត្រូវបានដឹង។” |



## ៥. សំណួរសរសេរ សម្រាប់វាយតម្លៃសិស្ស

១) តើអាកប្បកិរិយា/ទង្វើអ្វី ដែលអ្នកអាចពណ៌នា ជាលក្ខណៈអវិជ្ជមានចំពោះស្ថានការណ៍មួយនេះ?(៤ពិន្ទុ)
២) តើអាកប្បកិរិយា/ទង្វើអ្វី ដែលអ្នកអាចពិពណ៌នា ជាលក្ខណៈវិជ្ជមានចំពោះស្ថានការណ៍មួយនេះ?(៤ពិន្ទុ)
៣) តើអ្នកគិតដូចម្តេចដែរ ចំពោះអ្វីដែលអ្នកបានរៀនដោយផ្ទាល់ពីកម្មវិធីដែលបានរៀបចំនេះ ដែលបានបង្កើននូវការយល់ដឹងពីខ្លួនរបស់អ្នក ដែលក្នុងនាមជាមនុស្សម្នាក់?(៣ពិន្ទុ)
៤) តើអ្នកគិតដូចម្តេចដែរ ចំពោះអ្វីដែលអ្នកបានរៀនដោយផ្ទាល់ពីកម្មវិធីដែលបានរៀបចំនេះ ដែលបានបង្កើនសមត្ថភាពរបស់អ្នក ដើម្បីពង្រឹងការទំនាក់ទំនងសង្គមឱ្យកាន់តែមានភាពរឹងមាំ?(៤ពិន្ទុ)

ការផ្តល់ពិន្ទុ ៖

១) ឱ្យចាប់ពី១ រហូតដល់៤ពិន្ទុ សម្រាប់អាកប្បកិរិយា/ការសម្រេចចិត្តអវិជ្ជមាន ដែលសិស្សបានផ្តល់ឱ្យ ដោយធ្វើការប្រើប្រាស់បញ្ជីដែលមាននៅក្នុងសេចក្តីណែនាំសម្រាប់គ្រូ ដើម្បីជួយណែនាំអ្នក។
២) ឱ្យចាប់ពី១ រហូតដល់៤ពិន្ទុ សម្រាប់អាកប្បកិរិយា/ការសម្រេចចិត្តអវិជ្ជមាន ដែលសិស្សបានផ្តល់ឱ្យនូវការប្រើប្រាស់បញ្ជីដែលមាននៅក្នុងសេចក្តីណែនាំសម្រាប់គ្រូ ដើម្បីជួយណែនាំអ្នក។

*ចំពោះសម្លើយសម្រាប់សំណួរ ទី៣) និង ទី៤) នឹងធ្វើការផ្លាស់ប្តូរ ដរាបណាអ្នកពេញចិត្តថា សិស្សទាំងអស់បង្ហាញនូវការសិក្សា ដែលអាចឱ្យពួកគេអនុវត្តបាន តាមរយៈចម្លើយរបស់ពួកគេ ដែលអាចផ្តល់ឱ្យពួកគេចំនួន២ពិន្ទុ។*

**កំរិតនៃការផ្តល់ពិន្ទុ-ពិន្ទុនៅក្នុងការធ្វើតេស្តនេះ គឺទាក់ទងទៅនិងពិន្ទុទូទៅ**

| %ឆ្លើយបានត្រឹមត្រូវ | ពិន្ទុ | និទ្ទេស |
|---|---|---|
| ៦៦%ទៅ១០០%ល្អ | ច្រើនជាង៩ពិន្ទុ | ល្អ |
| ៥១%ទៅ៦៥%ល្អ | ៨ទៅ៩ពិន្ទុ | បង្គួរ |
| ក្រោម៥០%ល្អ | តិចជាង៨ពិន្ទុ | ខ្សោយ |

ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

## ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា...................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ...............

| | ចំណុចត្រូវដាក់ពិន្ទុ | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ | បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | |
| | **សង្កេតឥរិយាបថសិស្ស** | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក ........................សាលា ............................... ថ្នាក់ទី ........... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព

នាយកសាលា

ថ្ងៃទី ........... ខែ ............. ឆ្នាំ ...........

ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| **ការអង្កេតថ្នាក់រៀន** | | | | | **ការវាយតម្លៃគ្រូបំណិនជីវិត** |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្ដើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិតៈ |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្ដាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀន ដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ .......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ .....................................


តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច?
ក្រៀមក្រំ
សប្បាយ
ខឹង
ភ័យខ្លាច សប្បាយចិត្ត
ភ្ញាក់ផ្អើល ធម្មតា
USAID